ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ការស្លាប់របស់ អៀង សារី

◆ ប្រជាជនកម្ពុជាចង់ឱ្យសាលាក្ដីខ្មែរក្រហមពន្លឿនការកាត់ទោស

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៩ ខែមីនា ឆ្នាំ២០១៣

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥៩ ខែមីនា ឆ្នាំ២០១៣

## មាតិកា

◆ការស្លាប់របស់ អៀង សារី ....... ១

**ផ្នែកឯកសារ**

◆អនុលេខាតំបន់៤២រៀបរាប់ពី ....... ២

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១ ....... ៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ការកេណ្ឌយុវជន និងមនោគមវិជ្ជា ....... ២៤

◆កុមារភាពភ័យខ្លាច ....... ៣៣

**ផ្នែកច្បាប់**

◆មរណភាព អៀង សារី ....... ៣៦

◆សេចក្ដីប្រកាសរបស់សហចៅក្រមស៊ើប ....... ៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ចៅក្រមអង្គបុរេជំនុំជម្រះជាតិ និង ....... ៤៧

◆អង្គជំនុំជម្រះតុលាការកំពូលបដិសេធ ....... ៥០

◆ប្រជាជនចង់ឲ្យសាលាក្ដីខ្មែរក្រហមពន្លឿន ....... ៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការព្យាបាលរបួស និងការផ្សះផ្សា ....... ៥៩



ប្រជាជនមកចូលរួមពិធីបុណ្យសព អៀង សារី ដែលប្រារព្ធធ្វើនៅអតីតផ្ទះរបស់គាត់ ស្ថិតនៅក្នុងភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ



ផ្ទះរបស់ អៀង សារី នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ *ឆាយ ឈុនលី, លី សុខឃាង, អាន រ៉ាហ៊ីន, អាន ហាញឌុល, ឡេង លីណា, កាល ហេនរេធ* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា* ***អ្នកបកប្រែ*** ៖ *នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ផេង ពង្ស* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការស្លាប់របស់ អៀង សារី

ខ្ញុំពិតជាពិបាកនិងមានវិប្បដិសារីសម្រាប់មេដឹកនាំក្នុងរបបមួយដែលបណ្តាលឲ្យមានការស្លាប់ជីវិតមនុស្សរាប់លាននាក់នោះ ។

ការស្លាប់របស់ អៀង សារី មិនមែនជាជោគជ័យទេ ហើយការស្លាប់នោះមានតម្លៃតិចតួចបំផុតសម្រាប់ជនរងគ្រោះនៃរបបកាប់សម្លាប់ដែលរង់ចាំការស្វែងរកយុត្តិធម៌ដោយក្តីអំណត់ ។

អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែបានធ្វើការសន្យាក្នុងការស្វែងរកយុត្តិធម៌ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជានោះទេ ថែមទាំងដល់មនុស្សជាតិទាំងមូលផង ។ បញ្ហារដ្ឋបាលនិងការវិវាទផ្លូវនយោបាយមិនគួររារាំងដល់ការរក្សាពាក្យសន្យាដ៏មុតមាំនោះឡើយ ។ ជនរងគ្រោះគួរណាស់បានឃើញការបញ្ចប់សំណុំរឿង ហើយតុលាការគួរតែត្រូវបានអនុញ្ញាតឲ្យបញ្ចប់ការងារតាមឆន្ទៈរបស់ខ្លួន ។

**ឆាំង យុ**


អៀង សារី ឆ្នាំ១៩៧៧


អៀង សារី ឆ្នាំ១៩៩៦


សាកសពរបស់ អៀង សារី ពេលដឹកទៅដល់ស្រុកម៉ាឡៃនៅវេលាម៉ោង១០:៣០នាទីយប់ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣

អៀង សារី ឆ្នាំ២០០៧

# អនុលេខាតំបន់៤២រៀបរាប់ពីសកម្មភាពក្បត់បដិវត្តន៍

***ដកស្រង់ចេញពីឯកសារ J០០៧៩២***

*នួន រឿន ហៅ ទៀង អាយុ៣០ឆ្នាំ កើតនៅភូមិកន្ទែងរមាស ឃុំសំបួរមាស ស្រុកកំពង់សៀម តំបន់៤១ ភូមិភាគបូព៌ា ។ ប្រពន្ធឈ្មោះ អ៊ិន ហេង ហៅ ផុន ធ្វើការនៅពេទ្យស្រុកចម្ការលើ ។ រឿន មានបងប្អូនពីរនាក់ ។ បងប្រុសរបស់គាត់ឈ្មោះ អឿន ប្រធានសហករណ៍ស្វាយទាប ស្រុកចម្ការលើ ។ ឪពុកឈ្មោះ នួន អេង អតីតទាហានឥស្សរៈ រស់នៅចម្ការចេក កងពល១៧៤ ភូមិភាគកណ្តាល និងម្តាយឈ្មោះ កាក់ (ស្លាប់) ។ រឿន ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧ ដោយចោទប្រកាន់ថាជាខ្សែ សេ.អ៊ី.អា បង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ ។ នៅក្នុងនោះ រឿន ក៏បានរៀបរាប់ពីសកម្មភាពក្បត់របស់ខ្លួនជាមួយនឹងខ្សែសង្វាក់ចំនួន៤៣នាក់ទៀត ។ ចម្លើយសារភាពរបស់ នួន រឿន ត្រូវបានបញ្ចប់នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ដោយមានស្នាមផ្តិតមេដៃរបស់ រឿន ផ្ទាល់ និងមានឈ្មោះ ខន ជាអ្នកចម្លង សរុបចំនួនម្ភៃប្រាំបួនទំព័រ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ នួន រឿន ។*

*តាំងពីតូចមក ខ្ញុំរស់នៅជាមួយឪពុកម្តាយរហូតដល់អាយុ១៨ឆ្នាំក្រោយពីម្តាយស្លាប់ ខ្ញុំក៏ទៅរស់នៅជាមួយឪពុកមា ។ គាត់ក៏យកខ្ញុំទៅបួសរៀននៅវត្តអង្គ ក្នុងខេត្តកំពង់ចាម បានបួនវស្សាទើបសឹកមកនៅជាមួយគាត់វិញ ។*

## ***សកម្មភាពមុនឆ្នាំ១៩៧០***

*ឆ្នាំ១៩៦៤ ឈ្មោះ សាត ប្រធានចម្ការកៅស៊ូ (រត់ចូលព្រៃហើយ) ចូលមកអប់រំខ្ញុំនៅក្នុងភូមិពីបដិវត្តន៍ដោយយកឯកសារតស៊ូវណ្ណៈមកអប់រំ ហើយក៏ចាត់តាំងខ្ញុំធ្វើជានីរសាររបស់គាត់ និងធ្វើការនៅក្នុងភូមិ ។ ឆ្នាំ១៩៦៧ សាត បានបញ្ចូលខ្ញុំជាយុវកក ។ ឆ្នាំ១៩៦៨ បានចូលព្រៃនៅព្រៃស្រក ខ្ញុំមានជំងឺគ្រុនចាញ់ក៏បានសុំសាត មកព្យាបាលជំងឺនៅក្នុងភូមិវិញ ។ ឆ្នាំ១៩៦៩ ពេលខ្ញុំស្នាក់នៅវត្តកងតាណឹង(កំពង់ចាម) ខ្មាំងចាប់ខ្ញុំដាក់នៅគុកបេអេស (BS) បានមួយខែក៏បញ្ជូនខ្ញុំមកដាក់នៅគុកព្រៃស ។ កន្លះខែក្រោយមកក៏ឃើញឈ្មោះ លីន អនុលេខាស្រុកបារាយណ៍ (បច្ចុប្បន្នអង្គការចាប់ហើយ) និង គូ ជាកូនសិស្សនៅកំពង់ចាម (បច្ចុប្បន្នក្តាប់មិនបាន) ដែលនៅភូមិស្រុកជិតគ្នាទៅជាប់គុកជាមួយខ្ញុំដែរ ។*

*ខ្ញុំ និង គូ តាមរយៈ លីន ក៏មានការជិតស្និទ្ធគ្នា ព្រោះនៅក្នុងគុកមិនមានស្គាល់គេ ក្រោយមកក៏អ្នកយាមគុកបញ្ចេញអ្នកទោសឲ្យធ្វើស្មៅជុំវិញគុក ។ ខ្ញុំ, លីន និង គូ ធ្វើការនៅជុំគ្នា ពេលនោះក៏មានឈ្មោះ ម៉ន ពាក់ដោយបីដាន់ បានហៅខ្ញុំទាំងបីទៅអង្គុយលេងនៅសំយាបផ្ទះគាត់ខាងកើតបរិវេណគុក ។ គាត់សួរនាំខ្ញុំទាំងបីថា "ស្រុកភូមិនៅឯណា? រឿងអីបានជាមកជាប់គុក?" ខ្ញុំទាំងបីប្រាប់ពីភូមិស្រុក និងរឿងដែលជាប់គុកមកពីការប្រឆាំងរាជការ ។ ម៉ន និយាយថា "អីចឹងហើយឯងចូលព្រៃធ្វើក្រហមចង់ដូចចិន យួន មិនជឿរាជការ? ខ្ញុំអាណិតណាស់ សុទ្ធតែក្មេងដូចប្អូនហ្នឹង បើប្អូនឯងទាំងអស់ចូលបម្រើជាតិវិញនោះពិតជាល្អខ្លាំងណាស់ ដូច្នេះប្អូនឯងទាំងអស់ចង់តស៊ូអី? បើកម្លាំងខាងរាជការច្រើនយ៉ាងនេះមាននៅគ្រប់ទីកន្លែងទាំងអស់" ។ គាត់និយាយប៉ុណ្ណឹងក៏ឲ្យខ្ញុំទៅធ្វើការវិញ ។ ប្រាំថ្ងៃក្រោយមក ម៉នហៅខ្ញុំទៅជួបគាត់នៅកន្លែងដដែលទៀត ត្រូវជាថ្ងៃអាទិត្យផង ការអប់រំ គាត់ដូចមុនដែរ តែបន្ថែមថា "របបគ្រប់គ្រងរបស់សង្គមរាស្ត្រនិយម មានការសប្បាយហ៊ឺហារតាមចិត្ត ឯខាងបដិវត្តន៍ដូចប្អូនៗឯងធ្វើនោះវាគ្មានទៅមុខរួចទេ" ។ ម៉ន ក៏ចាត់តាំងឲ្យខ្ញុំទាំងបីធ្វើជាគិញ និងប្រាប់ទៀតថា បើអាចពិនិត្យទៅឃើញអ្នកណាកសាងចាត់តាំងជាគិញបានត្រូវចាត់តាំងឲ្យជួយធ្វើបន្តទៀត ។ ម៉ន តែងតែជួយផ្តល់ការស៊ីចុកឲ្យខ្ញុំទាំងបី ។ ម៉ន ក៏សួរបញ្ជាក់ខ្ញុំទាំងបីថា "បើប្អូនទាំងបីនាក់ស្ម័គ្រចិត្តចង់បម្រើប្រទេសជាតិខាងយោធាក៏បានតាមក្រសួងណាក៏បានតាមសមត្ថភាពខ្លួន" ។*

*ចុងឆ្នាំ១៩៦៩ ឈ្មោះ ម៉ន បានហៅខ្ញុំទាំងបីទៅផ្ទះគាត់ពេលនោះខ្ញុំឃើញមានឈ្មោះ ភា ស័ក្តិ៣ គុកព្រៃសរ និងស្បោង វ៉ា ស័ក្តិ៤ គុកព្រៃសរ និងមានរៀបចំពិធីបញ្ចូលខ្ញុំទាំងបីជា សេ.អ៊ី.អា*

ដោយមានទង់មួយពណ៌ក្រហមលឿង មានសញ្ញាបេះដូងនៅចំកណ្តាលពណ៌លឿង ផ្កាយពាពីលើផង ។ ដំបូងស័ក្តិ៣ ភា ឡើងខទេ្ទសនាមបញ្ចូលខ្ញុំទាំងបីជាសមាជិក សេ.អុី.អា និង ស្បោង វ៉ា ឡើងទទួលស្គាល់ខ្ញុំទាំងបីនាក់ ។ ស្បោង វ៉ា ប្រគល់ភារកិច្ចឲ្យអនុវត្តមានៈ

១) កសាងកម្លាំង សេ.អុី.អា ។

២) បន្តពិនិត្យតាមដានខ្មែរក្រហម ។

៣) ឃោសនាពីរបបលោកសេរីនៅតាមកន្លែងរស់នៅ ។

## សកម្មភាពក្រោយរដ្ឋប្រហារឆ្នាំ១៩៧០

បន្ទាប់មកប្រកាសឲ្យខ្ញុំទាំងបីធ្វើការទាក់ទងជាមួយគាត់ ។ ខ្ញុំទាំងបីនាក់គោរពទង់សេ.អុី.អា ប្តេជ្ញាចិត្ត ។ ខែមីនា ឆ្នាំ១៩៧០ អ្នកទោស៤០០នាក់ត្រូវបានរួចទៅផ្ទះវិញ ។ ដោយឡែកខ្ញុំទាំងបី ស្បោង វ៉ា ហៅទៅណែនាំថា ទាំងបីនាក់ទៅផ្ទះវិញត្រូវធ្វើការទាក់ទងគ្នាឲ្យបានជាប់ ហើយត្រូវរាវរកខ្សែ សេ.អុី.អា នៅកន្លែងនោះតទៅទៀត ព្រោះកម្លាំង សេ.អុី.អា យើងបានចេញទៅបង្កប់នៅតាមជនបទច្រើនដែរហើយ ។

ខែកក្កដា ឆ្នាំ១៩៧០ ខ្ញុំទាំងបីក៏បានបបួលគ្នាចូលទៅបង្កប់ខ្លួននៅក្នុងបដិវត្តន៍ទៀត តាមរយៈឈ្មោះ ឈឿន បញ្ជូនខ្ញុំឲ្យមកនៅមន្ទីរក-២៥ នៅជាមួយឈ្មោះ ឌឿន ពាណិជ្ជកម្មរដ្ឋ (អង្គការចាប់ហើយ) ។ ឌឿន ណែនាំថា សភាពការណ៍ឥឡូវនេះ តាមមូលដ្ឋានយុវជន យុវនារី កំពុងតែចូលបដិវត្តន៍ច្រើនណាស់ ។ ឯកម្លាំងយើងវិញក៏បានចូលបង្កប់ក្នុងជួរបដិវត្តន៍រហូតដល់មាននាទីដឹកនាំក្នុងបដិវត្តន៍ខ្លះ ឯបដិវត្តន៍ក៏មិនដឹងថាមានកម្លាំងចូលបង្កប់ដែរ ។ ដូច្នេះកម្លាំងយើងដែលបានមកជួបគ្នានេះ ឥឡូវយើងត្រូវចុះទៅតាមមូលដ្ឋាន តាមភូមិវិញដើម្បីយើងធ្វើការកសាងកម្លាំងសេ.អុី.អា បន្តទៅទៀត ។ ណែនាំរួចហើយក៏ចាត់តាំងឲ្យ លីន ចុះទៅនៅភូមិកំណើតរបស់គាត់នៅភូមិវិហារធំវិញ គូ ទៅភូមិសូភាព ហើយខ្ញុំគាត់ចាត់តាំងឲ្យនៅក្រុមនីសាររបស់គាត់សម្រាប់នាំសំបុត្រ ។ ឯការទាក់ទង គាត់ឲ្យទាក់ទងគ្នាជាប់មកនឹងគាត់ផ្ទាល់ ចំពោះកម្លាំងដែលនៅជាមួយគាត់ឲ្យខ្ញុំទាក់ទងជាមួយនឹងឈ្មោះ បេង ។

ចុងឆ្នាំ១៩៧១ ឌឿន ចាត់តាំងឲ្យខ្ញុំក្តាប់ក្រុមនីសារជប់ពីរនាក់ ព្រមជាមួយនោះខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះ ដេង (បច្ចុប្បន្នស្លាប់) ។ ឌឿន ចុះមកសមរភូមិកំពង់ធំ ខ្ញុំនៅមន្ទីរស្រែវាល ស្ទឹងត្រង់តែមានភារៈទំនាក់ទំនងមកគាត់ផ្ទាល់ ។ ខែមីនា ឆ្នាំ១៩៧១ ឌឿន ហៅខ្ញុំទៅជួបនៅសមរភូមិកំពង់ធំ គាត់សួរខ្ញុំថា ការងារកសាងកម្លាំងកន្លងមកបានយ៉ាងណាហើយ? ខ្ញុំរាយការណ៍ថា សព្វថ្ងៃកសាងបានឈ្មោះ ដេង ម្នាក់ ហើយក្រៅពីហ្នឹងខ្ញុំកំពុងតែតាមដានបន្តទៀត ។

ឌឿន ណែនាំថា ឥឡូវខំជំរុញការកសាងបន្តទៀត ព្រោះលទ្ធភាពមានច្រើនណាស់ ។ ឯសមមិត្ត ហូ នៅមន្ទីរបិតផ្គូ និងលីន ក៏រៀងយកចិត្តទុកដាក់ទៅទាក់ទងឲ្យគេខំកសាងកម្លាំងឲ្យបាន ហើយឲ្យបញ្ជូនមកឲ្យខ្ញុំនៅខាងមុខ ។

ខ្ញុំក្តាប់បានបញ្ហានេះក៏មកប្រាប់ ហូ ឲ្យទៅជួប ឌឿន នៅសមរភូមិកំពង់ធំ ឯការទាក់ទងគ្នានេះមានរហូតដល់ឆ្នាំ១៩៧២ ។ ឆ្នាំ១៩៧២ ឌឿន ដកខ្ញុំពីក្រុមនីសារឲ្យមកនៅមូលដ្ឋានវិញជាផ្លូវការឲ្យខ្ញុំមកទាក់ទងជាមួយនឹងឈ្មោះ យី ស៊ុន ជាលេខាស្រុកស្ទឹងត្រង់ ។ ការទាក់ទង ឌឿន ណែនាំឲ្យខ្ញុំទាក់ទងមក លីន នឹងគាត់ផ្ទាល់តែម្តង ហើយក៏គាត់សរសេរសំបុត្រឲ្យទៅ យី ស៊ុន ចាត់តាំងខ្ញុំឲ្យមកនៅធ្វើប្រធានភូមិស្តង់ក្រញ៉ាង ។ ការដកខ្ញុំចុះមកមូលដ្ឋានភារកិច្ចសំខាន់កសាងកម្លាំង ។

ពេលខ្ញុំមក យី ស៊ុន បានចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានភូមិស្តង់ក្រញ៉ាង តាមសំបុត្រ ឌឿន ។ តែខ្ញុំមិនមានការទាក់ទងរឿងក្បត់ជាមួយគាត់ទេ គឺធ្វើការងារបដិវត្តន៍ជាមួយគ្នាធម្មតា ។

រយៈពេលដែលខ្ញុំនៅធ្វើជាប្រធានភូមិ ដោយមានផែនការពី ឌឿន ខ្ញុំកសាងកម្លាំងពីរនាក់មាន ឈ្មោះ ញឹម អតីតកម្មករចម្ការកៅស៊ូបារាំងចម្ការអណ្តូង បច្ចុប្បន្នប្រជាជននៅភូមិស្តង់ក្រញ៉ាង ស្រុកចម្ការលើ តំបន់៤២ និងអឿន អតីតធ្វើការនៅចម្ការកៅស៊ូបឹងកេតរបស់បារាំង បច្ចុប្បន្នជាប្រជាជននៅភូមិស្តង់ក្រញ៉ាង ។

ការអប់រំសំខាន់របស់ខ្ញុំលើកយករបបសេរីបំពាក់ឲ្យគេយល់ដោយរស់ជាឯកជន មិនចង់ធ្វើការពីរបីថ្ងៃក៏មិនជាអ្វីដែរ ។ បើធ្វើបដិវត្តន៍វិញសុទ្ធតែគេបង្ខំទាំងអស់ ។ ការអប់រំនេះអស់រយៈពេលជាច្រើនដង ទើបទាំងពីរនាក់យល់ព្រម ។ ខ្ញុំក៏ទៅរាយការណ៍ឲ្យបង ឌឿន នៅសមរភូមិកំពង់ធំដឹង បងឌឿន ណែនាំថា ឲ្យខ្ញុំតាមដានបន្តទៀតទៅកុំអាលឃើញគេសកម្មមួយភ្លែតៗ ចេះតែចាត់តាំងប្រយ័ត្នបែកការណ៍ ។ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំក៏ទៅជួប លីន នៅវិហារធំដើម្បី

សួរតើខាង លីន អនុវត្តយ៉ាងណាហើយ ការងារកសាងកម្លាំងមានពិសោធន៍យ៉ាងណា? និងយកការណែនាំពី ឡឿន ទៅណែនាំប្រាប់ខ្លះគឺជំរុញការកសាងកម្លាំងឲ្យបានខ្លាំង ព្រោះលទ្ធភាពនៅកន្លែងនោះអាចកសាងបានច្រើនទៀត ។ ជាមួយការងារបដិវត្តន៍នោះ ខ្ញុំក៏តែងតែហៅឈ្មោះ ញឹម និងអឿន មកពង្រឹងឲ្យជាប់ដែរ ។

ឆ្នាំ១៩៧៣ យី ស៊ុន ក៏ត្រូវផ្លាស់ចេញពីស្រុកស៊ីងត្រង់ទៅឯ ឡឿន នៅសមរភូមិកំពង់ធំ ។ គាត់ក៏នាំឈ្មោះ សាត មកឲ្យទទួលខុសត្រូវលេខាស្រុកនេះ គាត់បានរៀបចំឲ្យមកបង្កប់នៅតាមស្រុកនីមួយៗដើម្បីធ្វើសកម្មភាព ព្រោះ សាត បានទទួលតាំងពីនៅសមរភូមិកំពង់ធំមកម្ល៉េះ ដូច្នេះនៅក្នុងស្រុកនេះធ្វើសកម្មភាពទាក់ទងជាមួយនឹង សាត ចុះ ។

បន្ទាប់មក សាត ក៏ដកខ្ញុំឲ្យធ្វើប្រធានកសិកម្មស្រុកស៊ីងត្រង់ ដោយណែនាំថា ទៅកន្លែងនោះត្រូវយកចិត្តទុកដាក់កសាងកម្លាំងឯគាត់ក៏បោះមន្ទីរនៅអណ្តូងស្វាយ និងខំកសាងកម្លាំងដែរ ។

ពេលខ្ញុំធ្វើជាកសិកម្មនៅស្រែសង្កែ មានកម្លាំងសាមសិបនាក់ទាំងនារី ទាំងបុរស ។ ការងារខ្ញុំនៅពេលនោះសំខាន់យកចិត្តទុកដាក់កសាងតាមការណែនាំពី សាត ។ កម្លាំងដែលកសាងបានពីរនាក់មាន រុង អតីតប្រជាជន អ្នកដាំបន្លែ បច្ចុប្បន្នប្រធានក្រុមកសិកម្មស្រុកស៊ីងត្រង់ និង យាន ឆ្នាំ១៩៧០ ជាប្រធានភូមិព្រះអណ្តូង ដោយស៊ីសំណូក បញ្ចេញសេដ្ឋកិច្ចឲ្យខ្មាំង ក៏ត្រូវប្រជាជនទម្លាក់ ។ ក្រោយមក ក៏មកនៅកសិកម្មស្រុកស៊ីងត្រង់ (បច្ចុប្បន្ននៅដដែល) ។ ខ្ញុំតែងតែលើកយករបបខាងសេរី ការរស់នៅស្រួល កសិកម្មនៅប្រទេសសេរីមានការជឿនលឿនយកមកប្រៀបធៀបនឹងការធ្វើបដិវត្តន៍ មានចាត់តាំងជាសហករណ៍តូចៗ ធ្វើការរួមពិបាក សត្វពាហនៈការប្រមូលមកដាក់រួម បុណ្យទានក៏មិនឲ្យធ្វើ ។ ការអប់រំនេះមានរយៈពេលយូរទើបពីរនាក់នេះមានជំនឿលើខ្ញុំ ។ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៣ ទើបខ្ញុំប្រគល់ភារកិច្ចឲ្យធ្វើសកម្មភាពបំផ្លាញផលកសិកម្ម ។ ខែមីនា ឆ្នាំ១៩៧៣ នៅក្នុងចំណោមប្រជាជន ខ្ញុំកសាងបានកម្លាំងពីរនាក់ដែលនៅជិតមន្ទីរខ្ញុំ គឺ យស់ ឆ្នាំ១៩៧០ ចូលធ្វើយោធាភូមិភាគបូព៌ា ខូចរឿងសីលធម៌រត់មកនៅផ្ទះវិញ បច្ចុប្បន្នប្រធានមុខព្រួញភ្ជួរស្រែនៅសហករណ៍សង្កែ ស្រុកស៊ីងត្រង់ តំបន់៤២ និង ធន អតីតធ្វើស្រែ បច្ចុប្បន្នអនុប្រធានកងចល័តសហករណ៍សង្កែ ។ ការអប់រំនេះ សំខាន់ខ្ញុំលើកយករបបសេរីមកធ្វើការប្រៀបធៀបនឹងការធ្វើបដិវត្តន៍សព្វថ្ងៃ ។ ដូច យាន និង រុង គឺខ្ញុំមសារប្រហាក់ប្រហែលគ្នា ។ ខ្ញុំប្រគល់ភារកិច្ចឲ្យយកចិត្តទុកដាក់កសាងកម្លាំងយុទ្ធជននៅក្នុងមូលដ្ឋាន ដោយប្រើរូបភាពជិតស្និទ្ធជាមួយគ្នាដើម្បីដណ្តើមរដ្ឋអំណាចពីបដិវត្តន៍វិញ ។

ខែឧសភា ឆ្នាំ១៩៧៣ ខ្ញុំឡើងទៅរាយការណ៍ឲ្យ សាត នៅមន្ទីរអណ្តូងស្វាយអំពីកម្លាំងកសាងបានមានឈ្មោះដូចខាងលើ ។ សាត ជួយជាមតិមកខ្ញុំថា កម្លាំងនេះយើងអប់រំបន្តទៀត ចាំទៅថ្ងៃមុខចាំបញ្ចូលជា សេ.អ៊ី.អា ព្រោះឥឡូវនេះធ្វើថ្មីណាស់ តាមដានមួយរយៈសិន ។ បន្ទាប់មកទៀត សាត ថាគាត់កសាងបានតែបីនាក់ទេ មានឈ្មោះ ធឿន អតីតអ្នកបើកលុយកម្មករចម្ការកៅស៊ូបារាំងបឹងកេត បច្ចុប្បន្នជាសមាជិកគណៈកម្មាធិការមន្ទីរស្រុកស៊ីងត្រង់ តំបន់៤២ , សឿ អតីតក្តាប់មិនបានទេ បច្ចុប្បន្នធ្វើឆ្មោះចាប់ត្រីនៅខ្ពបតាងួន ស្រុកស៊ីងត្រង់ និង ផាត អតីតក្តាប់មិនបាន បច្ចុប្បន្នលេខាសហករណ៍ពាមកោះស្នា ស្រុកស៊ីងត្រង់ ។

ពេលលើកទំនប់នៅស្រែសង្កែជាមួយប្រជាជន ខ្ញុំបានណែនាំ យស់ និង ធន ឲ្យនាំកម្លាំងទៅធ្វើការនៅចម្ការដីខាងលើរហូតដល់ពេលធ្លាក់ភ្លៀង បានខ្ញុំឲ្យនាំកម្លាំងមកលើកទំនប់វិញ ជាលទ្ធផលចម្ការក៏មិនបានធ្វើ ទំនប់ក៏មិនបានធ្វើ ។ ខ្ញុំបំផុសកម្លាំងយុវជនយុវនារីឲ្យទាមទាររៀបគ្រួសារតាំងពីអាយុ១៨ឆ្នាំដើម្បីកុំឲ្យចូលធ្វើកងទ័ពបដិវត្តន៍ ។ ធឿន, សឿ និង ផាត ខ្ញុំក៏មកទាក់ទងតាមការផ្តាំផ្ញើពី សាត តែការទាក់ទងសំខាន់សួរថាតើធ្វើសកម្មភាពយ៉ាងម៉េចកន្លងមក និងជួយរំឭកកសាងកម្លាំង ។ ចំពោះ លីន គិតតែធ្វើសកម្មភាពខ្ញុំជាមួយ យស់ ក៏ស្នើ សាត ឲ្យ លីន ទៅជួបនៅស្រុកកំពង់សៀម ហើយ សាតក៏សម្រេចឲ្យទៅ ។ ក្រោយមក ខ្ញុំនាំ លីន មកជួប សាត ដើម្បីឲ្យ សាត ជួយណែនាំបន្ថែមទៀត ។ ខែសីហា ឆ្នាំ១៩៧៣ សាត ខ្ញុំ និង អឿន នៅស្ពង់ក្រញ៉ាង បានរៀបបញ្ចូល យស់, យាន, រុង និង ធន ជាសេ.អ៊ី.អា នៅនឹងមន្ទីររបស់ខ្ញុំ ។ ឆ្នាំ១៩៧៤ សាត ផ្លាស់ចេញពីស្រុកស៊ីងត្រង់ទៅនៅចម្ការកៅស៊ូចម្ការអណ្តូងវិញ ហើយឈ្មោះ ឈឿន ក្រោយរំដោះនៅពាណិជ្ជកម្មភ្នំពេញ (អន្តការចាប់ហើយ) មកទទួលនាទីលេខាស្រុកស៊ីងត្រង់ លេខាតំបន់៣៣វិញ ។

សាត បានប្រាប់ឲ្យខ្ញុំទាក់ទងនឹង ឈឿន ព្រោះកម្លាំងនោះក៏បង ឌឿន ចាត់តាំងឲ្យមកដូចគាត់ដែរ ឥឡូវ ទៀង ឯងធ្វើការជាមួយ ឈឿន ទៅ មិនបាច់ទៅទាក់ទងគាត់ទៀតទេ ។ បងឈឿន មានមតិថា យើងរស់នៅពីសង្គម យើងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ ឯនៅសង្គមបដិវត្តន៍វិញ មិត្តមើលចុះ គាបគៀ្បតណាស់ គ្មានសិទ្ធិសេរីភាពអីទេ ។ ដូច្នេះបំណងដែលយើងធ្វើនេះដើម្បីវាយបដិវត្តន៍ទៅថ្ងៃមុខ ជាចាំបាច់ត្រូវកសាងកម្លាំងឲ្យបានច្រើន ។ ខែកុម្ភៈ ឆ្នាំ១៩៧៤ បងឈឿនដកខ្ញុំពីកសិកម្មឲ្យមកទទួលជាលេខាសង្កាត់ខ្ពបតាងួន ។ ខែមីនា ឆ្នាំ១៩៧៤ ឈឿន បានទៅពិភាក្សាជាមួយខ្ញុំអំពីគម្រោងផែនការ គឺបង្កើតកងទ័ពចោរព្រៃមួយកងឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍នៅសមរភូមិក្រោយ ដើម្បីបន្ធូរកម្លាំងបដិវត្តន៍វាយខ្មាំងនៅសមរភូមិមុខ ។ តាមការពិភាក្សាសម្រេចថារៀបចំធ្វើដោយប្រមូលកម្លាំងយុទ្ធជននៅតាមមូលដ្ឋានមកបំពាក់អប់រំជាកម្លាំង ។

រហូតដល់ខែមេសា ឆ្នាំ១៩៧៤ ប្រមូលកម្លាំងបានយុទ្ធជននៅតាមមូលដ្ឋានបានមួយកងអនុសេនាតូច តែការប្រមូលតាមមូលដ្ឋានមិនជាផ្លូវការទេ មកដល់កន្លែង ឈឿន ក៏អប់រំឲ្យទៅជាកម្លាំងប្រឆាំងនឹងបដិវត្តន៍ តែសំខាន់ ឈឿន និងខ្ញុំអប់រំបីនាក់ឲ្យក្ដាប់មានឈ្មោះ រិន (ស្លាប់) , ហៃ (ស្លាប់) និង ធឿន (ស្លាប់) ដែលជាអ្នកនៅក្នុងមន្ទីររបស់ ឈឿន ។ បីនាក់នេះ ដឹកនាំកងទ័ពឲ្យទៅវាយខ្មាំងនៅសមរភូមិមុខសិន ដើម្បីឲ្យបានកាន់កាំភ្លើងសិន ។ ពេលនោះក៏ចាត់តាំងឲ្យបីនាក់នោះនាំកម្លាំងទៅវាយខ្មាំងនៅសមរភូមិកំពង់ធំ ឈឿន ក៏ចាត់តាំងឲ្យ បេង យកកាំភ្លើងបើកឲ្យកាន់គ្រប់ៗគ្នា ហើយ រិន, ហៃ និង ធឿន ជាអ្នកបំផុសឲ្យរត់ពីមុខមកខាងក្រោយវិញ ។

ដល់ក្រោយមកក៏មានកម្លាំងនោះរត់មកសមរភូមិក្រោយជាបន្តបន្ទាប់ ខ្ញុំបានប្រមូលមកអប់រំបានម្ភៃប្រាំនាក់ ហើយឲ្យ រិន, ហៃ និង ធឿន មកក្ដាប់រួចក៏បញ្ជូនឲ្យទៅនៅក្នុងព្រៃឈើទើ ក្នុងស្រុកស្ទឹងត្រង់ ហើយជាអ្នកផ្ដល់ស្បៀង ។ ក្រោយមក ឈឿន និង ខ្ញុំក៏ចូលទៅចាត់តាំងឲ្យ ហៃ, ធឿន និង រិន នាំកម្លាំងមកធ្វើសកម្មភាពបាញ់នៅមន្ទីរតំបន់៤២ចាស់ នៅម្ដុំបែកអន្លង់ ។ ពេលនោះក៏ទៅបាញ់បណ្ដាលឲ្យស្លាប់អ្នកយាមពីរនាក់ នឹងចាត់តាំងឲ្យស្ទាក់បាញ់កង់ ម៉ូតូនៅតាមផ្លូវកែងបិតធ្នូ ដែលមានកម្មាភិបាលបដិវត្តន៍ធ្វើដំណើរតាមផ្លូវ ហើយក៏បានបាញ់ស្លាប់នីរសារម្នាក់ ។ ក្រោយមកទៀត ខ្ញុំបានទៅជាមួយគ្នា ហៃ, រិន និង ធឿន នាំកម្លាំងទៅវាយឈ្លបនៅមន្ទីរសង្កាត់អូម្លូរ គឺបានមកឈ្លបបាញ់ពីរដង ដោយសកម្មភាពញឹកញាប់ពេកក៏ត្រូវយោធាតំបន់៤២ ឡើងទៅវាតត្បាត ។ សកម្មភាពនេះត្រូវស្ងាត់មួយរយៈរហូតដល់ខែមិថុនា ឆ្នាំ១៩៧៤ ខ្ញុំនាំកម្លាំងទៅបាញ់មន្ទីរសង្កាត់អូរម្លូងទៀត គឺព័ទ្ធចាប់បានប្រធានសង្កាត់ម្នាក់ឈ្មោះ មិត យកទៅកម្ទេច ។ ឯកម្លាំងធ្វើសកម្មភាពនេះសព្វថ្ងៃនៅសល់តែឈ្មោះ ផល បច្ចុប្បន្នចូលមកសារភាពប្រធានភូមិនៅឃុំឈើទើ ស្រុកស្ទឹងត្រង់ តំបន់៤២ និង ឆាន បច្ចុប្បន្នចូលមកសារភាពប្រធានភូមិនៅឃុំឈើទើ ស្រុកស្ទឹងត្រង់ តំបន់៤២ ។

អំពីការងាររបស់ខ្ញុំនៅក្នុងសង្កាត់ខ្ពបតាងួន ខ្ញុំកសាងបានឈ្មោះ រ៉េន អតីតសិស្សថ្នាក់ទី៧ បច្ចុប្បន្នប្រធានពាណិជ្ជកម្មសហករណ៍ខ្ពបតាងួន ស្ទឹងត្រង់ និង នុន អតីតធ្វើចម្ការ បច្ចុប្បន្នប្រធានសហករណ៍ខ្ពបតាងួន ស្រុកស្ទឹងត្រង់ តំបន់៤២ ដោយខ្ញុំតែងតែយកចិត្តទុកដាក់ ស្និទ្ធស្នាលខាងមនោសញ្ចេតនា និងអប់រំតាមដានអស់រយៈប្រាំមួយខែទើបអប់រំបាន ។ រហូតដល់ចុងឆ្នាំ១៩៧៤ ខ្ញុំបានរាយការណ៍ឲ្យ ឈឿន ហើយគាត់ក៏ណែនាំមកវិញឲ្យរៀបចំបញ្ចូលជា សេ.អ៊ី.អា ដែលមាន ឈឿន, ខ្ញុំ និងអឿន ជាអ្នកបញ្ចូលពីរនាក់នេះ ហើយក៏ប្រគល់ភារកិច្ចឲ្យដូចអ្នកមុនៗ ។

ឈឿន ណែនាំឲ្យខ្ញុំខំពិនិត្យមើលសមាសភាពអ្នករកស៊ីលក់ដូរ និងពាក់ព័ន្ធផ្នែកនយោបាយថែមទៀត ដើម្បីអប់រំជាកម្លាំង ។ ក្រោយមកកម្លាំងដែលនៅក្នុងព្រៃក៏មានឈ្មោះ ឆេង រត់ចេញមករាយការណ៍ឲ្យប្រធានភូមិ ប្រធានភូមិក៏រាយការណ៍ឲ្យទៅយោធាតំបន់៤២ យោធាតំបន់ទៅព័ទ្ធបាញ់រត់បែកគ្នារហូតសព្វថ្ងៃ ។ ខ្ញុំឃើញបញ្ហាដូច្នេះក៏ទៅរាយការណ៍ឲ្យ ឈឿន ដឹង ។ បញ្ហានេះទុកមួយកន្លែងសិនចុះ ឥឡូវយើងធ្វើសកម្មភាព ខាងសហករណ៍ម្ដង ។ ជាទិសអនុវត្តឲ្យធ្វើសហករណ៍តែត្រឹមដប់ប្រាំគ្រួសារសិនទេ ។ ជាសកម្មភាពរបស់យើង ត្រូវរៀបចំចាត់តាំងជាសហករណ៍មួយភូមិតែម្ដង ប្រមូលទាំងមនុស្ស ទាំងសត្វ ដាក់រួមឲ្យអស់នៅតាមមាត់ទន្លេ យើងកុំចាត់តាំងជាសហករណ៍ គឺចាត់តាំងជាក្រុមប្រវាស់ដៃបានហើយ ដើម្បីប្រឆាំងមាគ៌ារបស់បក្ស ។ ក្រោយពីមានការណែនាំមក ខ្ញុំក៏យកបញ្ហាទៅអនុវត្តក្នុងសង្កាត់ទាំងមូល ដោយគ្មាន

ការចាត់តាំងដឹកនាំត្រឹមត្រូវ ធ្វើឲ្យច្របូកច្របល់ក្នុងសហករណ៍ ។ ខែសីហា ឆ្នាំ១៩៧៤ ឈឿន ណែនាំថា ឥឡូវបើការចាត់តាំងសហករណ៍មានការច្របូកច្របល់ហើយ យើងត្រូវរំសាយឲ្យទៅជាឯកជនវិញទៅ ។

ក្រោយពីគាត់ណែនាំមក ខ្ញុំក៏រំសាយសហករណ៍ភូមិបឹងទាំងមូលឲ្យទៅជាឯកជនវិញ តែក្រៅពីនោះខ្ញុំមិនទាន់ហ៊ានរំសាយទេ ។ ខ្ញុំរាយការណ៍ឲ្យ ឈឿន ថារំសាយបានមួយភូមិហើយ ឈឿន បានណែនាំថា យើងធ្វើនេះក្នុងគោលបំណងប្រឆាំងមាគ៌ាបក្ស កុំឲ្យសហករណ៍របស់បដិវត្តន៍ទៅមុខរួច ។ បន្ទាប់ពីនោះ ខ្ញុំណែនាំ នុន ឲ្យយកស្រូវធ្ងន់ទៅស្ងួននៅដីទួលឲ្យខូចអស់ម្ភៃហិកតា និង វ៉ែន ខ្ញុំណែនាំឲ្យស្តុកទុកសម្ភារដូចជា ក្រណាត់ទុកឲ្យខូចអស់ដប់កីអំបិលដប់បាវ ដោយបណ្តោយឲ្យត្រូវទឹកភ្លៀងខូច ហើយសម្ភារដែលមានគឺណែនាំមិនឲ្យយកទៅចែកឲ្យប្រជាជនទេ ។

ដើមឆ្នាំ១៩៧៥ ឈឿន ផ្លាស់មកមន្ទីរ១៣០ របស់ភាគឧត្តរចាស់ ហើយបញ្ជូលឈ្មោះ អឿន ជាលេខាតំបន់៤២វិញ មកក្តាប់លេខាស្រុកស្ទឹងត្រង់វិញ ។ ពេលនោះ ឈឿន បានប្រាប់ខ្ញុំថា អឿន មិនដឹងយ៉ាងណាទេ គាត់ក្តាប់មិនបានដែរ ។ ឯការទាក់ទងទៀង ឯងត្រូវធ្វើការទាក់ទងជាមួយឈ្មោះ ឌុល ជា សមាជិកស្រុកស្ទឹងត្រង់ខាងលើ បច្ចុប្បន្នលេខាសង្កាត់ ហើយកម្លាំងចាស់ក៏ត្រូវពង្រឹងថែមទៀត ទោះអ្នកក្រៅចូលមកក្តាប់នៅស្រុកនេះក៏ដោយ ។

ខែមីនា ឆ្នាំ១៩៧៥ អឿន ដកខ្ញុំមកឲ្យទទួលលេខាសង្កាត់អារក្សត្នោតវិញ ក្នុងស្រុកស្ទឹងត្រង់ ដដែល ។ ក្នុងឱកាសនេះ ខ្ញុំបានទៅពិភាក្សាការងាររកសាងកម្លាំងតើយ៉ាងម៉េចនៅមន្ទីររបស់ ឌុល តើឲ្យខ្ញុំកសាងកម្លាំងទៀត ឬមិនឲ្យកសាង ព្រោះខ្ញុំត្រូវផ្លាស់ចេញពីខ្ពបតាងួនហើយមកនៅសង្កាត់អារក្សត្នោតវិញហើយ ។ ឌុល មានមតិថា កម្លាំងកសាងទៀតចុះ តែត្រូវប្រុងប្រយ័ត្នឲ្យបានខ្ពស់ប្រយ័ត្នបែកការណ៍សម្ងាត់យើង ។ បន្ទាប់ពីនេះ ឌុល ខទ្មេសនាមខ្មែរដែលកម្លាំងគាត់ទើបកសាងបានដើម្បីឲ្យខ្ញុំធ្វើការទាក់ទងមានរួមមាន លី អតីតប្រជាជន បច្ចុប្បន្នប្រធានកងធំសហករណ៍ស្រែវាល ស្រុកស្ទឹងត្រង់, ស្រ៊ាង អតីតប្រជាជន បច្ចុប្បន្នគណៈកម្មាធិការសង្កាត់ស្រែវាល និង ស៊ីម អតីតប្រជាជន បច្ចុប្បន្នជាអនុកម្មាធិការសង្កាត់ស្រែវាល ។

## សកម្មភាពក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥

ក្រោយរំដោះភ្លាម ឌុល និយាយប្រាប់ខ្ញុំថា កន្លងមកកសាងកម្លាំង គាត់បានទទួលផែនការពីឈ្មោះ តុល ហើយគាត់ទទួលខុសត្រូវលើយើងទៀត ។ ពេលនោះ ក៏នាំខ្ញុំ និង ស៊ីម ទៅជួប តុល នៅមន្ទីរថ្នល់បំបែក ស្រុកចម្ការលើ ។ ឌុល ខទ្មេសនាមខ្ញុំ និង ស៊ីម ឲ្យ តុល ស្គាល់ ។ តុល ណែនាំពីសភាពការណ៍ថា បដិវត្តន៍បានរំដោះទូទាំងប្រទេសហើយ តែកម្លាំងរបស់យើងឥឡូវនេះបានចូលក្តាប់មន្ទីរក្រសួងបានចង់អស់ហើយដែរ ដូច្នេះយើងឥឡូវត្រូវសម្រុកកសាងកម្លាំងឲ្យបានរហ័សដើម្បីតស៊ូប្រឆាំងបដិវត្តន៍ កុំឲ្យជិះជាន់ប្រជាជនតទៅទៀត ព្រោះបដិវត្តន៍បំបាត់ប្រពៃណីអស់ហើយ គ្មានសិទ្ធិសេរីភាពទេ ។ ខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំ និង ឌុល បានពិភាក្សាគ្នារៀបចំផែនការពង្រីកកម្លាំងដែលមានហើយឲ្យកសាងកម្លាំងថ្មីទៀតចំពោះកិច្ចការផ្សេងៗ ខ្ញុំ និង ឌុល ត្រូវឡើងទៅជួប តុល ផ្ទាល់ ។ ក្រោយពីពិនិត្យពិភាក្សាមក ខ្ញុំបានហៅ ធាន, រុង, យាន, វ៉ែន, អឿន, ធឿន និង ជាត មកប្រជុំនៅមន្ទីរកសិកម្មចាស់ខ្ញុំមុន ។ ចំពោះខ្លឹមសារខ្ញុំបានណែនាំទៅតាមអ្វីដែល តុល ប្រាប់ខ្ញុំកាលពីលើកមុន ។

ខែកក្កដា ឆ្នាំ១៩៧៥ ឌុល, ខ្ញុំ, ស្រ៊ាង, លី និងស៊ីម បានទៅជួប តុល នៅកន្លែងដដែលទៀត ។ ខ្លឹមសារទៅជួបនេះ ខ្ញុំទាំងអស់គ្នាទៅរាយការណ៍ឲ្យ តុល ដឹងថាកម្លាំងរៀបចំកសាងហើយស្រេច ។ តុល មានមតិអប់រំប្រហាក់ប្រហែលមុនទៀត ណែនាំរក្សាការសម្ងាត់ឲ្យបានខ្ពស់មែនទែន ។ មួយរយៈក្រោយមក ខ្ញុំផ្លាស់មកនៅប្រធានពាណិជ្ជកម្មតំបន់៤២វិញ គឺទាក់ទង តុល ផ្ទាល់ ។ ឯកម្លាំងនៅមូលដ្ឋាន ខ្ញុំប្រគល់ឲ្យទៅ ឌុល គ្រប់គ្រងទាំងអស់ ។ ខ្ញុំនៅក្នុងពាណិជ្ជកម្ម តុល រៀបចំការងារឲ្យខ្ញុំធ្វើដោយណែនាំខ្ញុំយកចិត្តទុកដាក់កសាងកម្លាំងនៅក្នុងពាណិជ្ជកម្ម និងប្រជាជនដែលនៅជាប់ពាណិជ្ជកម្មផង ។ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មរបស់ខ្ញុំ ដែលមាន ៖ ជុន អតីតប្រធានសហករណ៍សង្គមចាស់ បច្ចុប្បន្នសមាជិកពាណិជ្ជកម្មតំបន់៤២ និង យ៉េត អតីតក្តាប់មិនបាន បច្ចុប្បន្ននាទីអនុពាណិជ្ជកម្មតំបន់៤២ ។ ខ្ញុំស្នើ តុល ថាតើសមាសភាពពីរនាក់នេះយ៉ាងម៉េចដែរ? តុល ថាពីរនាក់នេះគាត់បានអប់រំខ្លះហើយ ឥឡូវមិត្តត្រូវអប់រំបន្តទៀត ។

ដល់ដើមឆ្នាំ១៩៧៦ ទើបខ្ញុំកសាងពីរនាក់នេះបាន និង យ៉ុន

អតីតសិស្សថ្នាក់ទី៥ បច្ចុប្បន្នធ្វើបញ្ជីពាណិជ្ជកម្ម តំបន់៤២ ។ រហូតដល់ខែ មេសា ឆ្នាំ១៩៧៦ ក៏ តុល សម្រេចឲ្យចាត់តាំងបីនាក់នេះជា សេ.អ៊ី.អា ដែលមានឈ្មោះ តុល, ខ្ញុំនិង ព្រាប ជាអ្នកបញ្ជូល ។ ខែកក្កដា ឆ្នាំ១៩៧៦ តុល ដកខ្ញុំឲ្យមកទទួលជាលេខាស្រុកចម្ការលើវិញ ឯកម្លាំងនៅពាណិជ្ជកម្ម ខ្ញុំប្រគល់ឲ្យ យ៉េត គ្រប់គ្រង ។ តុល ណែនាំឲ្យខ្ញុំធ្វើការទាក់ទងជាមួយ ជាវ លេខាស្រុកតាំងគោក (អង្គការចាប់ហើយ) និងបញ្ជាក់ទៀតថា ត្រូវកសាងកម្លាំងនៅមូលដ្ឋានចម្ការលើ ព្រោះស្រុកនោះប្រហែលមិនទាន់មានកម្លាំងយើងចូលដល់ទេ ។ ខ្ញុំចុះទៅស្រុកចម្ការលើតាមការណែនាំរបស់ តុល ។ ខ្ញុំយកចិត្តទុកដាក់ចុះទៅសង្កាត់ តាប្រុក និងចម្ការអណ្ដូង ព្រោះកន្លែងនេះច្រើនជាសាច់ឈាមរបស់ តុល និងភាគច្រើនកម្មករចម្ការកៅស៊ូបារាំងទាំងពីរសង្កាត់ ។ ខ្ញុំកសាងកម្លាំងបានមួយចំនួនមានៈ ហ៊ាង អតីតគ្រូបង្រៀន បច្ចុប្បន្នប្រធានសហករណ៍ តាប្រុក ស្រុកចម្ការលើ, វន អតីតកម្មករចម្ការកៅស៊ូចម្ការអណ្ដូង បច្ចុប្បន្នប្រធានសហករណ៍ភូមិដូនបុស, ម៉ន អតីតគ្រូបង្រៀនបច្ចុប្បន្នប្រធានសហករណ៍ភូមិចម្ការអណ្ដូង និង សៀម អតីតកម្មករចម្ការកៅស៊ូបារាំង បច្ចុប្បន្នប្រធានក្រុមសហករណ៍ប្រើសមាស ។

ដោយម្នាក់ៗសេរី ធ្លាប់មានប្រាក់ខែ មុខមាត់ បុណ្យសក្តិ ខ្ញុំយកបញ្ហានេះទៅបំផុស បើពីសង្គមចាស់ មានការរស់នៅស៊ីចាយហ៊ឺហារ បានតាមចិត្ត ដូចសព្វថ្ងៃ បើបានធ្វើប្រធានក្រុម ប្រធានសហករណ៍ប៉ុណ្ណឹង បើពីសង្គមចាស់វិញមានប្រាក់ខែចាយយ៉ាងសប្បាយចិត្ត ។ ឥឡូវនេះធ្វើបដិវត្តន៍រកតែខោអាវស្លៀកមិនចង់បានផង ។ ការអប់រំជាញឹកញាប់ទាំងអស់សុទ្ធតែយល់ស្របតាមការអប់រំខ្ញុំទាំងអស់ ។ តែមិនទាន់ប្រគល់ភារកិច្ចឲ្យទេ ។ ក្រោយមកខ្ញុំរាយការណ៍ឲ្យ តុល ដឹងពីបញ្ហានេះ ។ តុល ជំរុញឲ្យខ្ញុំសម្រុកកសាងឲ្យមែនទែន នៅខាងតាប្រុក ។

ខែកញ្ញា ឆ្នាំ១៩៧៦ ខ្ញុំណែនាំឲ្យ ហ៊ាង ធ្វើសកម្មភាពបំផ្លាញសន្ទូង ដោយបំផុសឲ្យប្រជាជនស្ទូងបត់ដើម ទុកសំណាបឲ្យចាស់ខូចចោល ភ្ជួរកុំឲ្យសព្វដី និងលាយស្រូវពូជដាក់ស្រូវធ្ងន់លាយស្រូវស្រាល ។ ខែធ្នូ ឆ្នាំ១៩៧៦ តុល មកប្រជុំនៅកន្លែងម៉ោង៧យប់ ហើយអ្នកចូលរួមប្រជុំមាន ព្រាប, ជាវ និងឌុល ។ ខ្លឹមសារ តុល លើកថា ផែនការរបស់យើងពីលើរហូតក្រោម មានផែនការធ្វើរដ្ឋប្រហាររំលំបក្សនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ដើម្បីរំលំបក្សកុម្មុយនីស្តចេញ ហើយកម្លាំង សេ.អ៊ី.អា យើងកាន់អំណាចវិញ ។ រៀបចំចាត់តាំងគណៈកម្មាធិការទទួលធ្វើរដ្ឋប្រហារមានៈ

ក) តុល ទទួលរួមដឹកនាំខាងនយោបាយ ។

ខ) ឌុល ទទួលខាងចាប់ចង ពេលរដ្ឋប្រហារអ្នកមិនព្រមចុះចូល ។

គ) ខ្ញុំទទួលខាងឃោសនា អប់រំប្រជាជនកុំឲ្យមានការរំជើបរំជួលក្នុងពេលធ្វើរដ្ឋប្រហារ ។

ឃ) ព្រាប និង ជាវ ទទួលភារកិច្ចនីរសារទាក់ទង ស្រេងពីកំពង់ចាមមក តុល តាមការកំណត់ផ្ទះនៅក្រុងកំពង់ចាមទៅជនបទ តែការធ្វើនេះមិនឲ្យផ្ទុះអាវុធទេ គឺកម្លាំងរបស់យើងអប់រំកន្ទងមកត្រូវបំផុសឲ្យចាប់កម្មាភិបាលបដិវត្តន៍ណាដែលមិនព្រមដើរតាមយើងចាប់កម្ទេចចោលតែម្ដង ។ បើអ្នកសារភាពយើងជាកម្លាំងអព្យាក្រឹត្យទេ យើងទុកតទៅទៀត ។

ដើមខែមករា ឆ្នាំ១៩៧៧ តាមដែលខ្ញុំបានស្នើសុំ តុល សម្រេចបញ្ចូល វន, ម៉ន, ហ៊ាង និង សៀម ជា សេ.អ៊ី.អា ដោយមាន តុល, ព្រាប និង ខ្ញុំជាអ្នកបញ្ចូល ។ ចាប់ពីឆ្នាំ១៩៧៧ អង្គការបេះតែមានវិធានការជាបន្តបន្ទាប់ខាងយោធា១៧៤ ភូមិភាគកណ្ដាល (មុនយោធាកងពល១១៧) ។ ខ្ញុំទៅជួប តុល ម្ដងទៀត ហើយ តុល ណែនាំថា ផែនការយើងដែលត្រូវធ្វើរដ្ឋប្រហារត្រូវផ្អាកសិន ព្រោះឥឡូវបដិវត្តន៍កំពុងមានវិធានការជាបន្តបន្ទាប់ ។ យើងចាំមើលសភាពការណ៍នៅខាងមុខទៀតសិន តើយ៉ាងណា? ឯសកម្មភាពរបស់យើងបេះតែធ្វើបណ្ដើរទៅខាងការបំផ្លិចបំផ្លាញ ។ តុល ណែនាំខ្ញុំឲ្យយកចិត្តទុកដាក់ទាក់ទងជាមួយ មន អតីតសិស្សថ្នាក់ទី៣ បច្ចុប្បន្នលេខាឃុំស្វាយទាប ចុះទៅអប់រំកសាងកម្លាំងនោះផង ព្រោះឥឡូវខ្ញុំចាត់តាំងឲ្យ មន ទៅអប់រំនិងចាត់តាំងកម្លាំងឲ្យមានជាក្រុម ជាកងឲ្យហើយស្រេច ដល់ព្រឹត្តិការណ៍កើតឡើងយើងត្រូវបំពាក់កម្លាំងឲ្យធ្វើសកម្មភាពតែម្ដង ។

ខ្ញុំបានទាក់ទង មន នៅសង្កាត់ស្វាយទាប ឲ្យហៅសមាសភាពទាហានប្រុសទាំងអស់មកប្រជុំ សូមបញ្ជាក់ទាហានទាំងអស់នេះគ្មាននៅលាយឡំជាមួយប្រជាជនទេ ដាក់តែទាហានសុទ្ធសាធតែម្ដង (ហើយភូមិនោះនៅក្នុងព្រៃដាច់ស្រយាលពីគេ) ខ្លឹមសារអប់រំ គឺ

◆ ឲ្យខំសម្របខ្លួននៅក្នុងសហករណ៍កុំឲ្យអង្គការដឹងថា ក្នុងភូមិមានតែទាហានសុទ្ធសាធ ។

◆ យើងពីមុនសុទ្ធតែធ្លាប់មានបណ្តាសក្តិ ប្រាក់ខែចាយ ប៉ុន្តែឥឡូវនេះមកនៅក្នុងនេះដឹងស្រាប់ហើយ ដូច្នេះយើងត្រូវពុះពារទ្រាំទ្រការលំបាកបន្តិច ព្រោះយើងទ្រាំការលំបាកតែមួយរយៈសិនបន្តិចទៀត យើងបាននៅស្រួលដូចមុនវិញហើយ ។ ការអប់រំមានច្រើនតទៀត តែពេលនោះក៏ឲ្យត្រឡប់ទៅកន្លែងវិញសិន គឺទុកតែឆេង អតីតស័ក្តិ២យន្តហោះ បច្ចុប្បន្ននៅភូមិកាយគរ និង ផួន ស្រេង អតីតស័ក្តិ១ បច្ចុប្បន្ននៅភូមិកាយគរ ។ ពីរនាក់នេះ ខ្ញុំ និង មន ចាត់តាំង ឲ្យឈ្មោះ ឆេង ប្រធានកងធំ និង ផួន ស្រេង អនុកងធំ ឲ្យក្តាប់សមាសភាពទាហាននោះទាំងអស់ ហើយណែនាំឲ្យរៀបចំកម្លាំងទាំងអស់ ជាក្រុម ជាកង ឲ្យហើយស្រេច តែកុំជំពាក់ជំពិននឹងប្រពន្ធកូនឲ្យសោះ ដើម្បីពេលមានព្រឹត្តិការណ៍កើតឡើង យើងត្រូវទៅជួយធ្វើអន្តរាគមន៍តែម្តង ។ ព្រមជាមួយគ្នានេះ ខ្ញុំនិង មន ណែនាំឲ្យ ផួន ស្រេង និង ឆេង ចាត់តាំងឈ្មោះ ខ្លាក្រហឹម ហៅ មាន ពាក់សក្តិ៣ ឲ្យបង្កើតចោរព្រៃដប់ពីរនាក់ដើរលួចគោ ។ កន្លងមកគឺបានលួចគោនៅភូមិបុសខ្នោរបានប្រាំក្បាល និងភូមិជីយោ បួនក្បាលដែលគោលែងទាំងហ្វូង១ ។

ខែកុម្ភៈ និងខែមីនា អង្គការបានចាប់ខ្លួន គុល និងមនុស្សជាច្រើនទៀត ។ ពេលនោះខ្ញុំមានការព្រួយបារម្ភច្រើនបាត់ម្ចាស់ការមួយរយៈ ។ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧ គណៈភូមិភាគបានចាត់តាំងខ្ញុំឲ្យធ្វើជាអនុលេខាតំបន់៤២ ទទួលលេខាស្រុកចម្ការលើផង ។ ខ្ញុំគិតថា ប្រហែលបក្សមិនដឹងរឿងខ្ញុំទេ បានជាហានចាត់តាំងយ៉ាងនេះ ។

ពេលនោះខ្ញុំក៏ចាប់បន្តសកម្មភាពបន្តទៀត គឺទៅណែនាំឲ្យ ហ៊ាង, មន, វន និង សៀម ធ្វើសកម្មភាពបំផ្លាញផលស្រូវវស្សា ឲ្យយកសំណាបស្រូវធ្ងន់ស្ទូងដីទួល ស្រូវស្រាលស្ទូងដីទំនាប ទំលាយទឹកក្នុងស្រែចោលឲ្យស្កកស្រូវ និងទឹកក្នុងប្រឡាយខ្ញុំណែនាំឲ្យបើកចោលមិនបាច់បិទទេ ។ ជាលទ្ធផល ក្រោយពីមានការណែនាំមក ហ៊ាង បានយកស្រូវធ្ងន់ទៅស្ទូងដីទួលឲ្យខូចអស់៥០ហិកតា ។ ឯម៉ន, វន និង សៀម បំផ្លាញស្រូវវស្សាអស់១៥ហិចតា ដោយយកស្រូវស្រាលទៅស្ទូងដីជម្រៅ ។

ក្រោយមកទៀតខ្ញុំបានហៅម៉ន, សៀម និង ហ៊ាង មកប្រជុំនៅផ្ទះ វន ពេលម៉ោង៨ព្រឹក ដោយមានខ្លឹមសារដូចតទៅ ៖

◆ បំផ្លាញផលស្រូវ១ហិចតា៣តោន ដោយបំផុសប្រជាជនឲ្យស្ទូងបត់ដើម ទុកសំណាបឲ្យចាស់ដើម និងលួចបង្ហូរទឹកក្នុងស្រែចោល ។

◆ បំផុសប្រជាជនកុំឲ្យធ្វើការខំពេក ប្រយ័ត្នឈឺ គ្មានថ្នាំមើលទេ ឲ្យធ្វើការល្មមៗបានហើយ ។

◆ ដល់រដូវប្រាំងខាងមុខ ផែនការអង្គការឲ្យជីកប្រឡាយពីស្ទឹងជីនិតមកស្រុកតាំងគោក ផែនការរបស់យើងដើម្បីបន្ទុចបន្ទាក់ផែនការជីកប្រឡាយមាន ៖

១) ពេលទៅជីក បំផុសកម្លាំងឲ្យធ្វើពុតជាឈឺច្រើន ។

២) កុំឲ្យកម្លាំងប្រជាជនទៅជីកដោយយកលេសថា ជាប់ធ្វើត្រង់នេះត្រង់នោះ ។

៣) បំផុសយុវជន យុវនារី ឲ្យទាមទាររៀបគ្រួសារឲ្យស្នើមកលេងផ្ទះដើម្បីកុំឲ្យផែនការជីកប្រឡាយរបស់អង្គការបានសម្រេច ។

ខែសីហា ឆ្នាំ១៩៧៧ ខ្ញុំទៅជួប ឌុល នៅមន្ទីរសន្តាត់ស្រែវាលការជួបខ្ញុំពិភាក្សាពីផែនការអង្គការចាប់កម្លាំងក្បត់ជាបន្តបន្ទាប់ក្នុងតំបន់៤២ មិនដឹងគិតយ៉ាងណាឲ្យផុតពីកណ្តាប់ដៃបដិវត្តន៍ទេ ។ តាមការពិភាក្សាមក បានសម្រេចថានឹងពង្រីកកម្លាំងដែលនៅសល់ឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍តទៅទៀត តែការចេញចូលទាក់ទងគ្នាមិនឲ្យញឹកញាប់ពេក ប្រយ័ត្នខូចបែកការណ៍ ។

ខ្ញុំត្រឡប់មកវិញក៏ខិតខំយកចិត្តទុកដាក់ពង្រឹងកម្លាំងឲ្យធ្វើសកម្មភាពតទៅទៀត ។ រហូតដល់ថ្ងៃទី១ ខែ តុលា ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ខ្លួនតែម្តង ។

នៅបួនទំព័រចុងក្រោយនៃចម្លើយសារភាពគឺជាសេចក្តីសង្ខេបចម្លើយរបស់ នួន រឿន ហៅ ទៀង ដែលបានសង្ខេបឡើងវិញ ដោយឈ្មោះ ប៉ុន នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨ ។ ប៉ុន បានធ្វើសេចក្តីសង្កេត និងដាក់ជូនទៅអង្គការលើថា ការរៀបរាប់ពីសកម្មភាពក្បត់ដែល រឿន ឆ្លើយគឺខ្វីតែមានលក្ខណៈជាខ្សែសង្វាក់ច្បាស់គួរសមដែរតែពុំទាន់លម្អិតនៅឡើយ ។ ហេតុដូចនេះ ប៉ុន ស្នើទៅអង្គការលើពិនិត្យតាមការជាក់ស្តែង ដោយអនុគ្រោះ ។

**ឆាង សារៈមុនិន្ទ**

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីរ៉ សាវីណា

**(តពីលេខមុន)**

| លរ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ៤១៩ | ភិន អុល | ប្រុស | ? | មេក្រុម |
| ៤២០ | ម៉ក់ មាន | ប្រុស | ? | កម្មកររោងភ្លើង |
| ៤២១ | ទឹម សៃ | ប្រុស | ? | ទាហានអាត់សាដង់ |
| ៤២២ | យិន ស៊ុយ | ប្រុស | ? | កងពល ១៦០ |
| ៤២៣ | ប៉ែន អិនអ៊ូ | ប្រុស | ២ | កង ០៨ |
| ៤២៤ | សុក សាន | ប្រុស | ១ | កងដឹកជញ្ជូន |
| ៤២៥ | ទិត កាន | ប្រុស | ? | ស-២១យ |
| ៤២៦ | ដឹម ងីហេង | ប្រុស | ៣២ | កម្មករចាស់ |
| ៤២៧ | សៅ ឃឹន | ប្រុស | ៤ | សារ៉ុធ ពេទ្យកងរយ |
| ៤២៨ | ទេព សួបុផា | ស្រី | ? | ធនាគារជាតិមកពីបរទេស (តាឡី) អគ្គលេខាធនាគារ ១.៩.៧៦ |
| ៤២៩ | មែន ឌឹម | ប្រុស | ? | ១៧០ |
| ៤៣០ | ហម ហង់ | ប្រុស | ១ | កង៥១២ |
| ៤៣១ | ស៊ូ សាមឿន | ប្រុស | ? | កម្មកររោងភ្លើង |
| ៤៣២ | ហ្វូត សម្បត្តិ | ប្រុស | ២ | ទូត ១០.៩.៧៦ |
| ៤៣៣ | ស កិ | ប្រុស | ? | យុទ្ធជន ១៣ ស-២១យ |
| ៤៣៤ | បេង ហុកជី | ប្រុស | ១ | ទាហានកាំភ្លើងធំស័ក្តិពីរ |
| ៤៣៥ | ស៊ាង កាត | ប្រុស | ១ | ប្រ,ជ |

**រូបថតទទួលបានមកពី គូ សុខចន្ទី ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២**

| លរ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ៤៣៦ | សន វ៉ាត | ប្រុស | | ថ្ងៃចាប់ខ្លួន ១៨.៦.៧៨ |
| ៤៣៧ | ព្រំ ស អេល | ប្រុស | | ថ្ងៃចាប់ខ្លួន ១៧.៥.៧៨ |
| ៤៣៨ | ឡូញ វ៉ាន់ | ប្រុស | | ថ្ងៃចាប់ខ្លួន ១៨.៦.៧៨ |
| ៤៣៩ | ខៀវ ទ | ស្រី | | ថ្ងៃចាប់ខ្លួន ៩.៥.៧៨ |
| ៤៤០ | ឈន ខន | ប្រុស | | ថ្ងៃចាប់ខ្លួន ១៨.៦.៧៨ |
| ៤៤១ | ឌឿក សាបាន | ស្រី | | ថ្ងៃចាប់ខ្លួន ១៧.៥.៧៨ |

| | | | | |
|---|---|---|---|---|
| ៤៤២ | ឈង វ | ប្រុស | | ថ្ងៃចាប់ខ្លួន ១៩.៥.៧៨ |
| ៤៤៣ | ឃឹម ? សអុន | ប្រុស | | ថ្ងៃចាប់ខ្លួន ១៩.៥.៧៨ |
| ៤៤៤ | #៥៨៤ | ប្រុស | | ថ្ងៃចាប់ខ្លួន ១៧.៥.៧៨ |
| ៤៤៥ | យ៉ាន #៥៦០ | ស្រី | | ថ្ងៃចាប់ខ្លួន ១៧.៥.៧៨ |
| ៤៤៦ | ឌឿន #៦៦២ | ស្រី | | ថ្ងៃចាប់ខ្លួន ១៩.៥.៧៨ |
| ៤៤៧ | #៦៥០ | ប្រុស | | ថ្ងៃចាប់ខ្លួន ១៩.៥.៧៨ |
| ៤៤៨ | វឿន #៥៧១ | ប្រុស | | ថ្ងៃចាប់ខ្លួន ១៧.៥.៧៨ |
| ៤៤៩ | #៦៥៦ | ប្រុស | | ថ្ងៃចាប់ខ្លួន ១៩.៥.៧៨ |

**រូបថតទទួលបានមកពី នួន ម៉ាលី**

| | | | | |
|---|---|---|---|---|
| ៤៥០ | ព្រុំ អ៊ាត | ប្រុស | ៣៧៨ | ២១.៦.៧៨ |
| ៤៥១ | វៀល សំសាមឿន | ប្រុស | ៧១០ | ១៨.៤.៧៨ |
| ៤៥២ | ឡឹក សឿត | ប្រុស | ៦២៩ | ២៦.៦.៧៨ |
| ៤៥៣ | ម៉ៅ សារី | ប្រុស | ៣៧៣ | ២១.៦.៧៨ |
| ៤៥៤ | សួង ស៊ាម | ប្រុស | ១១ | ១.៤.៧៨ |
| ៤៥៥ | ស៊ូ សារ៉ន់ | ប្រុស | ៥៩០ | ២៣.៦.៧៨ |
| ៤៥៦ | អោក ឌៀន | ប្រុស | ៣៦២ | ២១.៦.៧៨ |
| ៤៥៧ | នៅ ប៊ុម | ប្រុស | ៣៦៣ | ២១.៦.៧៨ |
| ៤៥៨ | កេត ឆន (?) | ប្រុស | ៧៧៦ | ? ? ៧៨ |
| ៤៥៩ | គង់ សារី | ប្រុស | ៥៤៤ | ២៣. ៦.៧៨ |
| ៤៦០ | ម៉ៅ សុផល | ប្រុស | ៥៤៥ | ២៣.៦.៧៨ |
| ៤៦១ | មាស ឡាន | ប្រុស | ២០៩ | ១០.៦.៧៨ |
| ៤៦២ | ចាន់ ស្រ៊ាន | ប្រុស | ៧៩ | ១១.៧.៧៨ |
| ៤៦៣ | យ៉ា ឡៃ | ប្រុស | ៧៨ | ១១.៧.៧៨ |
| ៤៦៤ | សាយ ងឿន | ប្រុស | ៧៧ | ១១.៧.៧៨ |
| ៤៦៥ | សួន ស៊ុនហេង | ប្រុស | ៨៣ | ១១.៧.៧៨ |
| ៤៦៦ | ឆាន ផា | ប្រុស | ៨៤ | ១១.៧.៧៨ |
| ៤៦៧ | ហែម មឿន | ប្រុស | ៨៥ | ១១.៧.៧៨ |
| ៤៦៨ | ភាន យន | ប្រុស | ៥០៣ | ២១.៦.៧៨ |
| ៤៦៩ | ភ៊ាត រី | ប្រុស | ៨៦ | ១១.៧.៧៨ |
| ៤៧០ | ប៊ូ រី | ប្រុស | ៤៩៤ | ២១.៦.៧៨ |
| ៤៧១ | អៀង អោក | ប្រុស | ៤៩៣ | ២១.៦.៧៨ |
| ៤៧២ | ឈឹន ឆន | ប្រុស | ៤៩៥ | ២១.៨.៧៨ |

| | | | | |
|---|---|---|---|---|
| ៤៧៣ | រត្ន សំហន | ប្រុស | ៤៩៦ | ២១.៦.៧៨ |
| ៤៧៤ | ថោង ថន | ប្រុស | ៤៩៧ | ២១.៦.៧៨ |
| ៤៧៥ | បែរ ចាន់ | ប្រុស | ៤៩៨ | ២១.៦.៧៨ |
| ៤៧៦ | អ៊ឹម ទិត | ប្រុស | ៤៩៩ | ២១.៦.៧៨ |
| ៤៧៧ | ប៊ុន ឃន | ប្រុស | ៥០០ | ២១.៦.៧៨ |
| ៤៧៨ | ឡឹក ភាង | ប្រុស | ៥០២ | ២១.៦.៧៨ |
| ៤៧៩ | អំ សំអឿន | ប្រុស | ៥០១ | ២១.៦.៧៨ |
| ៤៨០ | ស៊ួង ហុក | ប្រុស | ៥៩៧ | ៣០.៣.៧៨ |
| ៤៨១ | កែន យឿន "កន" | ស្រី | ៥៩៨ | ៣០.៣.៧៨ |
| ៤៨២ | ឃឹម ខឿន | ប្រុស | ៥៨២ | ៣០.៣.៧៨ |
| ៤៨៣ | នុត ហើយ | ប្រុស | ៥៨១ | ៣០.៣.៧៨ |
| ៤៨៤ | អ៊ុង ប៉េងហុង | ប្រុស | ៥៨០ | ៣០.៣.៧៨ |
| ៤៨៥ | គឿង អឿង | ប្រុស | ៥៧៩ | ៣០.៣.៧៨ |
| ៤៨៦ | នៅ ណាត | ប្រុស | ៥៧៨ | ៣០.៣.៧៨ |
| ៤៨៧ | គ្រក់ ឃិន | ប្រុស | ៥៧៧ | ៣០.៣.៧៨ |
| ៤៨៨ | រស់ ស្រ៊ាន | ស្រី | ៥២៦ | ២១.៦.៧៨ |
| ៤៨៩ | ភ៊ន់ ណូ | ប្រុស | ៥១៥ | ២១.៦.៧៨ |
| ៤៩០ | មិញ មៀត | ប្រុស | ៥១៤ | ២១.៦.៧៨ |
| ៤៩១ | សៀម ឡោម | ប្រុស | ៥១៣ | ២១.៦.៧៨ |
| ៤៩២ | ហឹង ភាន | ប្រុស | ៥១២ | ២១.៦.៧៨ |
| ៤៩៣ | នៅ យាត | ប្រុស | ៥១១ | ២១.៦.៧៨ |
| ៤៩៤ | កែ ថុង | ប្រុស | ៥១០ | ២១.៦.៧៨ |
| ៤៩៥ | ឡិប សាលុក | ប្រុស | ៥០៩ | ២១.៦.៧៨ |
| ៤៩៦ | អំ ដុន | ប្រុស | ៥០៨ | ២១.៦.៧៨ |
| ៤៩៧ | ប្រាក់ វុត | ប្រុស | ៥០៧ | ២១.៦.៧៨ |
| ៤៩៨ | ដាន អុល | ប្រុស | ៥០៦ | ២១.៦.៧៨ |
| ៤៩៩ | ដាន សួស | ប្រុស | ៥០៥ | ២១.៦.៧៨ |
| ៥០០ | ហ៊ាន ហ៊ីង | ប្រុស | ៥០៤ | ២១.៦.៧៨ |
| ៥០១ | គីម សឿនសុន | ប្រុស | ៤៦ | ១.៤.៧៨ |
| ៥០២ | ស្រី ឆន | ប្រុស | ៧៦២ | ២០.៤.៧៨ |
| ៥០៣ | ទុង គាំង | ប្រុស | ៥៧៦ | ២៣.៦.៧៨ |
| ៥០៤ | យូ រាប | ប្រុស | ៧១១ | ២៩.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៥០៥ | អ៊ុំ អាត | ប្រុស | ៧១៣ | ២៩.៦.៧៨ (ឬ អ៊ុំ សាត) |
| ៥០៦ | ជុំ សេង | ប្រុស | ៧១២ | ២៩.៦.៧៨ |
| ៥០៧ | ឆន ខុម | ប្រុស | ៧១៤ | ២៩.៦.៧៨ |
| ៥០៨ | សូ ណាន | ប្រុស | ៨១៣ | ២២.៤.៧៨ |
| ៥០៩ | អ៊ុក ពៅ | ប្រុស | ៨០៩ | ២២.៤.៧៨ |
| ៥១០ | សេក សាម៉ន | ប្រុស | ៨០៨ | ២២.៤.៧៨ |
| ៥១១ | អ៊ុក ពៅ | ប្រុស | ៨០៩ | ២២.៤.៧៨ |
| ៥១២ | កូវ វណ្ណា | ប្រុស | ៨១០ | ២២.៤.៧៨ |
| ៥១៣ | លីម ហេង | ប្រុស | ៥៨៧ | ៣០.៣.៧៨ |
| ៥១៤ | អ៊ុក សាអេម | ប្រុស | ៨០៤ | ២២.៤.៧៨ |
| ៥១៥ | ទេព យាប | ប្រុស | ៥៣៩ | ២៣.៦.៧៨ |
| ៥១៦ | ឡុង សាខន | ប្រុស | ៥៤៣ | ២៣.៦.៧៨ |
| ៥១៧ | យស់ ម៉ុន | ប្រុស | ៣៩ | ១.៤.៧៨ (វរៈ) |
| ៥១៨ | គុល ទូច | ប្រុស | ៤០ | ១.៤.៧៨ |
| ៥១៩ | យ៉ង ញោបរឹម | ប្រុស | ១៤៣ | ១៤.៣.៧៨ |
| ៥២០ | ចេក ជួនដាំ | ប្រុស | ១៤២ | ១៤.៣.៧៨ |
| ៥២១ | លឿង យ៉ាំងជី | ប្រុស | ២៣ | ៤.៣.៧៨ |
| ៥២២ | ព្រីងអ៊ាន-សារ៉ុម | ប្រុស | ១២០ | ៧.៦.៧៨ |
| ៥២៣ | សជុន ឈាងស៊ី | ប្រុស | ៦៧ | ៨.៣.៧៨ ឬ (១៨.៣.៧៨) |
| ៥២៤ | ចាន់ អាត | ប្រុស | ៧០ | ៨.៣.៧៨ |
| ៥២៥ | ហេង សោយ-មក់ | ប្រុស | ៦៩ | ៨.៣.៧៨ |
| ៥២៦ | អ៊ុម សំអូន | ប្រុស | ៦៦ | ៨.៣.៧៨ (ដប់ខ្យល់នៅលើថ្ងាស់) |
| ៥២៧ | ឈឹម ឆន | ប្រុស | ៤១៩ | ២៣.៣.៧៨ |
| ៥២៨ | គង់ ប៊ុនលិន-អុន | ប្រុស | ៤២២ | ២៣.៣.៧៨ |
| ៥២៩ | សូ ចន | ប្រុស | ៤២១ | ២៣.៣.៧៨ |
| ៥៣០ | មាន មឹល-ខឿ | ប្រុស | ២៦៥ | ១២.៦.៧៨ |
| ៥៣១ | ងិន វុធធី | ប្រុស | ៦២៥ | ២៦.៦.៧៨ |
| ៥៣២ | ខៀវ សុក | ប្រុស | ៣៥៩ | ២១.៦.៧៨ |
| ៥៣៣ | ឡើយ ម៉ត់ធឿន | ប្រុស | ១៣៥ | ១៤.៣.៧៨ |
| ៥៣៤ | ពេជ ជ | ប្រុស | ៧០៩ | ១៩.៤.៧៨ |
| ៥៣៥ | ហឹង គេន | ប្រុស | ២៥៩ | ១២.៦.៧៨ |
| ៥៣៦ | លឹម ហេង | ប្រុស | ៥៨៧ | ៣០.៣.៧៨ **(នៅមានត)** |

# ប្រវត្តិសង្ខេប អៀង សារី

អៀង សារី មានឈ្មោះដើម គីម ត្រាង (គីម ស្រ៊ី) និងមានឈ្មោះបដិវត្តន៍ វ៉ាន់ ។ កាលពីទសវត្សរ៍៦០ អៀង សារី ត្រូវបានកម្មាភិបាលខ្មែរក្រហមហៅថា "បងពេញ" ។ ឈ្មោះ "ពេញ" នេះត្រូវបានប្រើនៅមន្ទីរ១០០ឬមន្ទីរ "ដើមផ្កៀក" ដែលផ្លាស់មកពីមន្ទីរដើមចំបក់ក្នុងខេត្តមណ្ឌលគិរី ។ ក្នុងអំឡុងឆ្នាំ១៩៦៦ ពេលធ្វើដំណើរពីមន្ទីរ១០០មកកាន់ខេត្តរតនគិរី អៀង សារី ដែលហៅក្រៅថា "បងពេញ" ត្រូវបានប្តូរឈ្មោះថា "បងវ៉ាន់" វិញ ។

អៀង សារី កើតនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ឃុំលឿងវ៉ា ខេត្តត្រាវិញ វៀតណាមខាងត្បូង ។ ឯកសារខ្លះបញ្ជាក់ថា អៀង សារី កើតនៅភូមិក្បាឡាក់ ឃុំសាងហ្វា ស្រុកចូវថាន់ ខេត្តត្រាវិញ ប្រទេសវៀតណាម ។ លិខិតឆ្លងដែនសញ្ជាតិខ្មែររបស់ អៀង សារី បញ្ជាក់ថា គាត់កើតនៅខេត្តព្រៃវែងក្នុងប្រទេសកម្ពុជា តែ អៀង សារី ក៏មានលិខិតឆ្លងដែនសញ្ជាតិចិនដែរ ដែលនៅក្នុងលិខិតឆ្លងដែននោះ អៀង សារី មានឈ្មោះថា ស៊ូ ហាវ កើតនៅទីក្រុងប៉េកាំងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៣០ ។

ឪពុកបង្កើតរបស់ អៀង សារី ឈ្មោះ គីម រៀម ជនជាតិខ្មែររស់នៅទឹកដីកម្ពុជាក្រោម ។ គីម រៀម មានជំងឺហើយត្រូវពិការភ្នែកមួយចំហៀងបន្ទាប់ពី អៀង សារី ចាប់កំណើតឡើង ។ ម្តាយរបស់ អៀង សារី ឈ្មោះ ង៉ៀន ធីឡឹយ ឬ ច្រិន ធីឡឹយ ដែលជាកូនកាត់ចិន ។ អៀង សារី មានបងប្អូនបីនាក់ (ប្រុសពីរ ស្រីមួយ) ក្នុងនោះ អៀង សារី ជាកូនពៅ ។ បងប្រុសទីមួយឈ្មោះ គីម ចូវ ក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មានឋានៈជាប្រធានផ្សារអូរឫស្សី ។ នៅក្នុងអំឡុងឆ្នាំ១៩៨០ គីម ចូវ និងក្រុមគ្រួសារបានភៀសខ្លួនទៅរស់នៅរដ្ឋផ្លរីដា សហរដ្ឋអាមេរិក ។ បងទីពីរគឺបងស្រីឈ្មោះ គីម ធីកូវ មានប្តីឈ្មោះ ថាច់ សុង (ស្លាប់ទាំងពីរនាក់ ប្តីប្រពន្ធ) ។ គ្រួសារនេះ មានកូនប្រាំពីរនាក់ ។ ក្នុងចំណោមនោះ មានអ្នកខ្លះរស់នៅស្រុកកំណើតក្នុងប្រទេសវៀតណាម ហើយអ្នកខ្លះទៀតរស់នៅក្នុងប្រទេសកម្ពុជា ។

អៀង សារី បានមករស់នៅក្នុងទឹកដីកម្ពុជាតាំងពីតូចៗមកម្ល៉េះដោយទទួលការចិញ្ចឹមបីបាច់ពីសំណាក់ឪពុកចិញ្ចឹមឈ្មោះ ហ៊ូ ហុងស៊ីន នៅខេត្តស្វាយរៀង ។ ក្រោយមក អៀង សារី ចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ នៅទីក្រុងភ្នំពេញ ។ នៅក្នុងឆ្នាំ១៩៥០ អៀងសារី បានទទួលអាហារូបករណ៍ទៅសិក្សានៅទីក្រុងប៉ារីស ប្រទេសបារាំង ហើយក៏បានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំង ។ មុនទៅរៀននៅ




លិខិតឆ្លងដែនចេញដោយក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិនកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៩ ជូន អៀង សារី ដោយប្រើឈ្មោះ ស៊ូ ហាវ កើតនៅទីក្រុងប៉េកាំង ថ្ងៃទី១ ខែមករា ឆ្នាំ១៩៣០ ។ លិខិតឆ្លងដែននេះចេញជូន អៀង សារី ដើម្បីឲ្យគាត់អាចធ្វើដំណើរក្រៅពីប្រទេសចិន ។

ប្រទេសបារាំង អៀង សារី បានទៅលេងស្រុកកំណើតតែម្តងប៉ុណ្ណោះ ។ នៅឆ្នាំ១៩៥១ អៀង សារី បានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំង ។ អៀង សារី បានរៀបការជាមួយ ខៀវ ធីរិទ្ធ នៅប្រទេសបារាំងអំឡុងពេលដែលអ្នកទាំងពីរទៅសិក្សានៅទីនោះ ។ ខៀវ ធីរិទ្ធ ដែលត្រូវជាប្អូនស្រីរបស់ ខៀវ ប៉ុណ្ណារី ប្រពន្ធរបស់ ប៉ុល ពត បានដូរឈ្មោះទៅជា អៀង ធីរិទ្ធ វិញ ក្រោយពីរៀបការជាមួយ អៀង សារី ដោយយកត្រកូលខាងប្តី ។ អៀង សារី និង អៀង ធីរិទ្ធមានកូនបួននាក់ ប្រុសមួយស្រីបី ។ កូនប្រុសរបស់ អៀង សារី ឈ្មោះ អៀង វុធ គឺជាអភិបាលរងខេត្តប៉ៃលិនបច្ចុប្បន្ន ។

ឆ្នាំ១៩៥៧ អៀង សារី បានវិលត្រឡប់មកប្រទេសកម្ពុជាពីប្រទេសបារាំងវិញ ហើយបានធ្វើជាគ្រូបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ ស្របពេលជាមួយគ្នានោះដែរ អៀង សារី ក៏បានចូលជាសមាជិកបក្សប្រជាជនបដិវត្តន៍កម្ពុជា ។ នៅឆ្នាំ១៩៦០ អៀង សារី បង្រៀននៅសាលាកម្ពុជបុត្រក្រុងភ្នំពេញ ផ្នែកប្រវត្តិសាស្ត្រ និងភូមិសាស្ត្រដែលមាន ហ៊ូ យន់ ជានាយកសាលា ។ នៅឆ្នាំ១៩៦៣ អៀង សារី បានលះបង់ចោលការងារនៅទីក្រុងភ្នំពេញ ហើយរត់ចូលព្រៃក្នុងខេត្តកំពង់ចាមដើម្បីចូលរួមចលនាកុម្មុយនីស្ត ដែលក្រោយមកត្រូវបានស្គាល់ថា "ខ្មែរក្រហម" ។ ប៉ុល ពត ត្រូវបានជឿថារត់ចូលព្រៃជាមួយនឹង អៀង សារី នៅពេលនោះដែរ ។ នៅឆ្នាំ១៩៦៥ អៀង សារី បានជួបជាមួយនឹង សឿង, ភឿន, ម៉ុល (ប្រពន្ធរបស់ កែវ មាស) នៅក្នុងទឹកដីខេត្តរតនគិរីដើម្បីរៀបចំមន្ទីរជាបផ្នែករបស់បក្ស ។ នៅខេត្តរតនគិរី អៀង សារី បានបង្កើតកងទ័ពនៅភូមិភាគឦសាន ហើយបានក្លាយជាមេបញ្ជាការកងទ័ពមុនឆ្នាំ១៩៧២ ។ នៅឆ្នាំ១៩៧០ អៀង សារី បានចេញទៅទីក្រុងហាណូយដើម្បីទៅទាក់ទងវៀតណាម និងសម្តេច សីហនុ នៅទីក្រុងប៉េកាំង ប្រទេសចិន ។ នៅឆ្នាំ១៩៧០នោះដែរ អៀង សារី បានបង្រៀនពីគោលជំហរនយោបាយរបស់រណសិរ្សដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅខេត្តរតនគិរី ។ កម្មាភិបាលខ្មែរក្រហមមួយរូបបាននិយាយថា "ពេលទៅដល់ខេត្តរតនគិរីក្នុងឆ្នាំ១៩៧០ ខ្ញុំបានជួប អៀង សារី ហៅ វ៉ាន់ ។ គាត់បានមកទទួលក្រុមយើងខ្ញុំ ហើយបង្រៀនយើងខ្ញុំអំពីគោលជំហរនយោបាយរបស់រណសិរ្សប៉ុន្តែគោលបំណងពិតប្រាកដគឺប្រឆាំងវៀតណាម" ។

រវាងឆ្នាំ១៩៧១-៧២ អៀង សារី និង អៀង ធីរិទ្ធ បាន



អៀង សារី (ស្តាំ) កំពុងចាប់ដៃជាមួយ ម៉ៅ សេទុង (ឆ្វេង) ក្រោមក្រសែភ្នែករបស់ ប៉ុល ពត (កណ្តាល) នៅទីក្រុងប៉េកាំង ក្នុងឆ្នាំ១៩៧០ ។ ម៉ៅ សេទុង ទទួលមរណភាពប្រាំមួយឆ្នាំក្រោយមក នៅខែកញ្ញា ឆ្នាំ១៩៧៦ ។



អៀង សារី ក្នុងអំឡុងពេលនាំគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចទ័ពជើងទឹកក្នុងខេត្តជាប់មាត់សមុទ្រ ដែលអាចជាខេត្តកំពតឬ ខេត្តព្រះសីហនុ ។ ក្នុងរូបថតនេះ អៀង សារី  កំពុងឈរនៅលើទូកមួយដែលបំពាក់ដោយកាំភ្លើងធំដើម្បីការពារផ្ទៃទឹកកម្ពុជា ។

បង្កើតរដ្ឋអំណាចនយោបាយមួយទៅលើខ្មែរនៅវៀតណាម ។ អៀង ធីរិទ្ធ ទទួលបន្ទុកខាងវិទ្យុផ្សាយសំឡេងនៅទីក្រុងហាណូយ ។ ឆ្នាំ១៩៧៣ អៀង សារី ធ្វើការនៅក្នុងមន្ទីរសម្ងាត់របស់បក្សនៅជាយក្រុងហាណូយ ។ នៅខែមិថុនា ឆ្នាំ១៩៧៤ អៀង សារី និង ខៀវ សំផន បានវិលត្រឡប់ចូលស្រុកវិញបន្ទាប់ពីបានដឹកនាំគណៈប្រតិភូទៅធ្វើទស្សនកិច្ចនៅក្រៅប្រទេស ។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧០ គណៈប្រតិភូរបស់រណសិរ្សបង្រួបបង្រួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានមកដល់ទីក្រុងហាណូយ ដើម្បីធ្វើទស្សនកិច្ចជាមិត្តភាព ។ នៅក្នុងសេចក្តីថ្លែងការណ៍រួមគ្នាមួយរវាងកម្ពុជានិងវៀតណាមដែលចេញផ្សាយនៅក្នុងទីក្រុងហាណូយ គណបក្សទាំងពីរបញ្ជាក់សាជាថ្មីអំពី «ការតាំងចិត្តក្នុងការអនុវត្តគោលការណ៍ទាំងប្រាំចំណុចដើម្បីសន្តិភាពរួមពោលគឺ ៈ គោរពអធិបតេយ្យភាពនិងបូរណភាពដែនដីរបស់គ្នាទៅវិញទៅមក ការមិនឈ្លានពានគ្នា ការគោរពរបបនយោបាយគ្នាទៅវិញទៅមក និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគ្នាផង សមភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក និងសន្តិសហវិជ្ជមាន» ។

ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ អៀង សារី បានចូលរួមជាមួយរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងជាបេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិខ្មែរ ។

ក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះក្នុងឆ្នាំ១៩៧៥ អៀង សារី បានហៅកម្មាភិបាលក្មេងៗឲ្យត្រឡប់មកពីប្រទេសវៀតណាមចំនួន៥០០នាក់ ។ អ្នកទាំង៥០០នោះ ត្រូវបានសម្លាប់ចោល ។ ក្នុងឆ្នាំ១៩៧៥នោះដែរ អៀង សារី បានសុំគណៈទាក់ទងវៀតណាមចុះទៅសួរសុខទុក្ខម្តាយរបស់ខ្លួននៅស្រុកកំណើត ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ក្នុងអង្គ «ប្រជុំអចិន្ត្រៃយ៍» ដែលមានរបៀបវារៈបីគឺ «ការបែកការងារ និងកិច្ចដំណើរការ ការរៀបចំនៅរួម និងការចាត់ចែងការងារដាក់ស្តែងមួយចំនួន» អៀង សារី ត្រូវបានតែងតាំងជាអ្នកទទួល «ការងារបរទេសទាំងបក្សទាំងរដ្ឋ» ។ ថ្ងៃទី២ ខែវិច្ឆិកា (ប្តុង្គ) ឆ្នាំ១៩៧៥ នៅវេលាម៉ោង៧យប់ អៀង សារី បានចូលរួមក្នុងអង្គ «ប្រជុំអចិន្ត្រៃយ៍» ដែលខ្លឹមសារនៃអង្គប្រជុំមាន «សេចក្តីរាយការណ៍ពីទស្សនកិច្ចនៅថៃ សភាពការណ៍នៅព្រំប្រទល់ និងសមុទ្រ បញ្ហាអំបិលនិងបញ្ហាផ្សេងៗ» ។ នៅឆ្នាំ១៩៧៦ រដ្ឋាភិបាលវៀតណាមធ្លាប់ បានយកទឹកដោះគោ តែ ស្ករ មកឲ្យម្តាយ អៀង សារី ឈ្មោះ ង៉ៀន ធីឡឹយ ប្រហែល៦-៧ដង ក៏ប៉ុន្តែចាប់ពីឆ្នាំ១៩៧៧មក រដ្ឋាភិបាលវៀតណាមពុំដែលមកសួរសុខទុក្ខនិងឧបត្ថម្ភទៀត

ឡើយ ។ នៅយប់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ អៀង សារី បានចូលរួម «អង្គប្រជុំគណៈអចិន្ត្រៃយ៍» ស្តីអំពី «បញ្ហាការពារប្រទេស» ដោយមាននិយាយអំពីជំនួយរបស់ចិនទាក់ទងខាងអាកាស និងខាងជើងទឹក និងអំពីមតិណែនាំមួយចំនួនរបស់អង្គការ ។ យប់ថ្ងៃដដែលនេះដែរ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» ស្តីអំពី «បញ្ហាសេដ្ឋកិច្ចដោយភ្ជាប់នឹងមតិណែនាំរបស់អង្គការផង ។ នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» ស្តីអំពី «បញ្ហាជំនួយស៊ុយអែត និងយូហ្គោស្លាវី» ក្នុងពេលនោះ អៀង សារី បានធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំ ។

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំការងារឃោសនាការ» ដែលមានរបៀបវារៈដូចជា «ការផ្សព្វផ្សាយអំពីការបោះឆ្នោតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ និងភារកិច្ចតាមដានដំណើរ» ។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» ដែលក្នុងអង្គប្រជុំនោះមានលើករបៀបវារៈអំពី «បញ្ហាព្រំប្រទល់ខាងកើត» និងមតិណែនាំរបស់អង្គការ ។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» ស្តីអំពី «ពាណិជ្ជកម្ម» ។ បន្ទាប់ពីសេចក្តីរាយការណ៍ត្រួសៗរបស់ អៀង សារី និង កុយ ធួន ស្តីពីការទាក់ទងជាមួយចិនរួចមកអចិន្ត្រៃយ៍បានសម្រេចចាត់តាំងគណៈកម្មាធិការមួយសម្រាប់ពិនិត្យរៀបចំទំនិញដែលត្រូវទិញដែលមាន អៀង សារី ជា «សមាជិកពិគ្រោះពិភាក្សា» ក្នុងគណៈកម្មាធិការនោះ ។ នៅក្នុង «សេចក្តីសម្រេចរបស់គណៈមជ្ឈិម» ថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៧៦ អៀង សារីត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ អៀង សារី បានចូលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ។ នៅថ្ងៃទី៣ ខែ ឧសភា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» អំពី «ការងារបរទេស» ដែលមាន អៀង សារី ខ្លួនឯងផ្ទាល់ជាអ្នករាយការណ៍ ។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង«អង្គប្រជុំគណៈអចិន្ត្រៃយ៍» អំពី «បញ្ហាពាណិជ្ជកម្ម» ពេលនោះអង្គប្រជុំបានរៀបចំ «គណៈកម្មាធិការពាណិជ្ជកម្មដំណើរទៅហុងកុង គណៈកម្មាធិការកំពង់ផែ និងការទាក់ទងពាណិជ្ជកម្មនិងធនាគារជាមួយចិន» ។ នៅរសៀល និងយប់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» ដើម្បី «ពិនិត្យអំពីប្រតិកម្មរបស់វៀតណាមក្នុង



អៀង សារី ដឹកនាំប្រធានទីប្រឹក្សាចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ (ពាក់អាវស ដើរក្រោយ អៀង សារី) និងជំនាញការចិនជាច្រើនរូបទៀត ទៅត្រួតពិនិត្យមើលការដ្ឋានជួសជុលផ្លូវរថភ្លើងនៅខេត្តតាកែវក្នុងឆ្នាំ១៩៧៧ ។ អមដំណើរជាមួយគ្នានោះ រួមមាន ៖ វន វ៉េត (ឆ្វេង) ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងតាម៉ុក ឯកសណ្ឋានខ្មៅ (ទីពីរាប់ពីស្តាំ) លេខាភូមិភាគនិរតី ។

អង្គប្រជុំលើកទី៥កាលពីពេលព្រឹក» ។ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ អៀង សារី បានជួបសន្ទនាជាមួយសមមិត្ត ផាន ហៀន អនុរដ្ឋមន្ត្រីការបរទេសរបស់វៀតណាម ដោយក្នុងភាគីកម្ពុជាអ្នកដែលចូលប្រជុំរួមមាន សមមិត្ត មុត, សមមិត្ត តូច និង សួង ស៊ីគឿន ។ នៅក្នុងជំនួបនោះ ផាន ហៀន បានរាយការណ៍ជូន អៀង សារី អំពីសភាពការណ៍នៅវៀតណាមអំពីការបោះឆ្នោតទូទៅ សន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធ និងបញ្ហាអាស៊ាន ។ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ អៀង សារី បានចូលរួមក្នុង «អង្គប្រជុំគណៈអចិន្ត្រៃយ៍» អំពីបញ្ហា «ការងារការបរទេស» ក្នុងពេលនោះ អៀង សារី ខ្លួនឯងបានធ្វើ «សេចក្តីរាយការណ៍អំពីសកម្មភាពរបស់ក្រសួងការបរទេស» ។ មុនខែសីហា ឆ្នាំ១៩៧៦ អៀង សារី បានរៀបចំប្រជុំជាមួយ ខៀវ សំផន និង ហ៊ូ នឹម អំពីការទៅចូលរួមសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ។ ក្នុងឆ្នាំ១៩៧៧ ហ៊ូ នឹម ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ឬ ទួលស្លែង ហើយនៅថ្ងៃទី១០ ខែមេសា ចម្លើយសារភាពរបស់ ហ៊ូ នឹម ត្រូវបានផ្ញើជូនទៅ អៀង សារី ដើម្បីអាន ។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៧ លោក រ៉ូសេរីយ៉ូ ឡូបាតូ អគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ទីម័រខាងកើត បានសរសេរសំបុត្រមួយច្បាប់សុំការអនុញ្ញាតពី អៀង សារី ចេញពីកម្ពុជាប្រជាធិបតេយ្យដើម្បីធ្វើដំណើរទៅសាធារណរដ្ឋប្រជាមានិតចិន ។ ក្នុងឆ្នាំ១៩៧៧ អៀង សារី បានចេញបញ្ជាឲ្យធ្វើការវាយប្រហារប្រឆាំងវៀតណាម ។ ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៨ មានលិខិតរាយការណ៍ទៅ អៀង សារី អំពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃប្រទេសយូហ្គោស្លាវី ។ ក្នុងពេលទៅចូលរួមសម័យប្រជុំរបស់អង្គការសហប្រជាជាតិក្នុងខែតុលា ឆ្នាំ១៩៧៨ អៀង សារី បានរៀបចំឲ្យមានសន្និសីទកាសែតមួយ ។ ក្នុងសន្និសីទនោះ អៀង សារី បានប្រកាសថានឹងអញ្ជើញលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ យើត វ៉ុលហែម ឲ្យមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ដោយភ្ជាប់ទៅនឹងការស៊ើបអង្កេតរឿងរំលោភសិទ្ធិមនុស្សក្នុងប្រទេស ។



អៀង សារី កំពុងជួបជាមួយគណៈប្រតិភូមកពីប្រទេសគុយបាក្នុងអំឡុងទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៦ ។ អ្នកបកប្រែភាសាបារាំងគឺ សួង ស៊ីគឿន ខាងស្តាំដៃ អៀង សារី ។

ក្នុងខែមិថុនា ឆ្នាំ១៩៧៨ អៀង សារី, ប៉ុល ពត, ខៀវ សំផន, វន វើត និង ចេង អន បានចូលរួមការសិក្សាមួយនៅសាលាចតុមុខ ដែលនិយាយអំពីការវិលត្រឡប់ចូលស្រុកវិញរបស់អ្នកនៅខាងក្រៅប្រទេសដើម្បីឲ្យជួយរៀបចំកម្មវិធីសិក្សា និងជួយធ្វើការនៅតាមបណ្តាក្រសួងនានា ។ ក្នុងអំឡុងខែសីហា



*អៀង សារី (ទីបួនរាប់ពីស្តាំ) អមដំណើរគណៈប្រតិភូចិនដឹកនាំដោយលោក វ៉ាំ ដុងស៊ីង (ទីបីរាប់ពីស្តាំ) ក្នុងអំឡុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូមកកាន់ប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ អៀង សារី បាននាំគណៈប្រតិភូនេះទស្សនាជុំវិញទីក្រុងភ្នំពេញ ។*



*អៀង សារី (ស្តាំ) ជល់កែវជាមួយ ស៊ុន ហ្វូ អគ្គរដ្ឋទូតចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ នៅទីក្រុងភ្នំពេញ ។*

ឆ្នាំ១៩៧៨ សមាជិករបស់សមាគមមិត្តភាពកម្ពុជា-ស៊ុយអែត ដឹកនាំដោយ ហ្គុនណា បើយស្ត្រម បានមកធ្វើទស្សនកិច្ចរយៈពេល ១៨ថ្ងៃនៅប្រទេសកម្ពុជា ដោយក្នុងអំឡុងពេលនោះ គណៈប្រតិភូបានចូលរួមអាហារជាមួយ ប៉ុល ពត និង អៀង សារី ។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ អៀង សារី ជាឧបនាយករដ្ឋមន្ត្រីបានជួបសន្ទនា និងទទួលរៀបចំពិធីជប់លៀងជូនភ្ញៀវគណៈប្រតិភូក្រសួងពាណិជ្ជកម្មក្រៅប្រទេសនៃសាធារណរដ្ឋប្រជាមានិតចិនដែលដឹកនាំដោយ សមមិត្ត ចេន ជាអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេសចិន ព្រមទាំងបានវាយតម្លៃយ៉ាងខ្ពស់ដល់ការរីកលូតលាស់នៃពាណិជ្ជកម្មរវាងប្រទេសចិន និងកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៨ អៀង សារី បានផ្ញើលិខិតមួយទៅឲ្យ សុន សេន ហៅ សមមិត្ត ខៀវ ដែលនិយាយអំពីសមមិត្តចិនស្នើសុំទៅមើលភូមិភាគបូព៌ាដែលកាលនោះសុនសេន មានភារកិច្ចមើលការខុសត្រូវភូមិភាគបូព៌ា ។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៨ អៀង សារី បានជួបជាមួយអ្នកសារព័ត៌មាន អេលីហ្សាប៊ែត បេកឃើ, រីឆាត ដាត់មេន និង ម៉ាល់ខូម ខូលវែល ក្នុងពិធីបាយល្ងាចនៅវិមានចំការមនដែលមាន ជួន ប្រាសិទ្ធ ជាអ្នកបកប្រែ ។ ក្នុងអំឡុងពេលនោះ អៀង សារី មិនបានឆ្លើយសំណួររបស់ រីឆាត ដាត់មេន ទេ ហើយសុំរង់ចាំឲ្យ ប៉ុល ពត ជាអ្នកឆ្លើយចំពោះថាតើគួរអនុញ្ញាតឲ្យសម្ភាសន៍ឬក៏អត់ ។ ជាជំនួសវិញ អៀង សារី បែរជានិយាយពីរឿងជោគជ័យក្នុងការវាយប្រហារជាមួយវៀតណាមដែលចង់ឲ្យកម្ពុជាទៅជាផ្នែកមួយនៃសហព័ន្ធឥណ្ឌូចិន ។ អ្នកទាំងបីត្រូវបានឲ្យស្នាក់នៅបច្ចុប្បន្នសណ្ឋាគារឡឺរ៉ូយ៉ាល់ ។ ម៉ាល់ខូម ខូលវែល ត្រូវបានសម្លាប់ ដោយខ្មាន់កាំភ្លើងម្នាក់នៅកន្លែងដែលគាត់ស្នាក់នៅ ។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ អេលីហ្សាប៊ែត បេកឃើ និង រីឆាត ដាត់មេន បាន



អៀង សារី (ទីបួនរាប់ពីឆ្វេង) ក្នុងអំឡុងពិធីមង្គលការរបស់ សួង ស៊ីគឿន នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ក្នុងខែមីនា ឆ្នាំ១៩៨៨ ។ ម៉ាឡៃគឺជាអតីតទីតាំងគ្រប់គ្រងរបស់ចលនាខ្មែរក្រហមមុនឆ្នាំ១៩៩៦ ក្រោមការត្រួតត្រាផ្ទាល់របស់ អៀង សារី ។ សួង ស៊ីគឿន គឺជាបញ្ញវន្តមួយរូបដែលធ្លាប់សិក្សានៅប្រទេសបារាំងហើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យធ្វើការនៅក្រសួងការបរទេស ។ សួង ស៊ីគឿន ត្រូវបានសាលាក្ដីខ្មែរក្រហមកោះអញ្ជើញឲ្យមកធ្វើសក្ខីកម្មកាលពីខែសីហា ឆ្នាំ២០១២ ។ ពីឆ្វេងទៅស្ដាំ ៖ ម៉ាលី (ប្រពន្ធ ជួន ជឿន) , វេជ្ជបណ្ឌិត ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ, សូ ផន (អតីតជំនួយការរបស់ អៀង សារី និងជាអនុប្រធានផ្នែកព័ត៌មាន និងឃោសនាការក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ) , សួង ស៊ីគឿន, តាំង ហ៊ុយអេង (ប្រពន្ធ សួង ស៊ីគឿន) , សរ គឹមល្មុត កម្មាភិបាលជាន់ខ្ពស់ផ្នែកធនាគារពាណិជ្ជកម្ម, អៀង ធីរិទ្ធ, ប្រពន្ធរបស់ ស៊ឹម សុន, ប្រពន្ធរបស់ ភី ភួន, វ៉ាន់ រិទ្ធិ, ប្រពន្ធរបស់ ភី ភួន, វ៉ាន់ រិទ្ធិ ប្រធានគណៈកម្មាធិការពាណិជ្ជកម្មក្រោយ កុយ ធួន បញ្ជូនទៅមន្ទីរស-២១ , ស៊ឹម សុន អតីតអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសកូរ៉េខាងជើង (១៩៧៦? - ១៩៧៩) ។



អៀង សារី ក្នុងពិធីមួយក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៦ នៅប៉ៃលិន ដែលរៀបចំឡើងដើម្បីអបអរសាទរ អៀង សារី ដែលបានផ្តាច់ខ្លួនពីចលនាខ្មែរក្រហមមករួបរួមជាមួយរដ្ឋាភិបាល ។ រូបនៅខាងស្តាំគឺ អៀង ធីរិទ្ធ ។ ថតដោយៈ ឆាំង យុ

ចាកចេញពីប្រទេសកម្ពុជាជាមួយនឹងសាកសពរបស់ ម៉ាល់ខ្ញុំ ខ្ញូលវែល ។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៨ អៀង សារី អង្គុយនៅខាងក្រោយ ប៉ុល ពត នៅឯអតីតវិមានរដ្ឋាភិបាលពណ៌ប្រផេះនៅជួរមាត់ទន្លេដែលសង់តាំងពីអាណានិគមបារាំង ប៉ុល ពត បានថ្លែងសុន្ទរកថាអំពីគោលបំណងរបស់វៀតណាមដែលចង់ឲ្យមានសហព័ន្ធឥណ្ឌូចិនដោយចោទវៀតណាមថាបានចងសម្ព័ន្ធមិត្តជាមួយប្រទេសក្នុងកតិកាសញ្ញាសង្រ្គាម និងប្រទេសសូវៀតដើម្បីរៀបចំចូលឈ្លានពានប្រទេសកម្ពុជា ។

ប្រមាណពីសប្តាហ៍ក្រោយមក វៀតណាមបានលើកទ័ពចូលប្រទេសកម្ពុជា ហើយ អៀង សារី ជាមួយនឹងមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យផ្សេងទៀតបានភៀសខ្លួនទៅព្រំដែនថៃ ។ អៀង សារី និង ប៉ុល ពត ត្រូវតុលាការបដិវត្តន៍ប្រជាជនកម្ពុជានៅទីក្រុងភ្នំពេញកាត់ទោសកំបាំងមុខពីបទប្រល័យពូជសាសន៍ ហើយសម្រេចផ្តន្ទាទោសប្រហារជីវិត ។ ទោះបីជារបបកម្ពុជាប្រជាធិបតេយ្យត្រូវដួលរលំក៏ដោយ ក៏ អៀង សារី នៅតែបន្តតួនាទីរបស់ខ្លួនក្នុងរដ្ឋាភិបាលនិរទេសមួយដែលបង្កើតឡើងនៅក្នុងទឹកដីថៃ ប៉ុន្តែ អៀង សារី បានផ្ទេរមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសទៅឲ្យ ខៀវ សំផន វិញ បន្ទាប់ពីបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៨២ ។

នៅខែសីហា ឆ្នាំ១៩៩៦ អៀង សារី គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដំបូងគេ ដែលបានចាកចេញពីចលនាខ្មែរក្រហមជាមួយនឹងអ្នកក្រោមបង្គាប់ និងកងកម្លាំងយោធាខ្មែរក្រហមរាប់ពាន់នាក់ មកចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ។ ការចុះចូលជាមួយរដ្ឋាភិបាលរដ្ឋកម្ពុជានេះគឺជាថ្នូរនឹងព្រះរាជក្រឹត្យលើកលែងទោសពីសំណាក់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ពីការកាត់ទោសប្រហារជីវិតនិងការកាត់ទោសក្រោមច្បាប់ដាក់ខ្មែរក្រហមនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤ ដែលបានចែងថា រចនាសម្ព័ន្ធអង្គការរបស់ខ្មែរក្រហមគឺមានលក្ខណៈមិនស្របច្បាប់ ។ បន្ទាប់មក អៀង សារី បានរស់នៅជាមួយប្រពន្ធរបស់ខ្លួនឈ្មោះ អៀង ធីរិទ្ធ ដោយមានសេរីភាពយ៉ាងពេញលេញនៅទីក្រុងភ្នំពេញ និងម្តងម្កាលនៅប៉ៃលិន ។

នៅឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើទៅអង្គការសហប្រជាជាតិដើម្បីនាំយកអ្នកដែលទទួលខុសត្រូវក្នុងការសម្លាប់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហមយកទៅតុលាការ ។ នៅឆ្នាំ ២០០១ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្នុងឆ្នាំ២០០៣

ទើបកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិក្នុងការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានធ្វើឡើង ។ ឆ្នាំ២០០៦ តុលាការខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានលេចជារូបរាងឡើង និងបានចាប់ផ្តើមដំណើរការការងាររបស់ខ្លួន ។

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានចាប់ខ្លួននៅភូមិគ្រឹះរបស់ខ្លួនទាទីក្រុងភ្នំពេញ ។ អៀង សារី គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩ មួយរូបក្នុងចំណោមមេដឹកនាំជាន់ខ្ពស់សំខាន់ៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យរួមមានៈ អៀង ធីរិទ្ធ, ខៀវ សំផន, នួន ជា និង កាំង ហ្គេចអ៊ាវ ហៅ ឌុច ។

អៀង សារី ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅចន្លោះពេលដែលខ្លួនកាន់អំណាចពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ឧក្រិដ្ឋកម្មទាំងនោះមានៈ

◆ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត ។

◆ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ៈ ការសម្លាប់ក្រុមជនជាតិវៀតណាម និងចាម ។

◆ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាពីឈឺយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំង និងនិរទេសជនស៊ីវិលដោយខុសច្បាប់ ។

◆ អំពើមនុស្សឃាត ៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។

អៀង សារី ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត ទីក្រុងភ្នំពេញ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ ហើយទទួលមរណភាពនៅវេលាម៉ោង៨ និង៤៥នាទីព្រឹក ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ដោយជំងឺបេះដូង ។ សពរបស់ អៀង សារី ត្រូវបានដឹកទៅកាន់ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នៅថ្ងៃដដែលដើម្បីធ្វើពិធីបុណ្យតាមប្រពៃណីពុទ្ធសាសនា ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



រូបខាងឆ្វេងៈ ភី ភួន ហៅ រចឹម ទុន ឬ ចៀម ជាសាក្សីនៅតុលាការខ្មែរក្រហម និង រូបខាងស្តាំៈ អៀង ម៉ិញ កូនស្រីច្បងរបស់ អៀង សារី ។

# ពិធីបុណ្យសពរបស់ អៀង សារី ប្រារព្ធធ្វើនៅភូមិដូង ឃុំម៉ាឡៃ ស្រ








(រូបខាងឆ្វេង) អាន ឧត្តម និង (រូបខាងស្តាំ) ម៉ៃឃើល ការណាវ៉ាស សហមេធាវីការក្តី អៀង សារី ធ្វើបទសម្ភាសន៍កាសែតបន្ទាប់ពី អៀង សារី ទទួលមរណភាព ។





# ្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣











# ការគេណ្ឌយុទ្ធជន និងមនោគមវិជ្ជា

(តចប់)

## សម័យ លន់ នល់ ជម្លោះប្រដាប់អាវុធ

ការគំរាមកំហែងបន្ទាប់ពីការកាន់អំណាចក្នុងប្រទេសកម្ពុជារយៈពេល១៨ឆ្នាំរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងអំឡុងពេលដែលព្រះអង្គគាំទ្រគោលនយោបាយដែលព្រះអង្គអះអាងថានឹងលើកស្ទួយអព្យាក្រឹតភាព ព្រះអង្គត្រូវបានផ្លាស់ប្តូរដោយរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ (ចន្លោះពីឆ្នាំ១៩៧០-១៩៧៥)។ របបថ្មីបានប្រឈមមុខនឹងការឈ្លានពានរបស់វៀតណាមចូលទឹកដីរបស់ខ្លួន។ ជម្លោះកាន់តែកើតឡើងស្តែងៗមិនត្រឹមតែរវាងវៀតណាម និងក្រុមកុម្មុយនីស្តកម្ពុជាពេញផ្ទៃប្រទេសនោះទេ ថែមទាំងរវាងអាមេរិក និងវៀតណាមខាងត្បូងទៀត។ ក្រុមនីមួយៗព្យាយាមកេងចំណេញផ្នែកយុទ្ធសាស្ត្រលើគ្នាទៅវិញទៅមក។ សាធារណរដ្ឋខ្មែរបានទទួលការគាំទ្រពីសហរដ្ឋអាមេរិកក្នុងការប្រយុទ្ធប្រឆាំងខ្មែរក្រហមដែលគាំទ្រដោយប្រទេសចិន។ បន្ទាប់ពីទម្លាក់សម្តេចព្រះនរោត្តម សីហនុ ក្នុងខែមីនា ឆ្នាំ១៩៧០ ព្រះអង្គបានរួបរួមជាមួយអតីតសត្រូវរបស់ព្រះអង្គដែលជាខ្មែរក្រហមក្នុងការអំពាវនាវឲ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈងើបឡើងប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរដែលខុសច្បាប់។ ស្ថានភាពនេះញុះញង់ឲ្យមានសង្គ្រាមស៊ីវិលឃោរឃៅដែលធ្វើឲ្យសេដ្ឋកិច្ចទទួលរងអស្ថិរភាព។ ជាងនេះទៅទៀត ការទម្លាក់គ្រាប់បែករបស់អាមេរិកយ៉ាងធ្ងន់ធ្ងរបានបណ្តាលឲ្យមានភាពក្រីក្រ ការជម្លៀស ការសម្លាប់ប្រជាជនរហូតដល់១៥០.០០០នាក់ ដោយជំរុញឲ្យអ្នករស់រានមានជីវិតជាច្រើនចូលរួមជាមួយចលនាខ្មែរក្រហម។ របប លន់ នល់ បានបាត់បង់ម្ចាស់ការគ្រប់គ្រងនៅតាមជនបទជាច្រើន។

គោលនយោបាយនិងពាក្យតិះដៀលរិះគន់ប្រឆាំងនឹងវៀតណាមរបស់ លន់ នល់ បានផ្តល់ជាតម្រុយដល់ការសម្លាប់ជនជាតិភាគតិចវៀតណាមក្រោមរបប ប៉ុល ពត។ បន្ទាប់ពីរដ្ឋប្រហារយោធាក្នុងខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានជំរុញឲ្យមានការគាំទ្រ "សង្គ្រាមព្រះពុទ្ធសាសនា" ប្រឆាំងនឹងជនជាតិវៀតណាម



កងអាវុធហត្ថរបស់របប លន់ នល់ នៅជិតវត្តព្រះកែវមរកតក្រុងភ្នំពេញអំឡុងពេលហ្វឹកហាត់

ដែលចាត់ទុកថាជាការគំរាមកំហែងដល់ស្ថានភាពរបស់កម្ពុជា ។ ជាញឹកញយ ទាហាន លន់ នល់ បានគំរាមកំហែង និងសម្លាប់ជនជាតិភាគតិចវៀតណាម ហើយមួយចំនួនទៀតត្រូវបានចាប់ដាក់ឃុំ ។ ជនជាតិវៀតណាមជាច្រើនត្រូវបានសម្លាប់ ។ ក្នុងខែសីហា ឆ្នាំ១៩៧០ប្រហែល៣១០.០០០នាក់ ក្នុងចំណោមជនជាតិភាគតិចវៀតណាម ៤៥០.០០០នាក់ នៅក្នុងប្រទេសកម្ពុជាត្រូវបានជឿថាបានចាកចេញពីប្រទេសកម្ពុជា ។ ការស្អប់ជនបរទេសត្រូវបានប្រើជាឧបករណ៍បង្រួបបង្រួមកម្លាំង និងធ្វើយុត្តិកម្មអំណាចដែលអាចសម្រេចបានតាមរយៈការធ្វើខេមរយានូកម្មសេដ្ឋកិច្ចមួយចំនួនដូចជា ការនេសាទត្រីក្នុងបឹងទន្លេសាប ដែលជាមធ្យោបាយប្រឆាំងជនជាតិវៀតណាមផ្សេងមួយទៀតដោយសារក្រុមជនជាតិភាគតិចដទៃផ្សេងទៀតមិនបានចូលរួមក្នុងដំណើរការនេះ ។ ឆ្នាំ១៩៧៣ ជនជាតិវៀតណាមជាច្រើនបានចាកចេញពីប្រទេសកម្ពុជា ។ ការទម្លាក់គ្រាប់បែករបស់អាមេរិកបានឈប់ពាក់កណ្តាលឆ្នាំនោះ ។ ខណៈដែលប្រជាជននៅទីក្រុងគាំទ្ររបប លន់ នល់ ក្រោយមក ប្រជាជនទាំងនោះ ខកចិត្តចំពោះរបបនោះដោយសារតែអំពើពុករលួយ និងការវិវដ្តទៅរកភាពផ្តាច់ការខាងយោធា ។

**មនោគមវិជ្ជា៖ មនោគមវិជ្ជាកសិកម្មយោធា និងខេមរយានុកម្មថ្មីដែលជាទំនើបកម្មប្រតិកិរិយា**

ក្នុងរបប លន់ នល់ សង្គ្រាមស៊ីវិល បាននាំឲ្យមានការកេណ្ឌប្រជាជនទាំងអស់ដែលគាំទ្រដោយរដ្ឋដើម្បីប្រយុទ្ធជាមួយកុម្មុយនីស្តខ្មែរក្រហម ។ នៅពេលដែល លន់ នល់ ថ្លែងក្នុងសភាជាតិក្នុងឆ្នាំ១៩៧២ «យុវជន និងមនុស្សចាស់ ជនស៊ីវិល និងយោធាទាំងអស់គ្នា បានក្រោកឈរការពារប្រទេសរបស់ខ្លួនពីគ្រោះមហន្តរាយ» ។ លន់ នល់ បានអំពាវនាវឲ្យមានចលនាពេញនិយមមួយដែលបង្រួបបង្រួមមនុស្សដើម្បីវាយប្រយុទ្ធឧបសគ្គទាំងអស់ដើម្បីការពារ កសាង និងពង្រីកទឹកដី ។ ពេលសង្គ្រាមចាប់ផ្តើម យុវជនមិនត្រូវបានចាត់ទុកថាជាក្រុមយុទ្ធសាស្ត្រតែឯងនោះទេ ដោយសារតម្រូវការបន្ទាន់នៃសង្គ្រាម មនុស្សទាំងអស់ក្នុងសង្គមត្រូវបានកេណ្ឌធ្វើទ័ព ។

ប៉ុន្តែការកេណ្ឌកងស្ម័យគ្រាណមួយចំនួននៅតែបន្តអនុវត្ត ។ ឧទាហរណ៍ យុវជនសង្គមរាស្ត្រនិយមខ្មែរដែលគាំទ្រសម្តេចព្រះ នរោត្តម សីហនុ បានប្រែទៅជាយុវជនស្រោចស្រង់គាំទ្ររបស់សាធារណរដ្ឋខ្មែរវិញ ដែលព្រឹត្តិប័ត្រព័ត៌មានរបស់យុវជនស្រោចស្រង់ទាំងនោះត្រូវបោះពុម្ពផ្សាយជារៀងរាល់សប្តាហ៍ ។ ក្នុងចំណោមអង្គការចាត់តាំងទាំងនោះ អង្គការចាត់តាំងយោធាកសិកម្មត្រូវបានលើកស្ទួយដែលយុវជនត្រូវបានស្នើឲ្យគាំទ្រទាហានដោយចូលរួមការងារផលិតកម្ម និងសូម្បីតែប្រយុទ្ធប្រឆាំងនឹងសត្រូវក្នុងពេលចាំបាច់ ។ យុវជនស្រោចស្រង់ បានរៀបចំថ្ងៃអបអរសម្រាប់យោធានៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧១ ដើម្បីបង្ហាញការគាំទ្រជានិមិត្តរូបដល់យោធាទាំងនោះដោយមានការផ្តល់វត្ថុអនុស្សាវរីយ៍ ។ គោលបំណងនេះ ត្រូវអ្នកតំណាងយុវជនស្រោចស្រង់ពោលអះអាងក្នុងសុន្ទរកថាដែលថា៖

> *យើងដែលបានសហការយ៉ាងជិតស្និទ្ធជាមួយជនសកម្មប្រយុទ្ធរបស់យើងជាច្រើនខែនោះនឹងនៅតែចងចាំសាមគ្គីភាព រវាងទាហាន និងយុវជន ។ ឥឡូវទោះបីជាយើងត្រូវជាប់រៀនសូត្រ ហើយមិនអាចធ្វើជាទាហានក៏ដោយ ក៏ទស្សនៈរបស់យើងនៅជាមួយជនសកម្មប្រយុទ្ធគ្រប់ពេលវេលា ហើយយើងនៅតែត្រៀមខ្លួនជាស្រេចដើម្បីបន្តការតស៊ូប្រឆាំងនឹងសត្រូវរហូតដល់ទទួលបានជ័យជម្នះចុងក្រោយ ។*

លន់ នល់ បានអរគុណយុវជនស្រោចស្រង់ដោយគូសបញ្ជាក់ថា យុវជនទាំងនោះ គឺជាអនាគតរបស់ប្រទេសកម្ពុជា ហើយគាត់បានកត់សម្គាល់ថា «យុវជន និងយោធានឹងលះបង់ដើម្បីជ័យជម្នះមួយ ដែលនឹងនាំទៅរកសន្តិភាព ការវិវដ្ត និងភាពថ្កើងថ្កានរបស់សាធារណរដ្ឋខ្មែរ ហើយគាត់មិនឲ្យនរណាម្នាក់លូកដៃចូលក្នុងចលនានោះទេ ។ ឧទាហរណ៍ដែលបានលើកឡើងនៅផ្នែកខាងក្រោយបានបង្ហាញថា ក្រុមយុវជនបានធ្វើសង្គមនិយកម្មគ្រួសាររបស់ខ្លួនតាមរយៈការបង្រៀនពីជំនាញកសិកម្ម និងតាមរយៈការគូសបញ្ជាក់ពីរបត់សង្គមនៃការផ្ទេរជំនាញ ។ «ដែនដីអាណានិគមរបស់យុវជន» ត្រូវបានបង្កើតឡើងសម្រាប់យុវជន ដើម្បីចូលរួមការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់តាមរយៈការ

ធ្វើកសិកម្មថែដូន និងការបន្ទាត់ពូជសត្វ ។ ក្រៅពីនេះ ជំរំយុវជនត្រូវបានរៀបចំឡើងដើម្បីបង្រៀនពីកសិកម្ម និងការបន្ទាត់ពូជសត្វ ដល់យុវជន ។ ស្របពេលជាមួយគ្នានេះ ខណៈដែលអំឡុងរបប សីហនុ ភាពគ្មានការងារធ្វើក្នុងចំណោមយុវជននៅទីក្រុងបន្តក្លាយជាបញ្ហា រដ្ឋបានកេណ្ឌយុវជនសម្រាប់ផែនការសេដ្ឋកិច្ច និងការពារជាតិ ។ សាធារណរដ្ឋខ្មែរបានឆ្លើយតបទៅនឹងការប្រឈមក្នុងការស្វែងរកការងារ ដូចដែលរបបសម្តេចព្រះ នរោត្តម សីហនុ ធ្លាប់ធ្វើដោយឲ្យយុវជនចូលរួមក្នុងការងារជួយសេដ្ឋកិច្ច ។ ឆ្នាំ១៩៧១ ប្រមុខយុវជនបានបង្កើត "កងស្ម័យគ្រាណសេដ្ឋកិច្ច" ដែលយុវជនចូលរួមក្នុងការចិញ្ចឹមត្រី និងដាំដំណាំហូបផ្លែ ។ ដើម្បីជំទាស់ទៅនឹងតម្លៃម្ហូបឡើងខ្ពស់ និងដើម្បីជួយសេដ្ឋកិច្ចវេគ្រោះដោយសង្គ្រាម កសិករនេសាទត្រី បានលក់ផលត្រីរបស់ខ្លួននៅតម្លៃថោក ។ យុវជនដទៃធ្វើការចិញ្ចឹមមាន់ និងជ្រូក ។ អំឡុងសម័យនោះ ប្រមុខយុវជនបានសាកល្បងបង្កើតដែនដីអាណានិគមសម្រាប់មនុស្សជាន់មុន ដែលទាមទារឲ្យយុវជនមិនត្រឹមតែចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ថែមទាំងការពារជាតិ ដោយបណ្តុះស្មារតី ក្រុមដែលថា៖

*យុវជនមានឱកាសយល់ដឹងពីប្រទេសជាតិរបស់ខ្លួន និងមានឱកាសពង្រឹងស្មារតីជាតិ ហើយម្យ៉ាងទៀតមានឱកាសលះបង់ពេលវេលារបស់ខ្លួនចំពោះការងារសេដ្ឋកិច្ច ហើយយុវជនមានឱកាសរៀនសូត្រពីរបៀបការពារប្រទេសរបស់ខ្លួន ។*

ការឃោសនាកាលសម័យនោះ បានសង្កត់ធ្ងន់ដោយប្រយោលពីសេចក្តីចាំបាច់ក្នុងការបង្កើតមនុស្សថ្មី ដោយគូសបញ្ជាក់ពីស្មារតីសមូហភាពដែលលះបង់ចំពោះការជួយប្រទេសតាមរយៈការអភិវឌ្ឍ ។ ក្រៅពីនេះ យុវជនត្រូវប្រតិបត្តិតាមការដាក់វិន័យយោធា ដែលការគោរពចំពោះអ្នកមានអំណាច និងសាធារណរដ្ឋខ្មែរត្រូវបានលើកស្ទួយ ។ ផែនការបែបនោះត្រូវបានជំរុញលើកទឹកចិត្តដោយគំរូរបស់ភូមិណាហាលក្នុងប្រទេសអ៊ីស្រាអែល ដែលបានបង្កើតឡើងដោយទាហានអ៊ីស្រាអែលក្មេងៗនៅតាមបណ្តោយព្រំដែនប្រទេស និងបានរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសអំឡុងពេលសម័យកាលបម្រើយោធា ។ មេដឹកនាំរបស់សាធារណរដ្ឋខ្មែរ បានជឿជាក់ក្នុងកិច្ចសហការណ៍ជាមួយយុវជនហើយធ្វើឲ្យអ្នកស្រែរំដួលចិត្តចំពោះតួនាទីរបស់ខ្លួន ។ ជំនឿនេះ ផ្អែកលើការអនុវត្តតាមប្រពៃណីនៃការជួយគ្នាទៅវិញទៅមកដែលស្គាល់ថាជាប្រវាសដៃគ្នាដែលកសិករ ធ្វើស្រែបានជួយភ្ជួររាស់ ស្ទូង និងច្រូតកាត់ ដូច្នេះកាតព្វកិច្ចទាំងអស់ និងត្រូវបញ្ចប់ក្នុងកាលកំណត់ពេលមានភ្លៀងធ្លាក់ ។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានក្តោបអំណាចហើយ សិរិ មតៈ ជាអ្នកគ្រប់គ្រង ថ្វីបើគាត់គឺជាអ្នកគ្រប់គ្រងទីពីរក៏ដោយ ។ ជាមួយគ្នានោះដែរ លន់ នល់ និង សិរិ មតៈ មានបំណងបង្កើតសង្គមមួយដែលគ្មានអាណានិគមដោយផ្អែកលើបាវចនា "ជាតិ សាសនា និងសាធារណរដ្ឋ" ។ ទោះបីជាយ៉ាងនេះក៏ដោយ របបនោះមិនបានកំណត់ច្បាស់ពីលទ្ធិរបស់របបសាធារណរដ្ឋ ជាជាងលទ្ធិដែលមានស្រាប់ គឺផ្អែកលើការប្រឆាំងជំទាស់ទៅនឹងសម្តេចព្រះ នរោត្តម សីហនុ និងសម្ព័ន្ធមិត្តរបស់ព្រះអង្គ និងជនកុម្មុយនីស្ត ។ លន់ នល់ ជឿថា ជនជាតិកម្ពុជាចាំបាច់ត្រូវការរួបរួមដោយស្មារតីស្នេហាជាតិ ហើយថា ឯករាជ្យសុវត្ថិភាព និងវិបុលភាព ទាមទារឲ្យមានសម្ព័ន្ធភាព ។ សម្ព័ន្ធភាពព្រះពុទ្ធសាសនាហាក់បីដូចជាជម្រើសដ៏ល្អសម្រាប់រូបគាត់ ហើយ លន់ នល់ បានប៉ុនប៉ងបង្កើតទំនាក់ទំនងជាមួយប្រទេសអាស៊ីដទៃដែលកាន់ព្រះពុទ្ធសាសនា ។ ដូចដែលគាត់បានថ្លែង "មនុស្សគ្រប់គ្នាគួរតែកត់សម្គាល់ថាសាសនានៅតំបន់ដទៃក្នុងពិភពលោកត្រូវបានរៀបចំឲ្យទៅជាស្ថាប័នអន្តរជាតិដែលមានឥទ្ធិពលខ្លាំងដូចអង្គការចាត់តាំងនយោបាយអន្តរជាតិ ។ ដើម្បីប្រឆាំងទល់នឹងឧត្តមគតិរបស់អ្នកសង្គមនិយម ឧត្តមគតិខាងសាសនាព្រះពុទ្ធត្រូវបានលើកឡើង ដូច្នេះហើយអត្តសញ្ញាណរបស់ព្រះពុទ្ធសាសនា ត្រូវបានលើកស្ទួយតាមរយៈការអំពាវនាវឲ្យមានការកសាងអង្គការចាត់តាំងនយោបាយសាសនាព្រះពុទ្ធអន្តរជាតិដែលមានឥទ្ធិពលដល់នយោបាយពិភពលោក" ។ លន់ នល់ បានអះអាងដែរថា "ប្រការនេះនឹងអនុញ្ញាតឲ្យយើងបន្តប្រពៃណីរបស់ដូនតារបស់យើងជារៀងរហូតនិងដើម្បីស្វែងរកការគាំទ្រខាងសីលធម៌ពីប្រទេសដទៃសម្រាប់ គោលនយោបាយការពារការឈ្លានពាន" ។ ដូចទៅនឹងសម្តេចព្រះនរោត្តម សីហនុ ដែរ លន់ នល់ បានកេង

ចំណេញផលប្រយោជន៍នយោបាយដែលមានស្រាប់ដូចក្នុងករណីព្រះពុទ្ធសាសនាដើម្បីទទួលបានការគាំទ្រពីប្រជាជនក្នុងតំបន់ ។ ដូចទៅនឹងសម្តេចព្រះ នរោត្តម សីហនុ លន់ នល់ បានស្វែងរកអំណាចតាមរយៈអរិយធម៌ខ្មែរ ។ គាត់ប្រកាសថា «ដុសខាត់វប្បធម៌ខ្មែរមន ពីព្រោះវាជាមូលដ្ឋាននៃអរិយធម៌របស់យើង» ។ វាជាវប្បធម៌ដែលផ្តល់ឲ្យប្រទេសយើងនូវភាពថ្កុំថ្កើងកាលពីសម័យមុនហើយនៅតែជាវប្បធម៌មួយដ៏មានកិត្យានុភាពក្នុងអាស៊ី ។

លន់ នល់ បាននិយាយអំពី «ខេមរយានុត្តកម្មថ្មី» ។ ពាក្យ «ខេមរយានុត្តកម្ម» បានគូសបញ្ជាក់ពីទំនាក់ទំនងរវាងអតីតកាលដ៏អស្ចារ្យទៅនឹងប្រជាជនកម្ពុជា ខណៈដែលពាក្យថ្មី «Neo» សំដៅទៅរកអនាគត ស៊ីវិល័យដែលមិនមានមនោគមវិជ្ជាផ្តាច់ការ» ។ ខេមរយានុត្តកម្មថ្មីនោះ គឺជាទស្សនវិស័យរបស់ជាតិនិយម ដែលជាសង្គមកសិវប្បធម៌ប្រមូលផ្តុំដែលយកគំរូតាមសម័យកាលអង្គរព្រមទាំងសម្រេចបានតាមរយៈការធ្វើទំនើបកម្មបច្ចេកវិទ្យា ។ ដែនដីអាណានិគមរបស់អ្នកជំនាន់មុន ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ក្បែរតំបន់អង្គរ ដោយសារប្រការនេះអាចជួយឲ្យយុវជនយល់ដឹងពីតម្លៃនៃតំបន់នោះ និងចូលរួមថែរក្សា ហើយមោទកភាពជាតិដែលកើតចេញពីអតីតកាលដ៏មានកិត្យានុភាពរបស់ប្រជាជនខ្មែរនឹងរួមចំណែកដល់ការពង្រឹងស្មារតីជាតិ ។ យុវជនដែលត្រូវបានបញ្ជូនទៅជនបទដើម្បីជួយតំបន់ទាំងនោះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងទស្សនវិស័យនៃអនាគតជាតិ ។ មេដឹកនាំជាច្រើនជឿថា ការកសាងផ្ទះឲ្យគ្រួសារតាមជនបទ គឺជាការឆ្លើយតបចំពោះបញ្ហាចំណាកស្រុកតាមរយៈ «ការផ្តល់លក្ខខណ្ឌសមស្របក្នុងការបណ្តុះបណ្តាលយុវជន ហើយជំរុញឲ្យយុវជនធ្វើការអភិវឌ្ឍខ្លួន និងជួយយុវជនដទៃឲ្យទទួលស្គាល់ថា ការងារកសិកម្មគឺមិនមែនជាការប្រមាថនិងជាការល្ងង់ខ្លៅនោះឡើយប្រសិនបើយុវជនបានត្រៀមខ្លួនសម្រាប់ការងារនោះ» ។ ប្រមុខយុវជនបានថ្លែងទាក់ទងនឹងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងភាពគ្មានការងារធ្វើដែលថា «ឱកាសនេះត្រូវបញ្ជូនយុវជនទៅជនបទជាជាងទៅទីក្រុងជាទីដែលមិនមានលក្ខខណ្ឌអំណោយផលសម្រាប់យុវជន» ។ កម្ពុជាគឺជាប្រទេសកសិកម្ម ហើយពិតប្រាកដណាស់កសិកម្មបានបង្កើតមូលដ្ឋានរបស់ប្រទេស ។

ការធ្វើទំនើបកម្ម ជាពិសេសដូចជា ការកសាងទំនប់ ការជីកអាងស្តុកទឹក ការប្រើប្រាស់ជី និងការប្រើប្រាស់ត្រាក់ទ័រ បានជួយបង្កើនទិន្នផលស្រូវពីមួយតោនកន្លះទៅពីរតោនក្នុងមួយហិចតា ។ ទោះបីជាយ៉ាងនេះក៏ដោយ តាមការអង្កេតរបស់ លោក ស្ទូម កាតព្វកិច្ចក្នុងការធ្វើសង្គ្រាមព្រមទាំងការធ្វើកិច្ចការងាររដ្ឋដទៃគឺជាការងារច្រើនហួសសម្រាប់ជនសាធារណរដ្ឋដែលគ្មានបទពិសោធន៍ ដូច្នេះហើយ របប លន់ នល់ មិនបានស្ថិតស្ថិរយូរអង្វែងនោះទេ ។

## សម័យ ប៉ុល ពត : ការធ្វើកំណែទម្រង់សង្គម ការគំរាមកំហែង : សត្រូវលាក់ខ្លួន និងសត្រូវខាងក្រៅ

ដើមខែមេសា ឆ្នាំ១៩៧៥ លន់ នល់ ត្រូវបានបង្ខំឲ្យធ្វើនិរទេស ហើយកងកម្លាំងរបស់ ប៉ុល ពត បានគ្រប់គ្រងទាំងស្រុង ។ ការកាន់កាប់របស់ខ្មែរក្រហមដែលប្រឈមនឹងការឈ្លានពានរបស់វៀតណាម បានដាក់ការការពារជាតិជាអទិភាព ជាជាងការធានាឲ្យមានការផ្គត់ផ្គង់ស្បៀងអាហារគ្រប់គ្រាន់សម្រាប់ប្រជាជនកម្ពុជា ។ ចុងបញ្ចប់ សង្គ្រាមជាមួយវៀតណាម ក៏បានផ្ទុះឡើង



ទាហាននិងមន្ត្រីរដ្ឋការនៅក្នុងរបប លន់ នល់ ដែលយោធាខ្មែរក្រហមចាប់ខ្លួនបានក្រោយថ្ងៃ១៧ ខែមេសា ១៩៧៥

ក្នុងឆ្នាំ១៩៧៧ ។

សត្រូវលាក់ខ្លួននៅក្នុងចំណោមប្រជាជន និងក្នុងចំណោមអ្នកមានឋានន្តរស័ក្តិនៅក្នុងបក្ស គឺជាការគំរាមកំហែងដល់របបកម្ពុជាប្រជាធិបតេយ្យ ។ របបមួយនេះ បានទទួចថា ការគំរាមកំហែងទាំងនេះ ចាំបាច់ត្រូវកម្ចាត់ចោល ។ យោងទៅតាមលោកអាឡិចសាន់ឌ័រ ហីលតុន ការមិនអាចសម្រេចនូវផលិតកម្ម ស្បៀងបានធ្វើឲ្យខ្មែរក្រហមកាន់តែប្រកាន់យកទស្សនៈការពារជាតិ ។ ដើម្បីសម្រេចបាននូវចំនួនស្បៀងអាហារផ្គត់ផ្គង់ប្រជាជនជនបទដ៏ច្រើននោះ កម្មាភិបាលតំបន់បានប្រើបង្វែរស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ប្រជាជនក្រុងភ្នំពេញឲ្យទៅជាស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ប្រជាជនតាមជនបទ ។ នៅពេលដែលមេដឹកនាំបក្សបានទទួលដំណឹងពីរបាយការណ៍ស្តីពីទុក្ខវេទនារបស់ប្រជាជនតាមជនបទ មេដឹកនាំទាំងនោះ បានសន្និដ្ឋានថា អំពើបះបោរដើម្បីរំលំរំលើងរបបគ្រប់គ្រងរដ្ឋ បានបណ្តាលឲ្យមានស្ថានភាពបែបនេះ ។ ប៉ុល ពត បាននិយាយថា “ជនស៊ីវិលតូចតាច” ដូចជាជំងឺអ៊ឹចឹងហើយជនទាំងនោះត្រូវតែកម្ចាត់ចោល បើតាមអ្វីដែលគាត់ហៅជនទាំងនោះថាជាខ្មាំងផ្ទៃក្នុង ។ ជនជាតិភាគតិចដែលគ្មានជំនឿលើបក្សបានក្លាយជាគោលដៅក្នុងការសម្លាប់ ដូចជា ជនជាតិភាគតិចវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា និងជនភាគតិចថៃ ។



ប្រជាជនកម្ពុជាកំពុងធ្វើការក្នុងរបបខ្មែរក្រហម

មេដឹកនាំកម្ពុជា មិនត្រឹមតែត្រូវការពារសត្រូវខាងក្រៅនោះទេថែមទាំងត្រូវការពារសត្រូវក្នុងចំណោមជួរមេដឹកនាំរបស់ខ្លួន ។ សំណេរក្នុងទស្សនាវដ្តីយុវជនបដិវត្តន៍ ក្នុងឆ្នាំ១៩៧៧ បានលើកឡើងថា៖

> គួរកត់សម្គាល់ថា ទោះបីជាជនចក្រពត្តិអាមេរិកព្រមទាំងវណ្ណៈជិះជាន់ផ្សេងៗ ត្រូវបានបំបាក់ខាងនយោបាយ និងសេដ្ឋកិច្ច ក៏ជនទាំងនោះមិនទាន់រលាយសាបសូន្យទាំងស្រុងនោះទេ ។ ជនទាំងនោះរឹងសម្បា ចំពោះជ័យជម្នះជាប្រវត្តិសាស្ត្រដែលប្រទេសទទួលបានដោយប្រជាជនស្ថិតក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ យុវជនបដិវត្តន៍របស់យើងបានយល់ឃើញថាប្រការនេះជាការសំខាន់ដើម្បីបន្តបដិវត្តន៍ឲ្យកាន់តែខ្លាំងក្លាជាងមុន អាស្រ័យហេតុនេះ ការការពារប្រទេស និងបក្សកុម្មុយនីស្តកម្ពុជាដោយស្មោះត្រង់ និងឥតងាករេនិងការការពារផលប្រយោជន៍បដិវត្តន៍ត្រូវតែធានាឲ្យបាន ។

## កសិកម្មសុខក្សេមក្សាន្ត ឥទ្ធិពលនៃគំរូបរទេស និងទំនើបកម្មប្រតិកិរិយា

ដោយសារខ្មែរក្រហម បានកាន់កាប់ប្រទេសទាំងស្រុង យុវជន ត្រូវធ្វើតាមគោលការណ៍ប្រឆាំង ដែលជាវិធានការបំផ្លាញយ៉ាងខ្លាំងក្លារបស់បក្សក្នុងការកែប្រែសង្គម ។ នៅប្រទេសចិន ការចូលរួមរបស់យុវជន មានសារសំខាន់ចំពោះការសម្រេចបាននូវសង្គមបដិវត្តន៍ ហើយលក្ខណៈពិសេសនៃការកេណ្ឌយុវជនក្នុងរបបខ្មែរក្រហម គឺផ្អែកលើមនោគមវិជ្ជា និងការអនុវត្តដែលដាក់ចេញដោយប្រមុខយុវជន ក្នុងប្រទេសកុម្មុយនីស្តជិតខាង ។ ភាពមន្ទិលក្នុងការបង្កើតសង្គមថ្មីក្នុងប្រទេសចិន និងកម្ពុជា ត្រូវបានយល់ឃើញថាជាផ្នែកមួយនៃកសិកម្មតាមការស្រមើស្រមៃ (Utopian Agrarainism) ដោយសំដៅទៅរកការបង្កើតសង្គម

កុម្មុយនីស្តរដ្ឋសីនី (Autochtone Communist Society) (រដ្ឋសីនី គឺជារដ្ឋដែលមានមនុស្សជំនាន់ដើម និងមនុស្សជំនាន់ក្រោយរស់នៅតែកន្លែងតែមួយ) ដោយផ្អែកលើភាពម្ចាស់ការ និងឯករាជភាពខាងសេដ្ឋកិច្ច និងទំនើបកម្ម ដោយមនោគមវិជ្ជាកសិកម្មក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេស ដោយឡែក ដូចជាលក្ខណៈនៃព្រះពុទ្ធសាសនាដែលខុសប្លែកពីលក្ខណៈនៃព្រះពុទ្ធសាសនាក្នុងប្រទេសចិន ។

មនោគមវិជ្ជាកសិកម្មអំឡុងសម័យ ប៉ុល ពត រងឥទ្ធិពលដោយទស្សនៈនៃការជួយខ្លួនឯង និង ទស្សនៈឧស្សាហកម្មនីយកម្មជឿនលឿន (ឧស្សាហនីយកម្ម គឺជាការកែប្រែប្រទេសឲ្យទៅជាប្រទេសឧស្សាហកម្ម) ដែល ម៉ៅ សេទុង បានប្រកាសឲ្យប្រើក្នុងប្រទេសចិនអំឡុងទសវត្សរ៍៥០ ។ មួយក្នុងចំណោមគោលដៅបដិវត្តន៍របស់ខ្មែរក្រហមគឺការពឹងផ្អែកលើខ្លួនឯង ហើយកម្មាភិបាលខ្មែរក្រហម បានប្រើពាក្យស្លោកស្រដៀងទៅនឹងពាក្យស្លោកចិនដើម្បីសម្រេចឲ្យបានគោលដៅនោះ ។ ប៉ុល ពត មានបំណងកម្ចាត់ឥទ្ធិពលបរទេសក្នុងប្រទេសកម្ពុជា ហើយគ្រប់គ្រងការងារជាតិទាំងអស់សម្រាប់គោលដៅរបស់ខ្លួន ។

ការពឹងផ្អែកខ្លួនឯងរបស់កម្ពុជា បានប្រែក្លាយទៅជាការខិតខំប្រឹងប្រែងយ៉ាងសំខាន់ដើម្បីបង្កើនផលិតកម្មស្រូវ និងប្រព័ន្ធធារាសាស្ត្រ ។ ស្រូវ គឺជាកត្តាគន្លឹះដើម្បីសម្រេចបាននូវកសិកម្មសុខក្សេមក្សាន្ត ដោយផ្អែកលើរដ្ឋដែលមានភាពម្ចាស់ការខាងធនធាន និងការធ្វើទំនើបកម្មជាតិ ។ លោក ដេវីដ ឆេនដ្លឺរ ពន្យល់ថា ខ្មែរក្រហមមានផែនការបង្កើនផលិតកម្មកសិផលដើម្បីប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសឧស្សាហកម្ម ។ បាវចនាស្តីពីសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានចែងថា "ប្រសិនបើយើងមានស្រូវ យើងអាចមានអ្វីៗទាំងអស់" ប្រការនេះ បានលើកសម្ដីអះអាងរបស់ ម៉ៅ សេទុង អំឡុងបដិវត្តន៍មហាលោតផ្លោះ ដែលថា "មានស្បៀង និងអាវុធ មានអ្វីៗទាំងអស់" ។ ក្នុងអត្ថបទរបស់ខ្មែរក្រហមដែលស្តីពី "អត្ថន័យរបស់យុវជន" កម្មាភិបាលបានលើកតម្កើងពាក្យស្លោក "បដិវត្តន៍មហាលោតផ្លោះ" ដើម្បីក្រើនរំឭកយុវជនពីកាតព្វកិច្ចរបស់ខ្លួនក្នុងការចូលរួមបម្រើជាកម្លាំងដើម្បីកសាងប្រទេសថ្មីមួយ ។ យុវជនកម្ពុជា ត្រូវបានស្នើឲ្យចូលរួមការងារសេដ្ឋកិច្ចក្នុងការពឹងផ្អែកខ្លួនឯង ដោយយកគំរូមនោគមវិជ្ជាកសិកម្មដើម្បីសម្រេចសុខដុមភាពសង្គម ។ ឧទាហរណ៍ ដោយនិយាយសំដៅទៅរកទង់ជ្រើរបស់សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ឬយុវកក ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៧១ ទស្សនាវដ្ដីយុវជនបដិវត្តន៍បានកត់សម្គាល់ពីឥរិយាបថគំរូរបស់សមាជិករបស់ខ្លួន ។

> យុវកក គឺជាគំរូល្អ និងនាំមុខ ដែលមានភាពក្លាហាន និងសកម្ម គ្រប់ស្ថានភាព និងលក្ខខណ្ឌការងារទាំងអស់ទាំងតូច ឬធំ ធ្ងន់ ឬស្រាល ពិបាក ឬស្រួលតាមការតម្រូវរបស់បក្ស ។ ជាងនេះទៅទៀត សម្ព័ន្ធនោះ ចូលរួមការងារជីកប្រឡាយ និងត្រពាំងសម្រាប់ប្រព័ន្ធធារាសាស្ត្រ ។ ប្រការនេះ ជួយដោះស្រាយបញ្ហាផ្គត់ផ្គង់ទឹក និងអាចឲ្យមនុស្សធ្វើការដាំដុះលើដីកសិកម្មរបស់ខ្លួនដើម្បីបង្កើនជីវភាពរបស់ប្រជាជនមូលដ្ឋាន ។

ការពឹងផ្អែកលើខ្លួនឯង គឺជាសេចក្តីចាំបាច់សម្រាប់បដិវត្តន៍សង្គម និងសេដ្ឋកិច្ចទាំងស្រុង ។ គោលដៅរបស់មេដឹកនាំសម្រាប់កម្ពុជា គឺត្រូវសម្រេចឲ្យបាននូវលក្ខខណ្ឌឧស្សាហកម្ម និងភាពទំនើបតាមរយៈការធ្វើស្រែចម្ការ និងការបង្កើតឧស្សាហកម្មលក្ខណៈគ្រួសារក្នុងឃុំដែលមានម្ចាស់ការលើខ្លួនឯង ដូច្នេះហើយ យុវជន បានបង្កើនល្បឿនអភិវឌ្ឍជាតិយ៉ាងលឿន ។ ឧទាហរណ៍ក្នុងឆ្នាំ១៩៧៦ យុវជនបដិវត្តន៍ ត្រូវបានគេកោតសរសើរចំពោះការរួមចំណែករបស់ខ្លួន ក្នុងការសម្រេចផែនការផលិតស្រូវបីតោនក្នុងមួយហិកតា ។ ក្រោយមក ផែនការនេះ បានក្លាយជាផ្នែកនៃផែនការរយៈពេលបួនឆ្នាំ (ចន្លោះឆ្នាំ១៩៧៧-១៩៨០) ដើម្បីសម្រេចឲ្យបានទិន្នផលជាតិមធ្យមបីតោនស្រូវក្នុងមួយហិកតា ។ មេដឹកនាំកម្ពុជា បានចម្លងផែនការកសិកម្មរបស់ចិនដោយមិនបានផ្តោតការយកចិត្តទុកដាក់ចំពោះការពិតដែលថាការធ្វើស្រែនៅប្រទេសចិនទទួលបានទិន្នផលខ្ពស់ជាងនៅប្រទេសកម្ពុជា ។ ដូចលោក ស្កុត បង្ហាញក្នុងបរិបទផ្សេងៗ ផែនការធ្វើទំនើបកម្មជារឿយៗមិនបានពិចារណាលើការប្រព្រឹត្តជាក់ស្តែង និងលក្ខខណ្ឌការងារនោះឡើយដែលនាំទៅរកលទ្ធផលមហន្តរាយ ។ គំរូកសិកម្ម ត្រូវបានកំណត់ជាថ្មីដើម្បីរក្សាភាពផ្តាច់ការរបស់វណ្ណៈ

ពលដីព ។ សុន្ទរកថាជាផ្លូវការមួយបានគូសបញ្ជាក់ថា ជនជាតិខ្មែរស្មោះត្រង់រួមមាន "កម្មករ កសិករ និងកងកម្លាំងបដិវត្តន៍" ។ ដោយនិយាយពីគំរូរបស់ចិន ការប្រឆាំងទៅនឹងសីលធម៌ ត្រូវបានឆ្លុះបញ្ចាំងពីទង្វើដ៏អាក្រក់របស់ជនកាន់អំណាចចាស់ និងស្ថាប័នរបស់ជនទាំងនោះ ។ កសិករនិងកម្មករ ដែលជាអង្គភាពសមូហភាពនឹងត្រូវបន្តការងារកសិកម្មរបស់គ្រួសារ រួមមានការចូលរួមការងារជួយសេដ្ឋកិច្ចគ្រួសារ ។ អត្ថបទក្នុងទស្សនាវដ្តី យុវជនបដិវត្តន៍ជារឿយ បាននិយាយដដែលថា កសិករនិងកម្មករ គឺជាក្រុមដែលអាចអប់រំយុវជនបាន "វណ្ណៈកសិករ និងកម្មករអាចបង្រៀនយុវជនពីរបៀបរស់នៅជាមួយអ្នកដទៃ និងរស់នៅដោយការចែករំលែក" ។ ការចែករំលែកភាពលំបាកគឺជាមធ្យោបាយមួយនៃការរីតចំណងយុវជនទាំងក្នុងចំណោមយុវជនខ្លួនឯងផ្ទាល់ ថែមទាំងប្រជាជនដទៃ ។ កសិករនិងកម្មករត្រូវអប់រំយុវជនពីគោលដៅបដិវត្តន៍ ហើយលើកស្ទួយការឲ្យតម្លៃដល់ជីវិតសមូហភាព ។ កម្មករនិងកសិករត្រូវធ្វើឲ្យប្រាកដថាយុវជន បានចូលរួមអង្គប្រជុំធ្វើស្វ័យទិតៀនខ្លួនឯង ។

ទាំងមេដឹកនាំចិន និងកម្ពុជា បានយល់ឃើញថាយុវជនគឺជាអ្នកកសាងជាតិដែលទាមទារឲ្យមានការចិញ្ចឹមបីបាច់ ។ ដូចម៉ៅ សេទុង បានថ្លែងក្នុងឆ្នាំ១៩៥៣ "ប្រទេសចិនថ្មី ត្រូវតែថែទាំយុវជនរបស់ខ្លួន និងត្រូវបង្ហាញពីការយកចិត្តទុកដាក់ចំពោះការចិញ្ចឹមបីបាច់មនុស្សជំនាន់ក្រោយ ដូច្នេះហើយ ត្រូវតែមានការយកចិត្តទុកដាក់ទាំងការងារ ការសិក្សា ការកម្សាន្ត កីឡា សម្រាប់យុវជន ។

អង្គការចាត់តាំងយុវជននៅប្រទេសកម្ពុជា និងប្រទេសចិន ជាពិសេសសម្ព័ន្ធយុវជនចិន ដែលជាកងស្វ័យត្រាណដ៏សំខាន់បំផុតរបស់ប្រទេសចិនដែលត្រូវបានរំពឹងថា កងស្វ័យត្រាណទាំងនោះនឹងជួយបក្សនិងបណ្តុះបណ្តាលលទ្ធិកុម្មុយនីស្តនៅតាមសាលារៀន ។ ដោយបង្កើតក្នុងឆ្នាំ១៩៦០ សម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យឬសម្ព័ន្ធយុវកក ត្រូវបានពិពណ៌នាក្នុងការឃោសនាថាជាអ្នកប្រកាសច្បាប់ដ៏សកម្មក្លាហាន និងនាំមុខគេ ហើយជាអ្នកអនុវត្តគោលការណ៍ និងមាគ៌ានយោបាយ ។ ការសម្រេចចិត្តត្រូវធ្វើឡើងដោយបក្ស ក្នុងវង្វង់ប្រជាជនកម្ពុជា ដូចជា កម្មករ ពលករ កសិករ និងយុវជនដែលមានវ័យចូលសាលាព្រមទាំងប្រជាជនទូទៅ ។ ពិតប្រាកដណាស់ សម្ព័ន្ធយុវកក បានក្លាយជាដៃស្តាំរបស់បក្ស ។

លក្ខណៈស្របផ្សេងទៀតទៅនឹងគំរូរបស់ប្រទេសចិន គឺថាការឃោសនា និងការអនុវត្តមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិដែលមានការចូលរួមពីយុវជន ។ ឧទាហរណ៍ មេដឹកនាំយុវជនក្នុងប្រទេសចិន បានកេណ្ឌប្រជាជនតាមជនបទ ដើម្បីឲ្យចូលរួមក្នុងចលនាកសិកម្មដ៏អស្ចារ្យមួយក្នុងទសវត្សរ៍៥០ ខណៈដែលការឃោសនារបស់យុវជនកម្ពុជាបានលើកឡើងដដែលពីគំនិតផ្តួចផ្តើមក្នុងការជំរុញឲ្យយុវជនខិតខំធ្វើស្រែដើម្បីបង្កើនផលិតកម្ម ។

ទាំងអង្គការចាត់តាំងយុវជនរបស់ប្រទេសចិន និងអង្គការចាត់តាំងយុវជនរបស់ប្រទេសកម្ពុជា មានសៀវភៅកំណត់ហេតុផ្ទាល់ខ្លួន ។ យុវជនកម្ពុជា ព្រមទាំងសម្ព័ន្ធយុវជនចិនបានអះអាងថា ខ្លួនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពាក់បំប៉នប្រមុខយុវជនអំពីគោលការណ៍កុម្មុយនីស្តដោយបណ្តុះបណ្តាលនិងកែប្រែប្រមុខទាំងនោះឲ្យទៅជាអ្នកស្នងបដិវត្តសម្រាប់សង្គមតាមការស្រមើស្រមៃ ។

ដោយមិនដឹងពីប្រភពនោះ យុវជនកម្ពុជា ជារឿយៗចម្លងទ្រឹស្តីដ៏ល្បីរបស់ ម៉ៅ សេទុង ដែលថា "បម្រើប្រជាជន" ដែលជាបាវចនាសម្រាប់ឲ្យប្រមុខយុវជនគោរពតាម ។

ថ្វីបើមានភាពស្រដៀងគ្នាទៅនឹងមនោគមវិជ្ជាប្រទេសចិន ផ្ទុយទៅវិញ មនោគមវិជ្ជាកសិកម្មក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេសដោយឡែកមួយដែលធ្វើឲ្យមានការខុសគ្នាពីស្ថានភាពនៅប្រទេសចិន ។ ខណៈដែលអ្នកសិក្សាជៀនសូត្រជាច្រើនបានគូសបញ្ជាក់ពីការប្រែប្រួលនៃតម្លៃរបស់ខ្មែរតាមរយៈរបបប៉ុល ពត ដែលធ្វើឲ្យចុះអន់ថយដល់ព្រះពុទ្ធសាសនា ខ្ញុំបង្ហាញថាគោលការនៃមនោគមវិជ្ជាកសិកម្មមួយចំនួនត្រូវបានកែប្រែជាជាងត្រូវបានលុបបំបាត់ចោល ។ ឧទាហរណ៍ វិន័យ និងការគោរពចំពោះឪពុកម្តាយនៅបន្តអនុវត្ត ប៉ុន្តែត្រូវបានប្រែជាការគោរពចំពោះអង្គការ រួមមាន អង្គការចាត់តាំងបក្សខ្មែរក្រហម និងខ្មែរក្រហមផ្ទាល់ ។ ពាក្យកេណ្ឌយុវជន បានបង្កប់អត្ថន័យថា

អង្គការនឹងបង្ហាញពីសេចក្តីស្រឡាញ់ និងសន្តានចិត្តស្មើគ្នាចំពោះយុវជនដែលឪពុកម្តាយមានចំពោះខ្លួន ប៉ុន្តែយុវជនត្រូវបង្ហាញជំនឿមុតមាំ ការគោរព ការគាំទ្រ និងការលះបង់ ចំពោះអង្គការនូវអ្វីដែលខ្លួនមានចំពោះឪពុកម្តាយ និងអ្នកមានគុណដទៃ ។ ការបង្រៀនយុវជន បានពង្រឹងពីគុណធម៌នៃការគោរព និងវិន័យតាមរយៈការលើកឡើងថា យុវជន គួរតែចាត់ទុកខ្លួនឯងថាជាអ្នកបម្រើប្រជាជន មិនមែនជាមេដឹកនាំ ឬជាអ្នកគ្រប់គ្រងប្រជាជនឡើយ ។

គោលការណ៍ការគោរព និងវិន័យរបស់មនោគមវិជ្ជាកសិកម្ម ត្រូវបានអនុវត្តហួសហេតុនៅពេលដែលយុវជនត្រូវបានផ្តល់សិទ្ធិ ដើម្បីសម្លាប់ក្នុងការសម្រេចឲ្យបានសង្គមកសិកម្មតាមការស្រមើស្រមៃ ។ មួយក្នុងចំណោមសីលធម៌១២ប្រការ សម្រាប់យុវជន បានចែងថា «កម្ចាត់ខ្មាំង កម្ចាត់ឧបសគ្គដោយ ភាពក្លាហាន និងហ៊ានលះបង់ចំពោះប្រជាជន កម្មករ កសិករ បក្ស និងបដិវត្តដោយឥតលក្ខខណ្ឌគ្រប់ពេលវេលាទាំងអស់ ។

យោងតាមលោក អាឡិចសាន់ឌ័រ ហីនតុន ខ្មែរក្រហមបានលើកស្ទួយគំរូនៃវប្បធម៌សង្គមនិងប្រកាន់យកទស្សនម៉ាក្សលេនីន ស្តីពី «ការអន់ចិត្ត និងការជំទាស់ចំពោះវណ្ណៈ» ។ ខ្មែរក្រហមបានចម្លងនូវតម្លៃនៃវប្បធម៌ដែលខ្លួនខំបំផ្លាញ ។ ឧទាហរណ៍ ទាំងជំនឿកុម្មុយនីស្ត និងជំនឿខាងព្រះពុទ្ធសាសនា បានចែងថា បុគ្គលិកលក្ខណៈរបស់មនុស្សអាចត្រូវបានកែប្រែ ហើយកសាងឡើងវិញពីចំណុចចាប់ផ្តើមតាមរយៈបក្សកុម្មុយនីស្ត ។ ឧទាហរណ៍ ការឃោសនាក្នុងទស្សនាវដ្តី យុវជនបដិវត្តន៍ បានចែងថា«ប្រមុខក្រុមយុវជនភាគច្រើនក្នុងសម្ព័ន្ធយុវជនគឺស្មោះត្រង់ ក្លាហាន និងមិនញញើតក្នុងការលះបង់សូម្បីតែជីវិតក្នុងការបម្រើបក្ស ។ ប្រមុខក្រុមយុវជន ត្រូវបានបណ្តុះបណ្តាលពីសីលធម៌ទាំង១២ប្រការដូច្នេះហើយ ប្រមុខក្រុមយុវជនទាំងនោះ នឹងក្លាយជាជនបដិវត្តន៍បរិសុទ្ធ ។

ជារឿយៗ របប ប៉ុល ពត ប្រកាន់យកទ្រឹស្តីដែលមាន ១០ចំណុច ឬ៦ចំណុច ដែលជាកត្តាមួយស្របនឹងការបង្រៀនរបស់ព្រះពុទ្ធសាសនា ។ ជាងនេះទៅទៀត វិទ្យុក្រុងភ្នំពេញបានលើកឡើងពីពាក្យស្លោកនៃការបង្រៀនរបស់ព្រះពុទ្ធសាសនាម្តងហើយម្តងទៀត ។ ប៉ុល ពត បានណែនាំរដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ហ៊ូ នឹម ថាអ្នកផ្សាយព័ត៌មានគួរតែឃោសនាឲ្យដូចព្រះសង្ឃដែលដឹកនាំពុទ្ធបរិស័ទនៅវត្ត ។ តាមរយៈការប្រកាន់ភ្ជាប់លក្ខណៈនៃព្រះពុទ្ធសាសនាថេរវាទដែលឆ្លើយតបចំពោះតម្រូវការរបស់ខ្លួននោះ ខ្មែរក្រហមបានបង្ហាញចំណាប់អារម្មណ៍ថា ខ្លួនអាចបញ្ចូលមនោគមវិជ្ជាដល់ប្រជាជនដោយគ្មានការលំបាក ។

ស្រដៀងគ្នានេះដែរ កម្មាភិបាលខ្មែរក្រហម ត្រូវតែអនុវត្តតាមសៀវភៅបញ្ជីរៀបរាប់ពីច្បាប់របស់អង្គការដែលមូលដ្ឋានលើសិក្ខាបទរបស់សង្ឃ ។ ឧទាហរណ៍ ការធ្វើទុក្ខកិរិយាត្រូវបានឆ្លុះបញ្ចាំងក្នុងការថ្កោលទោសកម្មាភិបាលប្រុសដែលចូលចិត្តស្រា កម្មាភិបាលទាំងនោះ ត្រូវហៅថាជា «ជន ប្រមឹក សេ អ៊ីអា» ។ ការដាក់កំហិតបែបនេះ បានបកស្រាយចំពោះកាលដែលថាគឺជាកម្មាភិបាលបដិវត្តន៍ជាជាងព្រះសង្ឃព្រះពុទ្ធសាសនាដែលគួរទទួលបានការគោរពពីគ្រហស្ថ ។

លោក អៀន ហាររីស បានកត់សម្គាល់ថា អំឡុងសម័យខ្មែរក្រហម របបខ្មែរក្រហមបានបង្ហាញពីបំណងក្នុងការគាត់តែងនិងការប្រើនិមិត្តរូបព្រះពុទ្ធសាសនា និងទស្សនៈរបស់ព្រះពុទ្ធសាសនា សូម្បីតែពេលដែលរបបនេះបានប្រឆាំងស្ថាបន័ព្រះពុទ្ធសាសនាហួសហេតុ ។ ឧទាហរណ៍ ពាក្យ «វដ្ត» («វដ្ត» គឺជាដំណើរវិលវល់នៃជីវិតបុគ្គលដែលកំណត់ដោយការកើតចាស់ឈឺស្លាប់) ដែលជានិមិត្តរូបចាស់នៃការបង្រៀនរបស់ព្រះពុទ្ធ និងជាអំណាចរបស់ក្សត្រដែលកាន់ព្រះពុទ្ធសាសនាដ៏ត្រឹមត្រូវបានប្រែក្លាយទៅជា «កង់ប្រវត្តិសាស្ត្រ» ។ «វដ្ត» មិននៅស្ងៀមឡើយ ហើយនឹងបំផ្លាញអ្នកដែលនៅចំពោះមុខ ។ ពាក្យស្លោកបដិវត្តន៍មួយចំនួនត្រូវបានកែខៃចេញពីកាព្យទានដែលបង្រៀនតាមបែបប្រពៃណីស្តីពីសីលធម៌ ដែលជាគំរូសម្រាប់ព្រះសង្ឃក្មេងៗធ្វើការសិក្សារៀនសូត្រអំឡុងការបណ្តុះបណ្តាលរបស់ខ្លួន ។

ក្រៅពីនេះ ទស្សនវិស័យនៃសារសំខាន់របស់កម្ពុជាចំពោះខ្មែរក្រហម កើតចេញពីពេលវេលាមុនបដិវត្តន៍ ។ ដូចរបបមុនអ៊ីចឹង ខ្មែរក្រហមបានសន្មត់ថា ខ្លួនគឺជាកូនចៅរបស់អាណាចក្រអង្គរខ្មែរដ៏អស្ចារ្យ ។ ក្រោយមក យុវជនត្រូវបានជំរុញឲ្យក្លាយជា «មហាកំដែងខាងសតិអារម្មណ៍របស់ប្រទេសចិន» ក្នុងការ

ការពារប្រពៃណីវប្បធម៌ខ្មែរ អក្សរសាស្ត្រ និងបេតិកភណ្ឌជាតិពីការឈ្លានពានរបស់បរទេស ។ ដូចរបប សម្តេចព្រះ នរោត្តម សីហនុ អ៊ីចឹង របបខ្មែរក្រហមមានបំណងចង់ នាំមុខសម័យអង្គរដ៏រុងរឿង ដោយសារសង្គមថ្មីនេះបានវិវឌ្ឍយ៉ាងលឿន និងប្រកបដោយជោគជ័យ ឆ្ពោះទៅរកសហគមន៍កុម្មុយនីស្ត ជាជាងសង្គមកុម្មុយនីស្ត ។

ចុងបញ្ចប់ ដូចជនជាតិកម្ពុជាជំនាន់ក្រោយ ខ្មែរក្រហមជឿថា ជនបរទេស ជាពិសេស ជនជាតិវៀតណាមទទួលខុសត្រូវចំពោះទុក្ខលំបាករបស់ប្រជាជនកម្ពុជា ។ ទស្សនាវដ្តីយុវជន បានលើកឡើងសាជាថ្មីថា "យុវជនគួរតែមានស្មារតីជាតិនិយមក្នុងការប្រយុទ្ធប្រឆាំងជាមួយសត្រូវជាពិសេសវៀតណាម" ។ ដោយឆ្លុះបញ្ចាំងពីការកេណ្ឌយុវជនក្រោមរបបខ្មែរក្រហម ការដាក់លំដាប់ព្រឹត្តិការណ៍ ស្ថានភាពខ្មែរជនបទ ដែលរួមបញ្ចូលទាំងយុទ្ធនាការជំរុញផលិតកម្ម និងកសាងសង្គមថ្មីត្រូវបានបកស្រាយដោយពាក្យ "ទំនើបកម្មប្រតិកិរិយា" ។ ប្រការនេះត្រូវបានភ្ជាប់ទៅនឹងការបរិយាយពីអតីតភាព និងអាណាចក្រអង្គរដ៏អស្ចារ្យដែលបានគ្រប់ដណ្តប់តំបន់អាស៊ីអាគ្នេយ៍ ភាគច្រើនចន្លោះសតវត្សរ៍ទី៩ ដល់សតវត្សរ៍ទី១៤ ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅពាក់កណ្តាលសតវត្សរ៍ទី១២ ការប៉ុនប៉ងរបស់មេដឹកនាំកុម្មុយនីស្តក្នុងការសម្រេចឲ្យបានទស្សនវិស័យតាមការស្រមើស្រមៃ បានកើតឡើងយ៉ាងខ្លាំង ។ ជីវិតមនុស្សពីរលាននាក់ដែលត្រូវជា២១ភាគរយនៃប្រជាជនកម្ពុជា ត្រូវបានស្មានមតិថាបានបាត់បង់ដោយសារតែបដិវត្តន៍ប៉ុល ពត ។ ទស្សនវិស័យនៃទំនើបកម្មប្រតិកិរិយា បានសម្រេចនៅពេលដែលការកេណ្ឌយុវជនប្រែក្លាយទៅជាអំពើប្រល័យពូជសាសន៍ ។ សូម្បីតែបន្ទាប់ពីការបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យទាំងស្រុងក្នុងទសវត្សរ៍៩០ មនុស្សរាប់សិបពាន់នាក់ ជាពិសេស យុវជន នៅតែមានឆន្ទៈលះបង់ជីវិតចំពោះរបបប៉ុល ពត ដែលបានផ្តល់នូវអំណាច និងការគោរពខ្លួនឯង ។ មនុស្សដែលបដិសេធទទួលយកការផ្លាស់ប្តូរ នៅតែបន្តគាំទ្របង្កើតមូលដ្ឋានទ័ពព្រៃ ប៉ុល ពត ក្នុងទសវត្សរ៍៨០ ។

**សេចក្តីសន្និដ្ឋាន**

អត្ថបទនេះ បានស្វែងរកកំណត់ហេតុការណ៍នៃការកេណ្ឌយុវជននៅក្នុងប្រទេសកម្ពុជាចាប់តាំងពីរបបអាណានិគមផ្តាច់ការវិជីអំឡុងសង្គ្រាមលោកលើកទី២រហូតដល់ការដួលរលំបដិវត្តន៍ប៉ុល ពត ក្នុងឆ្នាំ១៩៧៩ តាមរយៈរបប លន់ នល់ និង ប៉ុល ពត ។ ដោយពឹងផ្អែកលើយុវជនក្នុងការបង្រួបបង្រួម និងការពារអំណាចរបស់ខ្លួន រដ្ឋាភិបាលផ្តាច់ការ បានដាក់យុវជនជាផ្នែកសង្គម ។ ការកេណ្ឌយុវជនដែលគាំទ្រដោយរដ្ឋ មានលក្ខណៈទំនើបដែលការកេណ្ឌយុវជននោះ បានដាក់បញ្ចូលទម្រង់គ្រប់គ្រងយុវជនបែបថ្មីដែលមិនស្ថិតក្នុងរង្វង់គ្រួសារ ។ ក្រោមរូបភាពនៃមនោគមវិជ្ជាផ្សេងៗ ដំណើរការកេណ្ឌយុវជន បានឆ្លុះបញ្ចាំងពីការពង្រីកវិសាលភាពនៃការធ្វើផែនការរបស់រដ្ឋនៅក្នុងប្រទេសកម្ពុជា ។

ទោះបីជាយ៉ាងនេះក៏ដោយ ទន្ទឹមនឹងខ្ញុំនិយាយពោលលើកហេតុផលនេះ ខ្ញុំ អះអាងថា មនោគមវិជ្ជាកេណ្ឌយុវជន ត្រូវពឹងផ្អែកលើគោលការណ៍កសិកម្មដែលមានស្រាប់ និងការអនុវត្តដែលមាននៅនឹងកន្លែងចាប់តាំងពីចុងសម័យអាណានិគមដល់របបខ្មែរក្រហម រួមមាន ការរំពឹងទុកចំពោះយុវជនក្នុងការ រួមចំណែកខាងសេដ្ឋកិច្ច ការប្រកាន់ភ្ជាប់គោលការណ៍វិន័យ និងការគោរពចំពោះឥស្សរជនដែលមានអំណាច ។ ការគំរាមកំហែងដល់ជាតិនិងប្រទេស ធ្វើឲ្យមេដឹកនាំប្រើមនោគមវិជ្ជាកសិកម្មជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ចាត់តាំងយុវជន ដូច្នេះហើយមនោគមវិជ្ជាកសិកម្មដ៏មានឥទ្ធិពល បានបង្កើតជំនឿខាងនយោបាយរបស់មេដឹកនាំ និងជំនឿរបស់ប្រមុខយុវជន ចាប់តាំងពីមនោគមវិជ្ជាកសិកម្មបម្រើរដ្ឋរបស់ជនអាណានិគម និងរបបសម្តេចព្រះ នរោត្តម សីហនុ រហូតដល់មនោគមវិជ្ជាកសិកម្មយោធារបស់ លន់ នល់ ហើយចុងបញ្ចប់រហូតដល់ការកេណ្ឌយុវជនក្នុងរបប ប៉ុល ពត តាមរយៈមនោគមវិជ្ជាកសិកម្មបដិវត្តន៍ដែលមានបំណងបង្កើតប្រទេសកសិកម្មតាមការស្រមើស្រមៃ ។

ថ្វីបើរបបផ្សេងមានមនោគមវិជ្ជាខុសគ្នាក៏គោលបំណងក្នុងការដាក់ទណ្ឌកម្ម ការគ្រប់គ្រង និងការធ្វើសមាហរណកម្មយុវជនដែលប្រឈមមុខនឹងការគំរាមកំហែងពីឥទ្ធិពលខាងក្នុង និងក្រៅបានចាត់តាំងយុវជនពីថ្នាក់លើដល់ថ្នាក់ក្រោមចាប់តាំងពីឆ្នាំ១៩៤១ ដល់១៩៧៩ ។

**អាន វ៉ាហ្វីន**

# កុមារភាពភ័យខ្លាច

## បេ តៃសែ រៀបរាប់ពីជីវិតក្នុងរបបខ្មែរក្រហម

បេ តៃសែ ជាអតីតកុមារនៅក្នុងកងចល័តពិសេស ។ គាត់កើតឆ្នាំ១៩៦៨ នៅភូមិត្រពាំង វែង ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ សែ ជាកូនទីប្រាំក្នុងចំណោមបងប្អូនចំនួនប្រាំពីរនាក់ (ប្រុសបួននាក់ ស្រីបីនាក់) ។ គាត់មានឪពុកឈ្មោះ បេ តាប់ (ស្លាប់ឆ្នាំ២០០៧) និងម្តាយឈ្មោះ ហួយ ទៀង ។

មុនឆ្នាំ១៩៧៥ គ្រួសាររបស់ សែ រស់នៅផ្ទះល្វែងខាងជើងផ្សារកំពង់ធំ ដោយឪពុកម្តាយរបស់គាត់ពេលនោះប្រកបរបរលក់ឥវ៉ាន់ចាប់ហួយនៅផ្ទះ ។ អំឡុងពេលនោះ សែ រៀននៅថ្នាក់មត្តេយ្យនៅឡើយ តែគាត់ចាំថាមានគ្រាប់បែកផ្លោងចូលមកក្នុងទីរួមខេត្តញឹកញាប់ណាស់ ដែលធ្វើឲ្យប្រជាពលរដ្ឋមានការភ័យខ្លាចនិងជ្រួលច្របល់ ។ លុះមកដល់ឆ្នាំ១៩៧៥ សែ ឃើញទាហានចូលមកក្នុង



បេ តៃសែ ថតនៅឆ្នាំ១៩៨៤

ខេត្តព្រោងព្រាត ជាមួយសម្លៀកបំពាក់ខោអាវខ្មៅរុំក្បាលក្រមា និងបានប្រកាសឲ្យប្រជាជនចេញពីទីរួមខេត្តមួយរយៈដើម្បីឲ្យអង្គការរៀបចំសណ្តាប់ធ្នាប់ឲ្យស្រួល ដោយមិនឲ្យប្រជាជនយកឥវ៉ាន់ទៅច្រើនទេ ។ ចំណែកមន្ត្រីរាជការទាំងអស់ត្រូវមកចុះឈ្មោះបញ្ជាក់ពីឋានៈ និងតួនាទីដើម្បីឲ្យអង្គការរៀបចំឲ្យចូលធ្វើការតាមកន្លែងដើមវិញ ។ សែ ប្រាប់ថា ពេលនោះទាហានលន់នល់ បានចាញ់នយោបាយរបស់ខ្មែរក្រហម ដោយទម្លាក់អាវុធចុះចូលជាមួយខ្មែរក្រហម ។

គ្រួសាររបស់ សែ ក៏ដូចជាប្រជាជនដទៃទៀត បានរៀបចំឥវ៉ាន់ និងប្រមូលបងប្អូន កូនចៅ ដើម្បីចេញដំណើរទៅកាន់ស្រុកកំណើត ។ ឪពុកម្តាយរបស់ សែ បានដឹកអីវ៉ាន់មួយចំនួនទុកសម្រាប់ហូប និងប្រើប្រាស់រយៈពេលខ្លីប៉ុណ្ណោះព្រោះអង្គការប្រកាសថាឲ្យចេញតែមួយរយៈខ្លី ។ ក្រុមគ្រួសាររបស់ សែ សំដៅទៅទិសខាងត្បូងនៃខេត្តកំពង់ធំ តាមបណ្តោយផ្លូវជាតិលេខ៦ រហូតដល់ស្រុកបារាយណ៍ ដែលមានចម្ងាយ៥០គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ។ មូលហេតុដែលគ្រួសាររបស់ សែ ធ្វើដំណើរទៅស្រុកបារាយណ៍ ព្រោះនៅទីនោះមានបងប្អូនខាងម្តាយគាត់បីគ្រួសារជាអ្នកមូលដ្ឋាន ។ ប៉ុន្តែនៅទីនោះ ក្រុមគ្រួសាររបស់ សែ ត្រូវបានអង្គការរបស់ចាត់ទុកជាអ្នក១៧មេសា ។

ក្រុមគ្រួសាររបស់ សែ បានធ្វើផ្ទះខ្ទមមួយរស់នៅដោយមានការជួយឧបត្ថម្ភពីឪពុកធំ និងម្តាយមីងរបស់គាត់ ។ ពេលនោះអង្គការមិនទាន់ប្រមូលផ្តុំជាសហករណ៍នៅឡើយទេ ចំណែកការហូបចុកនៅតាមគ្រួសារធម្មតា ។ រយៈពេលប្រហែលជាពីរ ឬបីខែក្រោយមក ទើបអង្គការហៅប្រជាជនទាំងអស់មកប្រជុំ និងឲ្យប្រមូលសម្ភារទាំងអស់មកដាក់រួម ហូបចុករួម ធ្វើការរួម និងបង្កើតទៅជាកងចល័ត ដោយគិតតាមកម្លាំង និងតាមវ័យ ។

ឪពុករបស់ សែ ត្រូវអង្គការចាត់តាំងឲ្យដាំបន្លែក្នុងភូមិ ហើយម្តាយគាត់នៅក្នុងកងមនុស្សចាស់ដោយអង្គការតម្រូវឲ្យធ្វើការដកស្ទូង ច្រូតកាត់ បោកបែន និងធ្វើជីលេខមួយដាក់ស្រែ ។ បងប្រុស

ទីមួយរបស់ សែ ត្រូវបានអង្គការឲ្យទៅនេសាទត្រីនៅទន្លេសាប ។ បងស្រីទីពីរ ត្រូវទៅធ្វើការនៅកងចល័តលើកទំនប់១មករា នៅភូមិកំពង់ថ្ម ។ បងស្រីទីបីនៅកងចល័តជំទង់ត្រូវបានអង្គការចាត់តាំងឲ្យទៅកាប់ពោត ប្រូតសណ្តែកសៀងនៅចម្ការលើ ។ បងទីបួន ត្រូវអង្គការបញ្ជូនឲ្យទៅឃ្វាលគោនៅអណ្តូងពោធិ៍ ស្រុកចម្ការលើ ។ ចំពោះ សែ និងប្អូនប្រុសបន្ទាប់ត្រូវបានអង្គការតម្រូវឲ្យនៅកងកុមារក្នុងភូមិដោយឲ្យដើររើសអាចម៍គោ កាប់ដើមទន្រ្ទានខែត្រយកមកធ្វើជី និងឃ្វាលគោ ។ នៅពេលមួយ សែ និងមិត្តរបស់ សែ ត្រូវកូនអ្នកមូលដ្ឋានជេរតិះដៀលថា ពួកនាយទុន ពួកសក្តិភូមិ ជិះជាន់កម្លាំងពលកម្ម និងនិយាយពាក្យប្រមាថជាច្រើនដូជា ទុកមិនចំណេញ ដកចេញក៏មិនខាត ដោយសារតែគាត់ជាកូនអ្នក១៧មេសា ។

នៅដើមឆ្នាំ១៩៧៦ នៅស្រុកបារាយណ៍ អង្គការបានបង្កើតកងកុមារពិសេស ដោយជ្រើសរើសកុមារពេញកម្លាំង ។ ក្នុងមួយភូមិអង្គការជ្រើសយកពីរនាក់ ដើម្បីយកទៅដាំពោត និងសណ្តែកសៀងនៅស្រុកចម្ការលើ ហើយក្នុងភូមិបារាយណ៍អង្គការបានជ្រើសរើស សែ និងកុមារម្នាក់ទៀតឈ្មោះ ប្រុស ។ បន្ទាប់មកអង្គការកំណត់ពេលជួបជុំ និងរៀបចំចេញដំណើរក្រោមការដឹកនាំរបស់ប្រធានកងឈ្មោះសមមិត្ត ឃន ។ ឃន រស់នៅក្នុងភូមិថ្នល់ថ្មីនៅជាប់ភូមិបារាយណ៍ ។

សែ បានរៀបរាប់ពីអារម្មណ៍របស់ខ្លួនក្នុងពេលនោះថា "គាត់មានអារម្មណ៍រន្ធត់ និងឯកោ ព្រោះមិនដែលបែកពីឪពុកម្តាយ" ។ ពេលចេញដំណើរ សែ មានខោអាវតែមួយចង្កេះ និងក្រមាកញ្ចាស់មួយប៉ុណ្ណោះ សូម្បីតែស្បែកជើងក៏គ្មានពាក់ដែរ ។ ដូច្នេះគាត់បានកាត់ស្រទបចេកយកមករុំ ធ្វើជាទ្រនាប់ជើងព្រោះដើរលើថ្នល់ជាតិពេលថ្ងៃក្តៅខ្លាំងពេក ។ ទៅដល់ទីនោះមិត្ត ឃន បានឲ្យកងកុមារទាំងអស់ដែលមានគ្នាប្រហែលជាសែសិបនាក់ ដេកក្នុងរោងសហករណ៍រួមដែលធ្វើហើយជាស្រេចនៅទីនោះ ។ បន្ទាប់មក ឃន ប្រជុំចែកសម្ភារប្រើប្រាស់សម្រាប់ធ្វើការ ដូចជា ខ្វែវ ចបកាប់ជាដើម ។ សែ បន្តថា "ស្អែកឡើងប្រធានកងឲ្យគាត់ និងកុមារផ្សេងទៀតទៅជម្រះស្មៅដើម្បីដាំពោត និងសណ្តែក ។ អង្គការបានវាស់ឲ្យយើងជម្រះស្មៅដោយយកដងចបធ្វើជាខ្នាត ហើយក្នុងមួយព្រឹកត្រូវជម្រះឲ្យបានទទឹងប្រវែងពីរដងចបដែលក្នុងមួយដងចបស្មើនឹង១.២ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ ។ ពេលនោះ សែ តូចជាងគេ ចំណែកអ្នកផ្សេងទៀតដែលជម្រះស្មៅលឿន បានទុកស្មៅឲ្យគាត់ជម្រះកាន់តែច្រើន ។ សែ ជម្រះបណ្តើរយំបណ្តើរ ចំណែកអ្នកផ្សេងទៀតនាំគ្នាអង្គុយមើលគាត់ ព្រមទាំងសើចចំអកទៀតផង ។ រហូតដល់ សែ យំអស់ចិត្ត ទើបក្មេងៗទាំងនោះមកជួយជម្រះស្មៅគាត់ ។ ក្មេងៗនៅក្នុងកងតែងតែធ្វើឲ្យគាត់យំជារៀងរាល់ថ្ងៃ ។

មានថ្ងៃមួយពេល សែ កំពុងខឹង ស្រាប់តែ ប្រុស ដែលមកពីភូមិជាមួយគ្នាបានមកបញ្ចើចបញ្ចើ និងចាក់ចង្កេះគាត់ ។ ពេលនោះ សែ ក៏បានគ្រវាសមួយដងខ្វែវចំក្បាលរបស់ ប្រុស ធ្វើឲ្យហូរឈាម ។ មិត្ត ឃន បានដេញចាប់គាត់ ហើយ ដោយសារភិតភ័យពេក គាត់ក៏រត់ចូលព្រៃ ។ ប៉ុន្តែដោយខ្លាចពាក្យគំរាមថា តែហ៊ានរត់ចូលព្រៃខ្លាចាប់ស៊ីទើបគាត់ឈប់រត់ ។

សែ បានត្រឡប់មកកងវិញ ហើយគាត់ត្រូវបានឈ្លបចាប់ចងស្លាបសេកជាមួយនឹងខ្សែអង្រឹង និងវាយគាត់បែកឈាមពេញខ្លួន ព្រមទាំងគម្រាមថានឹងយកទៅសម្លាប់ចោល ។ ឈ្លបបានយក សែ ទៅឃុំនៅក្នុងជង្រុកស្រូវដោយមិនឲ្យបាយហូប ដែលធ្វើឲ្យគាត់រន្ធត់យ៉ាងខ្លាំង ហើយគិតប្រាកដជាស្លាប់មិនខាន ។ តែសំណាងល្អ កងឈ្លបឃុំឃាំង សែ តែមួយយប់អង្គការក៏ដោះលែងវិញ ដោយឲ្យគាត់និយាយទទួលកំហុសតាមអង្គការប្រាប់ និងឲ្យប្តេជ្ញាចិត្តឈប់ប្រព្រឹត្តកំហុសដូចមុនទៀត ។ សែ បានរំឭកថា "ដោយសារ ប្រុស ទៅអង្វរប្រធានកងកុមារឈ្មោះ ឃន ថាគាត់ (ប្រុស) បានប្រឡែងគ្នាលេង ហើយមុតនឹងខ្វែវដោយខ្លួនឯង ទើបឈ្លបដោះលែងខ្ញុំ បើមិនដូច្នេះទេ ឈ្លបនឹងយកខ្ញុំទៅសម្លាប់ចោលហើយ ។

អង្គការឲ្យ សែ ទៅធ្វើការធម្មតាវិញដោយពេលនោះគាត់មានខោអាវតែមួយចង្កេះប៉ុណ្ណោះ ។ ដូច្នេះយប់ឡើង សែ ត្រូវបោកខោអាវ ដើម្បីស្លៀកនៅពេលព្រឹកវិញ រហូតដល់ខោអាវពុកផុយប៉ះលែងកើតទើបអង្គការចែកឲ្យមួយសម្រាប់ទៀត ។ ជារៀងរាល់ព្រឹកមុននឹងចេញទៅជម្រះស្មៅ សែ ត្រូវដោះខ្វែវមកសម្លៀងឲ្យមុតដើម្បីចាំងស្មៅឲ្យបានលឿន ហើយពេលដាំពោត និងសណ្តែកចប់ ទើបអង្គការបានរំសាយឲ្យត្រឡប់មកភូមិវិញ ។ មកដល់ភូមិ អង្គការឲ្យ សែ ទៅនៅកងកុមារដដែល តែមិនឲ្យរើសអាចម៍គោដូចមុនទេ គឺឲ្យ

គាត់ដកសំណាប ស្ទូងស្រូវ ច្រូតស្រូវ រើសក្ួរស្រូវ លើកកណ្តាប់ដាក់រទេះ និងដើរចាប់កណ្តុរតាមស្រែ ។ កណ្តុរដែល សែ ចាប់បានត្រូវកាត់យកកន្ទុយដើម្បីរាប់ចំនួនតាមផែនការដែលអង្គការដាក់ឲ្យអនុវត្ត ។

នៅទីនោះ សែ ហូបមិនបានឆ្អែតទេដូច្នេះគាត់បានដើររើសខ្យងចាប់កង្កែប ក្តាម គីង្គក់ ថ្លែន ប្រគួយ ចាប់កណ្តុរ មកដុតហូប ហើយមានពេលខ្លះគាត់ហ៊ានលួចពោតដែលអង្គការដឹកតាមរទេះទៀតផង ។ ប៉ុន្តែប្រសិនបើជាអង្គការចាប់បាន គាត់នឹងធ្វើទារុណកម្មធ្ងន់ធ្ងរមិនខាន ។

នៅពេលនោះ ដោយសារតែផ្ទះរបស់ សែ ជាប់នឹងរបងវត្តបារាយណ៍ ដូច្នេះរៀងរាល់ខែ សែ ឃើញមានប្រជាជនជាច្រើនគ្រួសារមកពីគ្រប់ភូមិជញ្ជូនរបស់របរ និងអីវ៉ាន់មកអង្គុយចាំជិះឡាន ព្រោះគណៈឃុំបានស្រង់ឈ្មោះគ្រួសារអ្នក១៧មេសា និងជនជាតិខ្មែរអ៊ីស្លាមឲ្យទៅនៅភូមិថ្មី ។ តាមពិត អង្គការយកគ្រួសារទាំងនោះទៅសម្លាប់ចោល ព្រោះឡានបានដឹកអ្នកទាំងនោះទៅបាត់ពីរ ឬបីថ្ងៃក៏ត្រឡប់យកខោអាវរបស់គេមកចែកឲ្យអ្នកភូមិស្លៀកពាក់វិញ ។ អ្នកភូមិខ្លះឆ្ងល់ក៏សួរគណៈឃុំ តែគណៈឃុំបានកុហកថាអ្នកនៅភូមិថ្មីមិនខ្វះរបស់របរប្រើប្រាស់ទេ ហើយមានសុទ្ធតែរបស់ថ្មី។ សែ នៅចាំថា កាលនោះគណៈតំបន់ឈ្មោះមិត្តនារី ភឿក ចំណែកគណៈឃុំបារាយណ៍ឈ្មោះ តាដួន (ពីមុន តាដួន ធ្លាប់បើកត្រាក់ទ័រឲ្យឪពុកគាត់ ហើយនៅពេលដែលប្រពន្ធ តាដួន ឈឺ ឪពុកគាត់បានផ្តល់លុយកាក់ព្យាបាលរហូតដល់ជាទៀតផង) ។ ដូច្នេះ តាដួន គោរពស្រឡាញ់ឪពុកគាត់ណាស់ មូលហេតុនេះហើយបានជា តាដួន ទុកឲ្យក្រុមគ្រួសាររបស់គាត់ឲ្យនៅរស់រួមជាមួយគ្រួសារខ្មែរអ៊ីស្លាម ធ្វើជាជាងដុំដែកមួយគ្រួសារទៀត ក្រៅពីនោះគ្រួសារអ្នក១៧មេសាស្លាប់ស្ទើរទាំងអស់ ។

នៅពេលដល់រដូវប្រមូលផលពោត យន បានដើរប្រមូលកងកុមារឲ្យទៅចម្ការលើ ដោយបានធ្វើខ្ទមនៅលើដើមឈើ ដើម្បីឲ្យ សែ និងកុមារផ្សេងៗទៀតចាំគោះត្រដោកដេញបង្អើលសត្វសេកដែលចុះមកស៊ីផ្លែពោត ។ កងរបស់ សែ ធ្វើការនៅទីនោះរហូតដល់ឆ្នាំ១៩៧៨ ។ ក្រោយមក អង្គការបានហៅឲ្យ សែ និងកុមារផ្សេងៗឲ្យមកឈរតម្រង់ជួរ និងឲ្យស្ពាយកាំភ្លើង បើកុមារណាស្ពាយកាំភ្លើងមិនផុតពីដីអង្គការឲ្យឈរទៅម្ខាង តែបើស្ពាយផុតពីដីអង្គការបញ្ជូនទៅខេត្តកំពង់ចាម ដើម្បីច្បាំងជាមួយកងទ័ពវៀតណាម ។

ជាភ័ព្វសំណាង សែ ពុំត្រូវបានអង្គការបញ្ជូនទៅសមរភូមិទេ ។ រហូតដល់កងទ័ពវៀតណាមរំដោះបាននៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៩ ។ ក្រោយរបបខ្មែរក្រហមដួលរលំ សែ មិនបានបាត់បង់សមាជិកគ្រួសារម្នាក់ឡើយ ហើយគាត់និងក្រុមគ្រួសារក៏វិលត្រឡប់មករស់នៅក្នុងទីរួមខេត្តកំពង់ធំវិញ ។



បេ តៃសែ (ជួរមុខទីពីរាប់ពីស្តាំ) ថតជាមួយឪពុកម្តាយ និងបងប្អូន ក្នុងនោះមានបងប្រុសពីរនាក់ បងស្រីពីរនាក់ ប្អូនប្រុសម្នាក់ ថតប្រហែលក្នុងខែកុម្ភៈឆ្នាំ១៩៧៥ មុនពេលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។

សែ បានបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យាពីសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងឆ្នាំ១៩៩៦ និងបានរៀបអាពាហ៍ពិពាហ៍ឆ្នាំ១៩៩៦ ។ ប្រពន្ធរបស់ សែ ឈ្មោះ ខូវ ឃីលិញ និងមានកូនពីរនាក់(ប្រុសម្នាក់ និងស្រីម្នាក់) ។ សព្វថ្ងៃនេះ តៃសែ មាននាទីជាប្រធានការិយាល័យសារមន្ទីរនៅខេត្តកំពង់ធំ ។

**នង ចន្ទ័មល្លិកា**

# មរណភាព អៀង សារី និងពាក្យថា «ទុកនៅកំពង់នៅ»

តួនាទីរបស់ អៀង សារី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានលាតត្រដាងតាមរយៈការអានដីកាដំណោះស្រាយទាក់ទងនឹងអង្គហេតុ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗកាលពីថ្ងៃទី១២-១៥ ខែមីនា ឆ្នាំ២០១២ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចខាងក្រោម៖

**តួនាទីជាសមាជិកនៃគណៈអចិន្ត្រៃយ៍**

អៀង សារី គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ដោយយោងទៅលើកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលបានបន្សល់ទុកក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ។ ក្នុងចំណោមកំណត់ហេតុទាំង១៩នៃកិច្ចប្រជុំនោះ មានកំណត់ហេតុ១០ ដែលបញ្ជាក់អំពីវត្តមានរបស់ អៀង សារី ប៉ុន្តែការអះអាងរបស់ ខៀវ សំផន បានបញ្ជាក់ថា វត្តមានរបស់ អៀង សារី អាចមានច្រើនជាងនេះទៅទៀត ។

**តួនាទីជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស**

បើយោងទៅលើសម្តីរបស់ អៀង សារី ផ្ទាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេសនៅខែមេសា ឆ្នាំ១៩៧៦ ។ ក្នុងឋានៈនេះ អៀង សារី មានតួនាទីគ្រប់គ្រងស្ថានទូតនៅបរទេស និងមានតួនាទីគ្រប់គ្រងនៅមន្ទីរប-១ ដែលជាក្រសួងការបរទេសទាំងមូល ។ ក្រៅពីនេះ អៀង សារី ក៏មានតួនាទីជាប្រធានគណៈកម្មការដើម្បីដោះស្រាយបញ្ហាក្នុងការទិញសម្ភារ ធនាគារ និងឃ្លាំងរដ្ឋ ។

**ដំណើរការកាត់ទោស អៀង សារី**

ក្នុងចំណោមជនជាប់ចោទទាំងប្រាំរូបដែលត្រូវបាននាំយកមកកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមានតែជនជាប់ចោទ អៀង សារី ម្នាក់ប៉ុណ្ណោះដែលត្រូវបាននាំយកមកកាត់ទោសចំនួនពីរដង គឺម្តងនៅតុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិតេយ្យ និងម្តងទៀតនៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលបច្ចុប្បន្ន ។

**តុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩**

តុលាការប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៩ ក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ តុលាការនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើការកាត់ទោសមេដឹកនាំ ប៉ុល ពត និង អៀង សារី ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលមានរយៈពេលប្រាំថ្ងៃតែប៉ុណ្ណោះ ហើយត្រូវបានតុលាការផ្តន្ទាទោសប្រហារជីវិតដោយកំបាំងមុខ និងរឹបអូសយកទ្រព្យសម្បត្តិទៀតផង ។

**ការលើកលែងទោស អនុគ្រោះទោស និងគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ**

កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ ព្រះបាទនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្តលេខាលើអនុក្រឹត្យស្តីពីការលើកលែងទោស អៀង សារី ចំពោះទោសដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយតុលាការប្រជាជនបដិវត្តន៍កាលពីខែសីហា ឆ្នាំ១៩៧៩ និងអនុគ្រោះទោសដែលបានកំណត់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ដោយព្រះរាជក្រមលេខ០១.នស.៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ ជាថ្នូរនឹងការបញ្ចប់សង្គ្រាម និងសន្តិភាព ។

**នីតិវិធីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិកាលដែលចុះហត្ថលេខាក្នុងឆ្នាំ២០០៣ ហើយតុលាការនេះបានចាប់ផ្តើមដំណើរការជាផ្លូវការនៅឆ្នាំ២០០៦ ។ ជនជាប់ចោទដែលត្រូវបាននាំយកមកកាត់ទោសមានចំនួន៥រូប រួមមាន នួន ជា, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ។

អៀង សារី ត្រូវបានតុលាការចាប់ខ្លួនមកឃុំឃាំងនៅមន្ទីរ

ឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ២០០៧ ។ នៅក្នុងរយៈពេលបួនឆ្នាំនៅមន្ទីរឃុំឃាំង អៀង សារី បានដាក់ពាក្យបណ្តឹងស្នើសុំនៅក្រៅឃុំជាច្រើនលើកច្រើនសា ប៉ុន្តែសំណើទាំងអស់នោះត្រូវបានអង្គបុរេជំនុំជម្រះបដិសេធចោល ។ បន្ទាប់មក អៀង សារី ត្រូវបានចោទប្រកាន់តាមរយៈដីកាដំណោះស្រាយចំពោះបទល្មើសមួយចំនួនដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាអន្តរជាតិទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។

រាល់ការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ត្រូវបាន អៀង សារី បដិសេធ ដោយអះអាងថា ខ្លួនត្រូវបានអតីតព្រះមហាក្សត្រផ្តល់ការលើកលែងទោសរួចហើយ តាមរយៈអនុក្រឹត្យឆ្នាំ១៩៩៦ ។ បញ្ហានេះត្រូវបានលើកយកមកពិភាក្សាដេញដោលក្នុងសវនាការបឋមកាលពីថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ២០១១ ។ នៅក្នុងសវនាការនោះ សហមេធាវីការពារក្តី អៀង សារី បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងលើកលែងការចោទប្រកាន់ចំពោះ អៀង សារី ដោយផ្អែកទៅលើអនុក្រឹត្យលើកលែងទោសរបស់អតីតព្រះមហាក្សត្រឆ្នាំ១៩៩៦ និងការអនុវត្តគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ ។

ការអះអាងរបស់សហមេធាវីការពារក្តីនៅក្នុងអំឡុងពេលនៃសវនាការបឋម សហមេធាវីបានលើកឡើងនូវអំណះអំណាងមួយចំនួនថា អនុក្រឹត្យលើកលែងទោសដល់ អៀង សារី ពិតជាមានសុពលភាពដោយសារតែព្រះរាជក្រឹត្យនេះគឺជាលក្ខខណ្ឌមួយដែលធ្វើឲ្យ អៀង សារី ព្រមធ្វើសមាហរណកម្មដើម្បីបញ្ចប់សង្គ្រាម និងចុះចូលជាមួយរដ្ឋាភិបាល ។ ម្យ៉ាងទៀត សហមេធាវីការពារក្តីបានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យតែទៅលើអានុភាពនៃអនុក្រឹត្យពុំមែនសុពលភាពនៃអនុក្រឹត្យឡើយ ។ សមត្ថកិច្ចក្នុងការត្រួតពិនិត្យសុពលភាពនៃអនុក្រឹត្យ គឺមានតែក្រុមប្រឹក្សាធម្មនុញ្ញតែប៉ុណ្ណោះ ។ ដូច្នេះ អនុក្រឹត្យស្តីពីការលើកលែងទោស អៀង សារី នៅតែមានសុពលភាពនៅឡើយ ។

ចំណែកការអនុវត្តគោលការណ៍មិនកាត់ទោសពីរដងលើអង្គហេតុតែមួយវិញ សហមេធាវីការពារក្តី អៀង សារី បានផ្តល់អំណះអំណាងបួនចំណុចដូចខាងក្រោម ៖

◆ អៀង សារី មិនអាចត្រូវបាននាំយកមកកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឡើយ ដោយសារតែ អៀង សារី ត្រូវបានកាត់ទោសម្តងរួចទៅហើយ ។ សហមេធាវីបានលើកយកគោលការណ៍អាជ្ញាអស់ជំនុំដែលមានចែងនៅក្នុងមាត្រា៧ និងមាត្រា១២នៃក្រម នីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ថា មាត្រានេះមានអានុភាពទាំងទៅលើបុគ្គលដែលតុលាការសម្រេចដោះលែង និងបុគ្គលដែលត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពរថែមទៀតផង ។ ដូច្នេះ អៀង សារី មិនត្រូវនាំយកមកកាត់ទោសម្តងទៀតឡើយ ។

◆ ដោយយោងទៅលើមាត្រា១៤(៧) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលចែងថា "គ្មានជនណាម្នាក់ត្រូវបាននាំយកមកចោទប្រកាន់ ឬផ្តន្ទាទោសសាជាថ្មីចំពោះបទល្មើសដែលត្រូវបានផ្តន្ទាទោសជាស្ថាពរ ឬមានការលើកលែងទោសតាមច្បាប់ និងនីតិវិធីក្រមព្រហ្មទណ្ឌនៃរដ្ឋនីមួយៗរួចហើយ" ។ ដូច្នេះ ការចោទប្រកាន់ អៀង សារី មិនអាចត្រូវបានអនុវត្តសាជាថ្មីទេ ។

◆ តុលាការដែលបានបង្កើតនៅឆ្នាំ១៩៧៩ និងតុលាការដែលកំពុងកាត់ទោស អៀង សារី សព្វថ្ងៃគឺជាតុលាការរបស់កម្ពុជា ដូច្នេះតុលាការកម្ពុជាពីរមិនអាចកាត់ទោសលើបទល្មើសតែមួយបានទេ ។ ម្យ៉ាងទៀត ទោះបីជាតុលាការឆ្នាំ១៩៧៩ត្រូវបានបង្កើតដោយក្រឹត្យច្បាប់ ក៏នេះមិនមែនជាឧបសគ្គក្នុងការរារាំងសមត្ថកិច្ចរបស់តុលាការលើបទល្មើសនោះបានឡើយ ។

◆ ចំណុចចុងក្រោយ គឺធាតុផ្សំនៃបទល្មើសនៃបទប្រល័យពូជសាសន៍ដែលបានជំនុំជម្រះនៅឆ្នាំ១៩៧៩ មានលក្ខណៈស្ទើរតែដូចគ្នាទាំងស្រុងនឹងបទល្មើសដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បើទោះបីជាមានការលើកឡើងពីសំណាក់សហមេធាវីជនជាប់ចោទ ដូចបានលើកឡើងនៅក្នុងចំណុចខាងលើនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធរាល់ការលើកឡើងរបស់សហមេធាវីការពារក្តី និងប្រកាសមិនធ្វើការដោះស្រាយលើការលើកលែងទោសដោយព្រះរាជក្រឹត្យឆ្នាំ១៩៩៦ ចំពោះបទល្មើសតាមច្បាប់ជាតិក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីថ្ងៃទី២២

ខែកញ្ញា ឆ្នាំ២០១១ ដែលបញ្ជាក់ថា បទល្មើសតាមច្បាប់ជាតិពុំមានមូលដ្ឋានសម្រាប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ០០២នោះឡើយ ។ ការសម្រេចសេចក្តីនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ហេតុផលដូចខាងក្រោម ៖

ចំពោះការលើកលែងទោស និងអនុគ្រោះទោស អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា ព្រះរាជក្រឹត្យឆ្នាំ១៩៩៦ដែលជាចំណុចសារវន្តនាំឲ្យមានការលើកលែងទោសចំពោះ អៀង សារី ដែលត្រូវបានផ្តន្ទាទោសដោយតុលាការឆ្នាំ១៩៧៩និងទោសដែលមានចែងនៅក្នុងច្បាប់ឆ្នាំ១៩៩៤នាំឲ្យមានមន្ទិលផ្នែកច្បាប់មួយចំនួននៃសេចក្តីសម្រេចរបស់តុលាការឆ្នាំ១៩៧៩ការអនុវត្តទោសនិងការលើកលែងទោស ការអនុគ្រោះទោសដែលមានចែងនៅក្នុងច្បាប់ឆ្នាំ១៩៩៤និងសិទ្ធិអំណាចរបស់ព្រះមហាក្សត្រក្នុងការអនុគ្រោះទោសដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនពុំមានតួនាទីសម្រេចលើសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ និងសុពលភាពរបស់ព្រះរាជក្រឹត្យដោយសារតែសេចក្តីសម្រេចលើករណីនេះគឺជាបុព្វសិទ្ធិរបស់ក្រុមប្រឹក្សាធម្មនុញ្ញតែប៉ុណ្ណោះ ។ ចំណុចចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របតាមសំអាងហេតុរបស់អង្គបុរេជំនុំជម្រះថា សវនាការរបស់តុលាការឆ្នាំ១៩៧៩ពុំបានប្រព្រឹត្តទៅដោយឯករាជ្យ និងត្រឹមត្រូវតាមនីតិវិធីច្បាប់ទេ ។ ករណីនេះ អង្គជំនុំជម្រះលើកអំណះអំណាងថា នៅក្នុងច្បាប់របស់កម្ពុជា ចំពោះសាលក្រមកំបាំងមុខ គឺអៀង សារី មានសិទ្ធិប្តឹងទាស់ឲ្យតុលាការបើកការជំនុំជម្រះសាជាថ្មីដោយមានវត្តមានខ្លួន ប៉ុន្តែកន្លងមក អៀង សារី ពុំដែលបានអនុវត្តសិទ្ធិនេះហើយក៏ពុំបានបោះបង់សិទ្ធិនេះដែរ ។ ដូច្នេះសេចក្តីសម្រេចរបស់តុលាការឆ្នាំ១៩៧៩គ្មានអានុភាពគត្តិយុត្តិនោះឡើយ ។

ឆ្លើយតបនឹងគោលការណ៍គ្មានការកាត់ទោសពីរដងលើអង្គហេតុតែមួយដែលលើកឡើងដោយសហមេធាវីការពារក្តីវិញ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ហេតុផល៥ចំណុចគឺ ៖

១) ដោយផ្អែកលើអំណះអំណាងរបស់អង្គបុរេជំនុំជម្រះថា ការអនុវត្តគោលការណ៍នេះតាមបទដ្ឋានអន្តរជាតិដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយគឺមានអានុភាពតែទៅលើតុលាការជាតិតែប៉ុណ្ណោះដោយពុំមានអានុភាពលើការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។

២) បន្ថែមលើការអះអាងនេះ អង្គជំនុំជម្រះបានពន្យល់ថា ការអនុវត្តគោលការណ៍មិនកាត់ទោសពីរដងចំពោះបទល្មើសតែមួយនេះនឹងអាចយកមកអនុវត្តនៅក្នុងតុលាការអន្តរជាតិបាន លុះត្រាតែការកាត់សេចក្តីនៅក្នុងតុលាការជាតិបានប្រព្រឹត្តទៅដោយត្រឹមត្រូវ ។

៣) អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងអំពីការអនុវត្តគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយនៅក្នុងស្ថាប័នសិទ្ធិមនុស្សអន្តរជាតិថាគោលការណ៍នេះមិនមែនជាគោលការណ៍ដាច់ខាតឡើយ ហើយរដ្ឋពុំអាចប្រើប្រាស់គោលការណ៍នេះចំពោះសំណុំរឿងដែលជនជាប់ចោទត្រូវបានលើកលែងការចោទប្រកាន់ ដោយរំលោភលើច្បាប់អន្តរជាតិនោះឡើយ និងឲ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវខណៈពេលដែលនីតិវិធីបានប្រព្រឹត្តដោយមិនឯករាជ្យនោះឡើយ ។

៤) អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា អៀង សារី បានបដិសេធមិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអង្គហេតុដែលត្រូវបានវិនិច្ឆ័យទោសកាលពីឆ្នាំ១៩៧៩ ដោយបានព្យាយាមលើកយកអនុក្រឹត្យលើកលែងទោសនៅឆ្នាំ១៩៩៦មកធ្វើជាសម្អាង ។

៥) អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ថាតើបទល្មើសឧក្រិដ្ឋណា មួយដែលត្រូវដកចេញពីវិសាលភាពនៃព្រះរាជក្រឹត្យលើកលែងទោស ។

### ក) សេចក្តីថ្លែងការណ៍របស់ អៀង សារី ក្នុងអំឡុងពេលសវនាការ

សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទនៅពេលសវនាការគឺសំដៅទៅលើពាក្យពេចន៍ដែលបានអះអាងឡើងដោយជនជាប់ចោទដើម្បីតវ៉ាឬធ្វើការបញ្ជាក់ទៅលើចំណុចទាំងឡាយណាដែលលើកឡើងដោយភាគី ។ ក្នុងកិច្ចដំណើរការសវនាការកន្លងមក មេដឹកនាំខ្មែរក្រហមបានបដិសេធចំពោះការចោទប្រកាន់ទាំងឡាយ

ណាប្រឆាំងនឹងរូបខ្លួន ព្រមទាំងបដិសេធមិនព្រមធ្វើការឆ្លើយតបនឹងសំណួររបស់ភាគីតាមរយៈការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ សិទ្ធិនេះត្រូវបានអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងគោលបំណងធានាឲ្យបាននូវការជម្រះក្តីដោយយុត្តិធម៌ ។ រហូតមកដល់ពេលនេះ អៀង សារី បានធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួនចំនួនពីរលើកតែប៉ុណ្ណោះនៅចំពោះមុខអង្គជំនុំជម្រះដោយបានបញ្ជាក់នូវគោលជំហររបស់ខ្លួនក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ។

កាលពីថ្ងៃទី២១-២៣ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២ ដែលទាក់ទងនឹងសេចក្តីសន្និដ្ឋានដោយសង្ខេបរបស់សហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ជនជាប់ចោទទាំង៤រូប រួមមាន នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ។ នៅក្នុងឱកាសនោះ អៀង សារី បានស្នើសុំធ្វើសេចក្តីថ្លែងរបស់ខ្លួនដូចខាងក្រោម ៖

*«....នៅឆ្នាំ១៩៩៦ ខ្ញុំបានទទួលការលើកលែងទោសនិងអនុគ្រោះទោស ។ សហរដ្ឋមន្ត្រីទាំងពីរនៅពេលនោះបានចរចាអំពីអនុក្រឹត្យស្តីពីការលើកលែងទោស និងអនុគ្រោះទោស ហើយក៏បានអនុម័តនៅក្នុងរដ្ឋសភាជាតិទៅលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស រួចហើយអតីតព្រះមហាក្សត្រនៅពេលនោះក៏បានចុះហត្ថលេខាយល់ព្រម...ដោយផ្អែកលើយុត្តាធិការនៃតុលាការពិសេសនេះ លោក លោកស្រីចៅក្រមបានសម្រេចថាព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនោះមិនអាចយកមកអនុគ្រោះបានឡើយ ។*

*ថ្វីត្បិតខ្ញុំមិនយល់ព្រមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្តី ខ្ញុំក៏នៅតែគោរពដល់អំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចអំពីរឿងនេះជាមួយនឹងសេចក្តីសម្រេចដ៏ជ្រាលជ្រៅនេះ ខ្ញុំបាទក៏មានសេចក្តីអំពល់កង្វល់បារម្ភជាខ្លាំងដែរ ដោយសារថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងមិនយល់ព្រមបន្តនំដំណើរការនីតិវិធីរហូតដល់មានការសម្រេចពីបញ្ហានេះ ដោយអង្គជំនុំជម្រះតុលាការកំពូលរួចសិន ។*

*ខ្ញុំបាទមិនអាចមិនគោរពសេចក្តីសម្រេចនេះបានឡើយជាពិសេសដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងគួរតែអាចបានចេញសេចក្តីសម្រេចរបស់ខ្លួនតាំងពីយូរណាស់មកហើយ គ្មានអ្វីរារាំងលោកចៅក្រមមិនឲ្យសម្រេចដូច្នេះឡើយ ។ ខ្ញុំជាប់ឃុំអស់រយៈពេល៤ឆ្នាំហើយ រង់ចាំការជំនុំជម្រះ ។ ចាប់ពីនេះតទៅវានឹងចាប់ផ្តើមជាមួយនឹងបញ្ហាច្បាប់ដែលមានសារសំខាន់មួយដែលវាមិនទាន់ត្រូវបានដោះស្រាយពេញលេញនៅឡើយ ។ ដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានចាត់ការដោយត្រឹមត្រូវខ្ញុំយល់ឃើញថា ខ្ញុំបាទមិនគួរចូលរួមក្នុងការជំនុំជម្រះក្តីនេះទេ ដោយគួររង់ចាំរហូតដល់អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះសិន ។ ប៉ុន្តែដោយសារសេចក្តីគោរពទៅលើស្ថាប័ននេះ ខ្ញុំបាននឹងបន្តចូលរួមក្នុងដំណើរការនីតិវិធីនេះដូចដែលខ្ញុំបាទតែងតែបាននិងកំពុងធ្វើ ។ ដូច្នេះ ចាប់តាំងពីកាលដែលខ្ញុំបាទបានរងការចោទប្រកាន់ត្រូវបានចាប់ខ្លួននិងត្រូវបាននាំខ្លួនមកកាន់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក នេះម្ល៉េះ ។*

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ។ ហត្ថលេខា អៀង សារី ។ អស់ហើយខ្ញុំ» ។*

នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការសួរដេញដោលនិងពិនិត្យភស្តុតាងដោយសាកសួរជនជាប់ចោទអំពីប្រវត្តិបក្សកុម្មុយនិស្តកម្ពុជានិងសាវតារជនជាប់ចោទ ។ ក្នុងដំណើរការសវនាការនេះ អៀង សារី បានបដិសេធមិនឆ្លើយតបនឹងសំណួររបស់ភាគីដោយបញ្ជាក់នូវគោលជំហររបស់ខ្លួនដូចតទៅ ៖

*«លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រមទាំងអស់ ។ ខ្ញុំបាទសូមប្រើប្រាស់សិទ្ធិរបស់ខ្ញុំក្នុងរដ្ឋធម្មនុញ្ញដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរទាំងឡាយនាពេលនេះ ។ សិទ្ធិនេះមានចែងនៅក្នុងមាត្រា៣១និង៣៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំបាទមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូលហើយមិនមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយ» ។*

### ១) សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹង អៀង សារី

ចាប់ពីពេលដំណើរការសវនាការលើសំណុំរឿង០០២ នៅខែវិច្ឆិកា ឆ្នាំ២០១១កន្លងមកអង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាច្រើននាក់មកធ្វើសក្ខីកម្មទាក់ទងនឹងអង្គហេតុការណ៍កកើតនៃបក្សកុម្មុយនីស្តកម្ពុជារចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធយោធា និងតួនាទីរបស់ជនជាប់ចោទ ។ ក្នុងការសាកសួរនោះបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលបានបញ្ជាក់ថា អៀង សារី បានអប់រំឲ្យប្រជាជនខំធ្វើការនៅពេលខ្លួនមាននាទីជាគណៈភូមិភាគឦសាន ។

ចំណែកសាក្សីដែលត្រូវបានកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកន្លងមក បានបញ្ជាក់យ៉ាងច្បាស់ថា អៀង សារី ពិតជាមានតួនាទីខ្ពស់ក្នុងការដឹកនាំមន្ទីរប-១ ឬក្រសួងការបរទេសក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសដែលក្នុងនោះ មានសាក្សី ឌុច ជាអតីតប្រធានមន្ទីរស-២១មួយរូបដែរ ។

## ក) ការផ្អាកសវនាការដោយសារបញ្ហាសុខភាពរបស់ អៀង សារី

ស្ថិតក្នុងវ័យ៨៧ឆ្នាំ អៀង សារី បានប្រឈមមុខនឹងបញ្ហាសុខភាពធ្ងន់ធ្ងរជាច្រើនលើកច្រើនសាដែលបណ្តាលឲ្យអង្គជំនុំជម្រះសម្រេចផ្អាកកិច្ចដំណើរការសវនាការជាញឹកញាប់ដោយសារតែជនជាប់ចោទមិនព្រមលះបង់សិទ្ធិក្នុងការចូលរួមសវនាការសាកសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីកន្លងមក ។ ការសម្រេចពន្យារពេលសវនាការរបស់អង្គជំនុំជម្រះត្រូវបានធ្វើឡើងដោយយោងទៅលើវិធាន៨១(២) នៃវិធានផ្ទៃក្នុងរបស់តុលាការដែលចែងថា "ប្រសិនបើជនជាប់ចោទដែលស្ថិតនៅក្រោឃុំដែលរៀបចំដោយអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាសម្រេចពន្យារពេលសវនាការជាបណ្តោះអាសន្ន ហើយចេញដីការបង្គាប់ឲ្យនាំខ្លួន ឬដីការបង្គាប់ឲ្យចាប់ខ្លួនតាមករណីស្របច្បាប់ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ ។ អង្គជំនុំជម្រះត្រូវកំណត់កាលបរិច្ឆេទសវនាការជាថ្មី ។ ជនជាប់ចោទត្រូវនាំមកកាន់មន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញរហូតដល់ពេលជនជាប់ចោទរូបនោះត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើការឃុំខ្លួនជនជាប់ចោទនោះស្របតាមវិធាន៦៣" ។

ការផ្អាកកិច្ចដំណើរការសវនាការដោយសារបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី បានចាប់ផ្តើមដំបូងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដោយអង្គជំនុំជម្រះបានសម្រេចលើកពេលបើកសវនាការនៅថ្ងៃទី២១ ខែឧសភាវិញ ។ ដោយសារតែបញ្ហាសុខភាពជនជាប់ចោទនៅតែបន្តអង្គជំនុំជម្រះបានសម្រេចផ្អាកសវនាការម្តងទៀត ដោយកំណត់យកថ្ងៃទី២៣ ខែឧសភាដើម្បីកោះអញ្ជើញវេជ្ជបណ្ឌិតលឹម ស៊ីវុត្ថា មកធ្វើការសួរដេញដោល ។ តាមរយៈរបាយការណ៍របស់វេជ្ជបណ្ឌិតបានបង្ហាញថា ជនជាប់ចោទមានជំងឺរលាកទងសួតខណៈពេលដែលជនជាប់ចោទប្រឈមមុខនឹងជំងឺបេះដូង និងសរសៃឈាម ។

បន្ទាប់មកទៀត នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រហូតមកដល់ថ្ងៃទី២១ ខែកញ្ញា អង្គជំនុំជម្រះបានបន្តសវនាការដោយកោះហៅវេជ្ជបណ្ឌិតពីររូប គឺវេជ្ជបណ្ឌិត លឹម ស៊ីវុត្ថា និងវេជ្ជបណ្ឌិត គី ប៊ូស្វ ដែលបម្រើការងារនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតដើម្បីមកសួរដេញដោលទាក់ទងនឹងស្ថានភាពសុខភាពរបស់ អៀង សារី ។ តាមរយៈសក្ខីកម្មរបស់វេជ្ជបណ្ឌិតទាំងពីររូបបានបង្ហាញថា ជនជាប់ចោទស្ថិតក្នុងស្ថានភាពហត់ និងវិលមុខដោយសារជំងឺខ្សោយបេះដូងនិងស្ថានភាពមួយទៀតដែលបណ្តាលឲ្យជនជាប់ចោទវិលមុខដោយសារសរសៃឈាមកៀបនឹងឆ្អឹងកងកដែលធ្វើឲ្យឈាមមិនអាចរត់ទៅចញ្ចឹមខួរក្បាលបានគ្រប់គ្រាន់ ។

កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់សាស្ត្រាចារ្យ ចន ខាំប៉ែល អំពីបញ្ហាសុខភាពរបស់ អៀង សារី បន្ទាប់ពីជនជាប់ចោទបានសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេលជិតពីរខែរួចមក ។ នៅក្នុងការសួរដោញដោលនោះ សាស្ត្រាចារ្យ ខាំប៉ែល បានបញ្ជាក់ថា ស្ថានភាពរាងកាយរបស់ជនជាប់ចោទគឺគ្រាន់តែមានការចុះខ្សោយសាច់ដុំដោយសារមិនមានការធ្វើលំហាត់ប្រាណអស់រយៈពេលយូរ ។ ម្យ៉ាងទៀតអាការៈវិលមុខដែលតែងតែកើតមានគឺបណ្តាលមកពីបញ្ហាបេះដូង និងសរសៃឈាម ។ ចំណែក

របាយការណ៍ទាក់ទងនឹងសុខភាពបញ្ញាស្មារតីវិញ បានបង្ហាញឲ្យឃើញថា ការចងចាំរបស់ជនជាប់ចោទមិនមានសភាពប្រែប្រួលទេ គឺជនជាប់ចោទអាចផ្ដល់អារម្មណ៍និងមានការចងចាំបានល្អដែលអាចឲ្យជនជាប់ចោទមានលទ្ធភាពចូលរួមសវនាការបាន។

នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសបន្តបើកសវនាការសួរដេញដោលសាក្សីជំនាញគឺលោក ហ្វីលីព ហ្សុត និងអ្នកជំនាញ អេលីហ្សាបែត ប៉ែកឃើ។ ខណៈពេលដែលសវនាការនេះទើបតែបានចាប់ផ្ដើមដំណើរការជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយសារស្ថានភាពសុខភាពមានការប្រែប្រួល។ ដូច្នេះ អង្គជំនុំជម្រះបានសម្រេចផ្អាកកិច្ចដំណើរការសវនាការសាកសួរអ្នកជំនាញទាំងពីររូបភ្លាមនិងរង់ចាំឲ្យមានការចេញសេចក្ដីសម្រេចថ្មីមួយរបស់អង្គជំនុំជម្រះស្ដីអំពីការបំបែកសំណុំរឿង០០២មុនពេលសវនាការត្រូវបានបន្ត។

### ឃ) ផលប៉ះពាល់ក្រោយពេលមរណភាពរបស់ អៀង សារី

មរណភាពរបស់ អៀង សារី នៅពេលនេះ បានធ្វើឲ្យនីតិវិធីចោទប្រកាន់របស់តុលាការប្រឆាំងនឹង អៀង សារី ត្រូវបានបញ្ចប់ទាំងស្រុង ដោយយោងតាមមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧។

តាមរយៈអត្ថន័យនៃមាត្រានេះមានន័យថា រាល់បទចោទប្រកាន់ទៅលើ អៀង សារី នឹងមិនអាចបន្តទៅមុខទៀតបានហើយរាល់ភស្តុតាង និងសាក្សីនានាដែលនឹងត្រូវយកមកបង្ហាញនិងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះប្រឆាំងនឹង អៀង សារី ត្រូវបានបញ្ចប់។ ដូច្នេះ សេចក្ដីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២ដែលត្រូវកំណត់ថាតើ អៀង សារី មានទោសឬមិនមាននោះក៏មិនអាចធ្វើទៅបានដែរ។

មរណភាពរបស់ អៀង សារី បានបង្ហាញឲ្យឃើញថាដំណើរការស្វែងរកការពិតមួយប្រជាជនកម្ពុជាគ្រប់រូបបានទន្ទឹងរង់ចាំនិងស្វែងរកអស់រយៈពេល៣៤ឆ្នាំកន្លងមកនេះ នៅតែមិនអាចបង្ហាញចេញមកក្រៅតាមរយៈសម្ដីផ្ទាល់របស់ អៀង សារី និងការសួរដេញដោលសាក្សីជាច្រើនរូបទៀត នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ដូច្នេះ ភស្តុតាងជាច្រើនទៀតនៅក្នុងសំណុំរឿង០០២ ជាពិសេសភស្តុតាងសំខាន់ៗដែលបង្ហាញអំពីតួនាទីរបស់ អៀង សារី ជាសមាជិកនៃគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជានិងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ ការពិតមួយនេះ គឺជាចំណុចសារវន្តដែលអាចឲ្យតុលាការវិនិច្ឆ័យទោសចំពោះ អៀង សារី ហើយក៏ជាការពិតដែលនៅពីក្រោយការធ្វើទំនាក់ទំនងនយោបាយការបរទេស ការចាប់ខ្លួន និងសម្លាប់បញ្ញវន្តទាំងនៅក្នុងនិងក្រៅប្រទេសជាច្រើននាក់ក្រោមការដឹកនាំរបស់មេដឹកនាំខ្មែរក្រហមក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

មរណភាពរបស់ អៀង សារី មិនត្រឹមតែជាការបាត់បង់ការពិតដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះទេ ប៉ុន្តែការខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជាកន្លងក្នុងការស្នើសុំនិងចូលរួមគាំទ្រឲ្យមានការថ្កោលទោសមេដឹកនាំខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌ដល់អ្នកដែលបានបាត់បង់ជីវិតនឹងនៅតែពុំទទួលបានយុត្តិធម៌។

ការបាត់បង់ អៀង សារី គឺជាការបាត់បង់បុគ្គលម្នាក់ក្នុងចំណោមមេដឹកនាំខ្មែរក្រហមបីនាក់នៅក្នុងសំណុំរឿង០០២ដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្រោមការគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត នេះគឺជាការបាត់បង់បុគ្គលដែលអាចទទួលខុសត្រូវចំពោះការសម្លាប់បញ្ញវន្តជាច្រើននាក់ដែលមានឆន្ទៈចូលរួមបម្រើប្រទេសជាតិរបស់ខ្លួន។

ជាវិបាក បញ្ហាទាក់ទងនឹងការពិត យុត្តិធម៌ ការផ្សះផ្សា ការទទួលខុសត្រូវ និងប្រវត្តិសាស្ត្រត្រូវបានធ្វើឲ្យខកខាន និងបាត់បង់ទៅតាមរយៈមរណភាពខាងលើ ក៏ប៉ុន្តែមរណភាពនេះបន្សល់ទុកនូវការពិចារណាលើពាក្យចាស់បុរាណដែលពោលថា "ទូកទៅកំពង់នៅ"។



**ឆាយ ឈុនលី**

# សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងសំណុំរឿង០០៣

ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ពីការិយាល័យសហព្រះរាជអាជ្ញា នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ។

## សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតជាតិ

សហចៅក្រមស៊ើបអង្កេតជាតិសូមគូសបញ្ជាក់ថា៖

◆ បន្ទាប់ពីការជូនដំណឹងអំពីការបិទការស៊ើបសួរតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ *Siegfried Blunk* ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១

◆ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍នៅចំពោះអង្គបុរេជំនុំជម្រះត្រូវបានសម្រេចរួចរាល់នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ និង

◆ បន្ទាប់ពីការមកដល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ *Mark B.Harmon* (ដែលជាសហចៅក្រមអន្តរជាតិដែលមាននីតិសម្បទាគ្រប់គ្រាន់)

សហចៅក្រមអន្តរជាតិ ដោយបានធ្វើកំណត់ហេតុខ្វែងយោបល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ បានបញ្ជូនដីកាពិនិត្យមូលទៅការិយាល័យសហព្រះរាជអាជ្ញាដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ (៤) នៃវិធានផ្ទៃក្នុង ។

នាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិបន្ទាប់ពីធ្វើការខ្វែងយោបល់គ្នាជាមួយសហព្រះរាជអាជ្ញាជាតិបានបញ្ជូនសេចក្តីសន្និដ្ឋានឆ្លើយតបរបស់ខ្លួនទាក់ទងនឹងសំណុំរឿង ០០៣ មកសហចៅក្រមស៊ើបអង្កេតវិញ ។

សហចៅក្រមស៊ើបអង្កេតជាតិសូមគូសបញ្ជាក់ថា ខ្លួននឹងបន្តចំណាត់ការនីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុងនៅក្នុងរយៈពេលសមស្រប ប៉ុន្តែខ្លួននឹងទទួលយកមកពិចារណាផងដែរនូវដីកាសន្និដ្ឋានផ្សេងទៀតរបស់ការិយាល័យសហព្រះរាជអាជ្ញាដែលអាចធ្វើឡើងក្នុងរយៈពេល៣ខែ គិតចាប់ពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ ។

## សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

យោងតាមវិធាន២១(១)(គ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ *Mark B.Harmon* សូមបញ្ជាក់ថាសំណុំរឿង០០៣ នៅតែបើកដំណើរការ ហើយការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋកំពុងបន្តដំណើរការ ។



អគារមួយនៃមន្ទីរស-២១ ឬដែលបច្ចុប្បន្នសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ដើម្បីធានាថា សាធារណជនទទួលបានព័ត៌មានត្រឹមត្រូវអំពីសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញសេចក្តីប្រកាសនេះដោយបង្ហាញពីឧក្រិដ្ឋកម្មដែលត្រូវបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមការស៊ើបអង្កេត ។ ជនណាដែលជាជន

រងគ្រោះនៃបទឧក្រិដ្ឋទាំងនោះ ឬមានដឹងឮពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មទាំងនោះ អាចចូលរួមក្នុងសំណុំរឿង ០០៣ ក្នុងនាមជាសាក្សី ជាដើមបណ្តឹងរដ្ឋប្បវេណីឬជាអ្នកប្តឹង ។

**ឧក្រិដ្ឋកម្មដែលត្រូវបានចោទ និងជនរងគ្រោះ**

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ សម្រាប់សំណុំរឿង០០៣ សហព្រះរាជអាជ្ញាបានចោទថា សមាជិកកងទ័ពបដិវត្តន៍កម្ពុជា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ អំពើមនុស្សឃាត និងអំពើទារុណកម្មនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នៅចន្លោះពីខែមេសា ឆ្នាំ១៩៧៥ ទៅខែមករា ឆ្នាំ១៩៧៩ ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ សហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ដូចតទៅ ៖ កងទ័ពបដិវត្តន៍កម្ពុជា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យបានបោសសម្អាតកងពលយោធា ។ មនុស្សដែលត្រូវបានបោសសម្អាតត្រូវបានចាប់ខ្លួនតាមអំពើចិត្ត ដាក់ឃុំឃាំងដោយខុសច្បាប់ ធ្វើទារុណកម្ម ធ្វើមនុស្សឃាត និងទទួលរងពលកម្មដោយបង្ខំ ។ កម្មករ អ្នកនេសាទ និងប្រជាជនដែលត្រូវបានសម្គាល់ថាជា "ជនក្បត់" ខ្មែរក្រហម ជនបរទេស (លោកខាងលិច ថៃ និងវៀតណាម) ដែលត្រូវបានចាប់ខ្លួននៅក្នុងដែនទឹករបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬត្រូវបានចាប់ពង្រត់ពីតំបន់ព្រំដែន គឺជាជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនោះ ហើយបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលនៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលវាយលុកចូលប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ។

បន្ថែមពីលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅតំបន់ឆ្នេរប្រទេសកម្ពុជា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង០០៣ បានបង្ហាញទីតាំងជាក់លាក់មួយចំនួនដែលឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង ។

**ទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៣**

◆ មន្ទីរសន្តិសុខ ស-២១ ស្ថិតនៅភ្នំពេញ

◆ ទីតាំងសម្លាប់ស្ទឹងតូច ស្ថិតនៅស្រុកពញាក្រែក ខេត្តកំពង់ចាម

◆ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ស្ថិតនៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។



ផ្លូវរត់នៃព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

◆ មន្ទីរសន្តិសុខកងពល៨០១ ស្ថិតនៅស្រុកវើនសៃ ខេត្តរតនគិរី ។

◆ ការដ្ឋានវាយថ្មស្ទឹងហាវ ស្ថិតនៅខេត្តព្រះសីហនុ ។



ការដ្ឋានវាយថ្មស្ទឹងហាវ ខេត្តព្រះសីហនុ

◆ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់វត្តឥន្ទញាណ (ត្រូវបានស្គាល់ដែលថា វត្តក្រោម) ស្ថិតនៅខេត្តព្រះសីហនុ ។



មន្ទីរសន្តិសុខនិងទីតាំងសម្លាប់វត្តឥន្ទញាណ ខេត្តព្រះសីហនុ

◆ មន្ទីរសន្តិសុខ ស-២២ ស្ថិតនៅខណ្ឌមានជ័យ ភ្នំពេញ

◆ ចម្ការធូរេន ស្ថិតនៅភូមិរាម សង្កាត់រាម ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ

◆ ការដ្ឋានបិតត្រាំង ស្ថិតនៅសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ

## ជនដែលអាចក្លាយជាសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកប្តឹង

ដូចបានបញ្ជាក់ខាងលើ ជនណាដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវចោទ ឬជនណាដែលមានដឹងឮពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីតាំងទាំងនោះអាចចូលរួមនៅក្នុងសំណុំរឿង ០០៣ ក្នុងនាមជាសាក្សី ជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាអ្នកប្តឹង ។

## សាក្សី

សាក្សីគឺជាមនុស្សម្នាក់ដែលអាចផ្តល់ព័ត៌មានពីរឿងហេតុការណ៍ផ្ទាល់ ឬការពិតដែលអាចកើតឡើងនៅទីតាំងសម្លាប់នៅក្នុងសំណុំរឿង០០៣ ។ សាក្សីនឹងត្រូវធ្វើការសម្ភាសន៍ដោយសម្ងាត់ពីអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនៅពេលក្រោយទៀត អាចត្រូវកោះអញ្ជើញឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើសំណុំរឿង០០៣ដំណើរការការជំនុំជម្រះ ។

ជនដែលអាចក្លាយជាសាក្សី គួរទាក់ទងការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រាប់ព័ត៌មានពីរឿងហេតុការណ៍ផ្ទាល់ ឬការពិតដែលអាចកើតឡើងនៅទីតាំងសម្លាប់នៅទីតាំងសម្លាប់នៅក្នុងសំណុំរឿង០០៣ ។ សាក្សីនឹងត្រូវធ្វើការសម្ភាសន៍ដោយសម្ងាត់ពីអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនៅពេលក្រោយទៀត អាចត្រូវកោះអញ្ជើញឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើសំណុំរឿង០០៣ដំណើរការការជំនុំជម្រះ ។

ជនដែលអាចក្លាយជាសាក្សីគួរទាក់ទងការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រាប់ព័ត៌មានបន្ថែម ៖ ជាភាសាខ្មែរ សូមទាក់ទងលោក រស់ សំពៅ តាមរយៈទូរស័ព្ទការិយាល័យ៖ ០២៣ ២១៩ ៨៤១ លេខតភ្ជាប់ ៦១០៣ ។

ជាភាសាអង់គ្លេស និងបារាំង សូមទាក់ទងលោក Bernard Brun តាមរយៈទូរស័ព្ទការិយាល័យ ៖ ០២៣ ៨៦១ ៥៦៦ លេខតភ្ជាប់ ៦០៦៦ ។

## ដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទ អាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចឲ្យពួកគាត់ចូលរួមនៅក្នុងដំណើរការនីតិវិធី និងទាមទារសំណងផ្លូវចិត្ត និងសមូហភាព ។ ជនរងគ្រោះត្រូវជាជន ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មរូបកាយ សម្ភារ និងផ្លូវចិត្ត ដែលជាលទ្ធផលផ្ទាល់ពីបទឧក្រិដ្ឋកម្មយ៉ាងហោចមួយក្នុងចំណោមបទឧក្រិដ្ឋនៅក្នុងសំណុំរឿង០០៣ ។

ក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសហចៅក្រមស៊ើបអង្កេតឲ្យសម្ភាសន៍ខ្លួន សាកសួរសាក្សី ឬទៅទីតាំងឧក្រិដ្ឋណាមួយ ឬក៏ប្រមូលភ័ស្តុតាងផ្សេងទៀត ។

អ្នកដែលចាប់អារម្មណ៍ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទាក់ទងអង្គភាពគាំពារជនរងគ្រោះដើម្បីស្នើសុំជំនួយគាំទ្រ ដោយប្រើប្រាស់ព័ត៌មានទំនាក់ទំនងខាងក្រោមនេះ ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបញ្ជូនមកមិនឲ្យហួសរយៈពេល១៥ថ្ងៃ បន្ទាប់ពីថ្ងៃដែលភាគីនានា ត្រូវបានជូនដំណឹងពីការបញ្ចប់ការស៊ើបសួរ ។

## អ្នកប្តឹង

ជន ឬនីតិបុគ្គលណាដែលមានព័ត៌មានសារៈប្រយោជន៍ទាក់ទងនឹងបទឧក្រិដ្ឋនៅក្នុងសំណុំរឿង០០៣ អាចដាក់ពាក្យបណ្តឹងទៅសហព្រះរាជអាជ្ញា តាមរយៈអង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក ។ ព័ត៌មាននៅក្នុងពាក្យបណ្តឹងអាចត្រូវប្រើប្រាស់ដើម្បីជួយដល់ការស៊ើបអង្កេត ។

អ្នកប្តឹង មិនចូលរួមជាភាគីនៅក្នុងសវនាការឡើយ ហើយពួកគាត់មិនមានសិទ្ធិស្នើសុំតុលាការឲ្យផ្តល់សំណង ។ ទោះបីយ៉ាងណាពួកគាត់អាចត្រូវស្នើសុំឲ្យផ្តល់ភ័ស្តុតាង ឬសក្ខីកម្មក្នុងនាមជាសាក្សី ។

អ្នកដែលចាប់អារម្មណ៍ដាក់ពាក្យបណ្តឹង អាចទាក់ទងអង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក សម្រាប់ស្នើសុំជំនួយគាំទ្រ ។ ទោះបីជាគ្មានកាលបរិច្ឆេទកំណត់សម្រាប់ដាក់ពាក្យបណ្តឹងក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើកទឹកចិត្តឲ្យជនរងគ្រោះ ឬសាក្សីដាក់ពាក្យបណ្តឹងឲ្យបានលឿនតាម ដែលអាចធ្វើទៅបាន ។

**ឯកសារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនិងថ្នាក់រៀននេះ សូមទាក់ទង ស៊ីរិ សាវីណា តាមរយៈទូរសព្ទ័លេខៈ ០២៣ ២១១ ៨៧៥ ។

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ**

**◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវដ្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ុំ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។





















# ចៅក្រមអង្គបុរេជំនុំជម្រះជាតិ និងអន្តរជាតិខ្វែងគំនិតគ្នានៅក្នុងសំណុំរឿង០០៣ ជាថ្មីម្តងទៀត

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានខ្វែងគំនិតគ្នារវាងចៅក្រមអន្តរជាតិ និងចៅក្រមជាតិជាថ្មីទៀតលើសំណុំរឿង០០៣ ដែលមានភាពចម្រូងចម្រាស់គ្នា ដោយបដិសេធនូវបណ្តឹងឧទ្ធរណ៍របស់អ្នកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានការទាត់ចោលម្តងរួចហើយ កាលពី ១៨ខែមុន ក្រោយពីបណ្តឹងនេះជាប់គាំងនោះ ។ សេចក្តីសម្រេចនេះស្តែងឲ្យឃើញបន្ថែមទៀតនូវភាពមិនប្រក្រតីលើនីតិវិធីក្នុងការគ្រប់គ្រងសំណុំរឿងនិងធ្វើឲ្យមានកង្វល់ឡើងវិញអំពីសមត្ថភាពរបស់តុលាការក្នុងការចាត់ការកិច្ចស៊ើបសួរដែលនៅសេសសល់ដោយឯករាជ្យនិងមិនលម្អៀង ។

ក្នុងខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និងអតីតសហភាគារបស់គាត់ គឺចៅក្រម ស៊ីកហ្វ្រេដ ប្លុង បានសម្រេចបិទការស៊ើបអង្កេតលើសំណុំរឿង០០៣ភ្លាមៗដោយចេញតែសេចក្តីថ្លែងការណ៍ព័ត៌មានមួយល្បះប៉ុណ្ណោះ ហើយពុំបានជូនដំណឹងជនរងគ្រោះអំពីសិទ្ធិដែលនឹងផុតកំណត់ក្នុងចូលរួមក្នុងដំណើរការនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងការដាក់សំណើសុំចំណាត់ការស៊ើបអង្កេតចុងក្រោយ ។ ជនរងគ្រោះពីរបីនាក់មានលទ្ធភាពដាក់ពាក្យបណ្តឹងនៅក្នុងអំឡុងពេលនៃការកំណត់រយៈ១៥ថ្ងៃដែលច្បាប់ផ្តល់ជូន ហើយអ្នកដាក់បណ្តឹងដែលដឹងជាសាធារណៈទាំងនោះត្រូវបានទាត់ចោលដោយសហចៅក្រមស៊ើបអង្កេត ។ ដោយទទួលបានបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹង រ៉ប់ ហាមីល ដែលបងរបស់គាត់ត្រូវបានយោធាដើងទឹកដែលស្ថិតក្រោមបញ្ជាការរបស់ជនសង្ស័យក្នុងសំណុំរឿងនេះចាប់ជាអ្នកទោស និងក្រោយមកត្រូវបានសម្លាប់ចោលនោះអង្គបុរេជំនុំជម្រះពុំអាចឈានដល់ការសម្រេចទេដោយសារតែមានការខ្វែងគំនិតគ្នារវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ។ យោបល់ដោយឡែករបស់ចៅក្រមអន្តរជាតិបានបន្ទោសសហចៅក្រមស៊ើបអង្កេតពីភាពមិនស៊ីសង្វាក់នៅក្នុងការដោះស្រាយកិច្ចស៊ើបសួរដោយប្រៀបធៀបនឹងរបៀបស៊ើបអង្កេតលើសំណុំរឿង០០១ និង០០២ ដែលបានធ្វើឡើងកន្លងមករួមទាំងការខកខានក្នុងការចង្អុលបង្ហាញជនសង្ស័យដែលត្រូវចោទប្រកាន់ការខកខានក្នុងការជូនដំណឹងជនរងគ្រោះឲ្យបានទាន់ពេលវេលាដើម្បីឲ្យជនរងគ្រោះអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនចូលរួមនៅក្នុងដំណើរការស៊ើបអង្កេតការខកខានក្នុងការទទួលស្គាល់មេធាវីរបស់ដើមបណ្តឹងនិងក្នុងការជូនដំណឹងដល់មេធាវីអំពីឯកសារនៅក្នុងសំណុំរឿងឬផ្តល់សិទ្ធិទទួលបានការមើលសំណុំរឿង ព្រមទាំង «ការពន្យារពេលដែលពុំមានការពន្យល់ឲ្យបានជាក់លាក់នៅក្នុងដំណើរការទទួលយកឯកសារ និងដាក់ឯកសារចូលក្នុងសំណុំរឿង» ។

អ្នកដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតគឺមិនត្រូវបានបញ្ចេញឈ្មោះទេ ។ ដើមបណ្តឹងម្នាក់នេះត្រូវបានបង្ខំឲ្យរៀបការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យហើយប្តីរបស់ខ្លួនត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់នៅការដ្ឋានសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង (ទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៣) មុននឹងត្រូវបានធ្វើទារុណកម្ម និងសម្លាប់ចោលនៅមន្ទីរសន្តិសុខ ស-២១ ។ បើទោះបីជាដើមបណ្តឹងម្នាក់នេះត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០១ និង០០២រួមមក ហើយក៏ដោយ សហចៅក្រមស៊ើបអង្កេតនៅតែផ្តល់ហេតុផលថាដើមបណ្តឹងម្នាក់នេះពុំទទួលរងផលប៉ះពាល់ដោយផ្ទាល់ដោយឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងប្តីរបស់ខ្លួនទេ ផ្ទុយទៅវិញគឺដោយបច្ច័យផ្សេង ពោលគឺការងារធ្ងន់ដែលត្រូវបានបង្ខំឲ្យធ្វើរបស់ប្តីដើមបណ្តឹងនោះ ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញទៀតថា វា «មិនជាទំនងប៉ុន្មានទេ» ដែលថាដើមបណ្តឹងម្នាក់នេះតាមពិតទៅបានទទួលរងការឈឺចាប់ខាងផ្លូវចិត្តដោយសារតែការបង្ខំឲ្យធ្វើការជាទម្ងន់របស់ប្តីខ្លួន កាលពី ៣៨ឆ្នាំកន្លងទៅនោះ ហើយសន្និដ្ឋានថាដើមបណ្តឹងម្នាក់នេះប្តឹង

ទាមទារ «ដោយផ្អែកលើការឲ្យយោបល់ដែលមិនសមហេតុពីភាគីទី៣» ។ នៅទីបញ្ចប់សហចៅក្រមស៊ើបអង្កេតបាននិយាយថាដើមបណ្តឹងនេះមិនគួរនឹងទទួលយកទេពីព្រោះខ្លួនគឺជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង០០២ រួចទៅហើយ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងនេះកាលពីឆ្នាំ២០១១ បានចង្អុលបង្ហាញថា វាពុំមានការបន្ទន់នូវទស្សនៈយល់ឃើញតាំងពីពេលចេញសេចក្តីសម្រេចលើ រ៉ប់ ហាមីុល មកម៉្លេះ ។ដោយសារតែអង្គបុរេជំនុំជម្រះ ពុំអាចឈានដល់សេចក្តីសម្រេចជាឯកច្ឆ័ន្ទ អនុលោមតាមវិធានរបស់តុលាការសេចក្តីសម្រេចទាត់ចោលការដាក់បណ្តឹងរបស់ដើមបណ្តឹងដោយសហចៅក្រមស៊ើបអង្កេតនៅតែមានប្រសិទ្ធភាព ។ដោយឆ្លុះបញ្ចាំងលើហេតុផលដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ រ៉ប់ ហាមីុល យោបល់ដោយឡែករបស់ចៅក្រមជាតិនៅអង្គបុរេជំនុំជម្រះអះអាងថា ដោយសារតែសហចៅក្រមស៊ើបអង្កេតពុំទាន់ចោទប្រកាន់នរណាម្នាក់នៅឡើយក្នុងសំណុំរឿង០០៣ «ទើបពុំមានជនត្រូវចោទដែលត្រូវទទួលខុសត្រូវលើដំណោះស្រាយដែលស្វែងរកសម្រាប់ជួសជុលការខូចខាតដែលបង្កដល់ជនរងគ្រោះ ហើយអាស្រ័យហេតុនេះ ការទាត់ចោលការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលនេះគឺពុំរំលោភលើសិទ្ធិរបស់ជនរងគ្រោះទេ» ។

ផ្ទុយទៅវិញចៅក្រមអន្តរជាតិ *Downing* និង *Chung* បានយកតាមការកត់សម្គាល់ទាំងអស់នៅក្នុងសេចក្តីលើបណ្តឹងឧទ្ធរណ៍របស់ រ៉ប់ ហាមីុល ស្តីអំពីការកើតមានឡើងនូវភាពមិនប្រក្រតីផ្នែកនីតិវិធី និងភាពមិនស៊ីសង្វាក់នៅក្នុងកិច្ចការរបស់សហចៅក្រមស៊ើបអង្កេត ។ លើសពីនេះទៀតចៅក្រមទាំងពីរ បានរកឃើញភាពមានចន្លោះផ្នែកនីតិវិធីបន្ថែមទៀត ដែលតាមទស្សនៈរបស់ខ្លួនគឺត្រូវឈានដល់ការសម្រេចមោឃភាព ដោយសារតែ «ផលប៉ះពាល់របស់វាមានលក្ខណៈផ្ទុយគ្នា» លើសិទ្ធិរបស់ភាគី ៈ ទាំងការដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឯកសារដែលគាំទ្រដល់បណ្តឹងគឺជាផ្នែកខ្លះនៅក្នុងសំណុំរឿងដែលនាពេលនោះត្រូវទាត់ចោល ។ «ហេតុដូច្នេះវាទំនងត្រូវបានសហចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចដែលរងការជំទាស់ដោយពុំទទួលយកបណ្តឹងនឹងពុំជូនដំណឹងដល់សហព្រះរាជអាជ្ញា និងជនត្រូវចោទ» ដោយជៀសវាងនូវ «របបនីតិវិធីដែលមានរួចមកហើយតាមរយៈវិធានផ្ទៃក្នុង ព្រមទាំងការធានាជាមូលដ្ឋានលើដំណើរការក្តីប្រកបដោយយុត្តិធម៌ដែលចែងឡើងជាស្តង់ដាទទួលស្គាល់ជាអន្តរជាតិ ។» ភាពមិនប្រក្រតីថ្មីនេះ «ឆ្លុះបញ្ចាំងឲ្យឃើញនូវគំរូនៃការប្រព្រឹត្តដែលទទួលយកដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣» ដែល «ធ្វើឲ្យមានមន្ទិលសង្ស័យលើចេតនារបស់ចៅក្រមក្នុងការបើកកិច្ចដំណើរនីតិវិធីតាមរបៀបមួយដែលប្រកបដោយតម្លាភាព និងអាចគតាំងបានដែលនឹងធានាដល់ការគោរពសិទ្ធិរបស់ភាគីនិងអ្នកចូលរួមនៅកិច្ចដំណើរការនោះ» ។

ដោយចៅក្រមជាតិ និងអន្តរជាតិពុំយល់ព្រមបញ្ជូនសំណុំរឿងត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញដើម្បីធ្វើការពិចារណាជាថ្មីដោយសារតែផលវិភាគដែលកើតចេញពីភាពមានចន្លោះផ្នែកនីតិវិធីទាំងនោះគឺជាលើកទី១ហើយ ដែលចៅក្រមអន្តរជាតិ នៅអង្គបុរេជំនុំជម្រះដោះស្រាយលើខ្លឹមសារនៃហេតុផលដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ។ ចៅក្រមអន្តរជាតិបានកត់សម្គាល់ថាទាំងដើមបណ្តឹងឧទ្ធរណ៍ ទាំងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលធ្លាប់បានទទួលយកដោយសហចៅក្រមស៊ើបអង្កេតអង្គបុរេជំនុំជម្រះនិងអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ និង ០០២ បានពឹងផ្អែកលើ «ការឈឺចាប់ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកគ្រួសារផ្ទាល់របស់ខ្លួន ដោយរួមបញ្ចូលទាំងប្តីឬប្រពន្ធរបស់ខ្លួនទៀតផង» ។ ក្នុងការសម្រេចផ្ទុយដែលថារបួសស្នាមរបស់ដើមបណ្តឹងពុំឆ្លើយតបនឹងលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ការទទួលយកនៅក្នុងសំណុំរឿង ០០៣នោះ គឺសហចៅក្រមស៊ើបអង្កេតមិនបានយកចិត្តទុកដាក់លើការសម្រេចពីមុនៗរបស់តុលាការ និងបានរំលោភលើសិទ្ធិរបស់ភាគី «ក្នុងការទទួលបាននូវភាពជាក់លាក់របស់ច្បាប់ និងភាពស្មើគ្នាចំពោះមុខច្បាប់» ។ លើសពីនេះទៀតចៅក្រមអន្តរជាតិបានរកឃើញនូវចំណងទាក់ទងដែលសហចៅក្រមស៊ើបអង្កេតសម្រេចថាមានតែជនរងគ្រោះក្នុងចំណងលោហិតជិតស្និទ្ធប៉ុណ្ណោះមានសិទ្ធិក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហើយមិនមែនញាតិលោហិតឆ្ងាយនោះទេដែលមានសិទ្ធិនេះដែលវាខុសមិនត្រឹមតែនឹងគោលបំណងរបស់វិធានផ្ទៃក្នុង

ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងខុសនឹងការអនុវត្តលក្ខណៈជាតិ និងអន្តរជាតិទៀតផង ។ ចុងបញ្ចប់ ចៅក្រមអន្តរជាតិ បាននិយាយថា ស្តង់ដានៃភ័ស្តុតាងដូចដែលយកមកអនុវត្តនេះខ្វះការឲ្យហេតុផលច្បាស់លាស់ និងការសន្មត់ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិទទួលឲ្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងច្រើនផ្សេងពីគ្នានោះ “គឺពុំមានក្នុងមូលដ្ឋានច្បាប់ ឬនៅក្នុងការឲ្យហេតុផលពីមុនៗទេ ហើយបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះទៀតផង” ។ ដោយសារតែអង្គបុរេជំនុំជម្រះដែលមានការខ្វែងគំនិតនេះមិនអាចផ្តល់ជូនដើមបណ្តឹងខទ្វរណ៍នូវការដោះស្រាយចំពោះការពិចារណាដោយខ្វះចន្លោះរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំរបស់ដើមបណ្តឹងទើបចៅក្រមអន្តរជាតិជំរុញឲ្យសហចៅក្រមស៊ើបអង្កេតបច្ចុប្បន្នអនុវត្តសិទ្ធិអំណាចដែលខ្លួនមានដើម្បីពិចារណាលើសំណើសុំនោះឡើងវិញ ។ ទោះបីជាយ៉ាងនេះក្តីដូចដែលបានកត់សម្គាល់ដោយចៅក្រមអ៊ីចឹងគឺរឿងនេះធ្លាប់បានកើតមានរួចមកហើយ ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងឡូរ៉ង់ កាស្ពឺ-អានសើមេត ចូលកាន់តំណែងជំនួសឲ្យចៅក្រមប៊្លុង) លោកបានពិចារណាសំណើសុំនោះឡើងវិញដោយរកឃើញថា សំណើសុំនោះបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវចាំបាច់ដែលអាចទទួលយកបាននិងបានផ្តល់ជូននូវសិទ្ធិទទួលបានឯកសារក្នុងសំណុំរឿងទៀតដោយបានធ្វើឲ្យបណ្តឹងខទ្វរណ៍របស់ដើមបណ្តឹងអាចយកមកពិភាក្សាបានយ៉ាងត្រឹមត្រូវ ។ ទោះបីជាយ៉ាងនេះក្តីសេចក្តីសម្រេចរបស់ចៅក្រមកាស្ពឺ-អានសើមេត ពុំមានឥទ្ធិពលជាក់ស្តែងទេគឺដោយសារតែរដ្ឋាភិបាលកម្ពុជាមិនព្រមទទួលស្គាល់ការតែងតាំងនិងសិទ្ធិអំណាចក្នុងការចាត់វិធានការរបស់លោកចៅក្រម ។ បុគ្គលិកជាតិបានបដិសេធដោយបែបក្នុងការអនុវត្តសេចក្តីសម្រេចនេះដោយរាប់បញ្ចូលទាំងការសម្រេចទទួលយកការពិចារណាឡើងវិញលើសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រ៉ប់ហាមីល និងផ្តល់ជូនមេធាវីរបស់ដើមបណ្តឹងរូបនេះនូវសិទ្ធិទទួលបានឯកសារនៅក្នុងសំណុំរឿង ០០៣ទៀតផង ។

អាស្រ័យហេតុនេះវាមិនសូវជាទំនងទេដែលថាសេចក្តីសម្រេចណាមួយរបស់ចៅក្រម កាស្ពឺ-អានសើមេត រួមទាំងការបន្តការស៊ើបអង្កេតលើសំណុំរឿង០០៣នោះនឹងត្រូវបានគោរពតាម លុះត្រាតែចៅក្រម *Mark Harmon* (ម៉ាក់ ហាម៉ុន) ដែលទទួលតំណែងបន្តនោះទទួលយកសេចក្តីសម្រេចមកអនុវត្ត ។ សេចក្តីសម្រេចថ្មីរបស់អង្គបុរេជំនុំជម្រះបានប្រកាន់យកលំនាំពីមុនដោយសារតែទស្សនៈរបស់ចៅក្រមជាតិនៅតែព្យាយាមលើកហេតុផលដដែលៗនោះគឺភាពខ្វះខាតក្នុងការទទួលបានអំណាចរបស់ចៅក្រមកាស្ពឺ-អានសើមេត ដែលបានធ្វើឲ្យចៅក្រមពុំមានសិទ្ធចាត់កិច្ចស៊ើបសួរ ។ ភាពគ្មានសុឆន្ទៈបន្តទៀត របស់ចៅក្រមជាតិនៃអង្គបុរេជំនុំក្នុងការទទួលស្គាល់ និងដោះស្រាយភាពមានចន្លោះផ្នែកនីតិវិធីដែលជាក់ស្តែង និងរីករាលដាលទាក់ទងនឹងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ អាចធ្វើឲ្យកើនឡើងនូវភាពមន្ទិលសង្ស័យដែលថាសំណុំរឿងនេះនឹងត្រូវអនុញ្ញាតឲ្យចាត់ការបន្តដោយអនុលោមតាមវិធានផ្ទៃក្នុង និងស្តង់ដាអន្តរជាតិរបស់តុលាការទោះបីជាមានសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីចូលមកកាន់តំណែងក៏ដោយ ។

**អាន ហាញឌុល**



# អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធ ការបំបែកសំណុំរឿង០០២

ដោយការដាក់កិច្ចដំណើរការនីតិវិធីស្ថិតក្នុងស្ថានភាពប្រឬក ប្រឬល់អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានលុបចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿង០០២/០១ ដែលបានចំណាយពេល១៥ខែឲ្យទៅជាសវនាការមួយសម្រាប់តែឃ្លាំមើលការធ្លាក់ចុះដុនដាបនៃសុខភាពរបស់ជនជាប់ចោទដែលមានវ័យជាង៨០ឆ្នាំ ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូង បានរំលោភទៅលើសិទ្ធិរបស់ភាគីក្នុងការទទួលបានយោបល់ដែលមានសំអាងហេតុ និងការជំនុំជម្រះព្រមទាំងបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបំបែកកិច្ចដំណើរការនីតិវិធីនៃការចោទប្រកាន់ដ៏ធំនៅក្នុងសំណុំរឿង០០២ ឲ្យទៅជា «សវនាការតូចៗ» និងបង្គាប់ឲ្យពិនិត្យឡើងវិញនូវចំណុចបានកោសលុប ។ អង្គជំនុំជម្រះសាលាដំបូងនាពេលបច្ចុប្បន្នបានរៀបចំកាលវិភាគសម្រាប់សវនាការលើផលវិបាកដែលចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចំនួនពីរថ្ងៃនាសប្តាហ៍ក្រោយ ។

កាលពីខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច «បំបែកដំណើរការនីតិវិធី (សំណុំរឿង ០០២) ឲ្យទៅជាផ្នែកតូចៗជាច្រើនដែលពុំជាប់ពាក់ពន្ធ័នឹងអង្គហេតុចោទប្រកាន់ និងបញ្ហាផ្លូវច្បាប់» ។ សំណុំរឿង ០០២/០១ បង្ហាញពីប្រធានបទមូលដ្ឋានដូចជា រចនាសម្ព័ន្ធ និងគោលនយោបាយនៃរបបខ្មែរក្រហម និងតួនាទីរបស់សហជនជាប់ចោទនៅមុន និងក្រោយពេលរបបខ្មែរក្រហមបានឡើងកាន់កាប់អំណាច ។ នៅក្នុងចំណោមគោលនយោបាយឧក្រិដ្ឋកម្មទាំង៥យ៉ាងនៅទូទាំងប្រទេស ដែលអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកំពុងរងការចោទប្រកាន់ទាមទារឲ្យទទួលខុសត្រូវ មានតែឧក្រិដ្ឋកម្មមួយគត់ដែលលើកយកមកពិភាក្សា គឺបទឧក្រិដ្ឋទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនកម្ពុជាដោយបង្ខំចេញពីទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបញ្ហាផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចំនួនរាប់ម៉ឺននាក់ទៅប៉ែកខាងត្បូងនៃប្រទេសកម្ពុជា ពីចុងឆ្នាំ១៩៧៥ ដល់១៩៧៧ ។ បទចោទប្រកាន់ទាក់ទងនឹងទីកន្លែងធ្វើការងារ សហករណ៍ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ក៏ដូចជា បទឧក្រិដ្ឋរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើប្រល័យពូជសាសន៍ត្រូវបានរក្សាទុករង់ចាំសវនាការមួយនាពេលខាងមុខដែលមិនទាន់កំណត់ពេលវេលាច្បាស់លាស់ ។

ទោះបីជាមានការយល់ស្របថា បទចោទប្រកាន់ត្រូវតែតាមលំដាប់លំដោយ ភាគីព្រះរាជអាជ្ញាបានស្នើសុំភ្លាមៗឲ្យរាប់បញ្ចូលនូវភាពតំណាងបទចោទប្រកាន់ដែលបានជ្រើសរើស ដោយយោងតាមការព្រួយបារម្ភរបស់ខ្លួនចំពោះជនជាប់ចោទកំពុងមានវ័យចំណាស់ដែលអាចនឹងពុំមានជីវិតប្រឈមមុខចំពោះសវនាការដំណាក់កាលទីពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើសុំរបស់ភាគីសហព្រះរាជអាជ្ញា ប៉ុន្តែខ្លួនបានរក្សាទុកនូវសិទ្ធិសម្រេច «នៅពេលណាមួយ» ដើម្បីរួមបញ្ចូលគ្នានូវចំណុចបន្ថែមនៃបទចោទប្រកាន់ ។ ដោយសារបញ្ហាមួយ គឺកាលពីខែមករា ឆ្នាំ២០១២ ភាគីសហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងដាក់បន្ថែមទីតាំងសម្លាប់មនុស្សចំនួនបីកន្លែង ។ នៅខែតុលា បន្ទាប់ពីឆ្លងកាត់ការបើកសវនាការអស់រយៈប្រហែលជិតមួយឆ្នាំ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់វិសាលភាពនៃបទចោទប្រកាន់ដោយរួមបញ្ចូលទីតាំងសម្លាប់មនុស្សមួយកន្លែងក្នុងចំណោមទីតាំងសម្លាប់មនុស្សបីកន្លែងដែលព្រះរាជអាជ្ញាបានស្នើសុំឲ្យដាក់បញ្ចូល ។ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឲ្យដាក់បញ្ចូលទីតាំងពីរកន្លែងទៀត ដែលត្រូវបានច្រានចោលដើម្បីកែតម្រូវភាពតំណាងនៃបទចោទប្រកាន់ ។ ការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូល មិនត្រឹមតែដោះស្រាយចំពោះសេចក្តីសម្រេចដែលរងការជំទាស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានដោះស្រាយ

ចំពោះសេចក្តីសម្រេចបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានទម្រង់ជា "សេចក្តីសម្រេចប្រើរយៈពេលមួយឆ្នាំ" ក្នុងអំឡុងពេលដែល "អង្គជំនុំជម្រះសាលាដំបូង នៅតែមិនទាន់កំណត់វិសាលភាពសំណុំរឿង០០២/០១ ឲ្យប្រាកដប្រជា និងបើកឲ្យមានការកែប្រែដោយពុំមានលក្ខខណ្ឌវិនិច្ឆ័យដែលអាចជះឥទ្ធិពលចំពោះការកែប្រែណាមួយនោះទេ" ។

វិធានបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖

> នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ រឿងក្តីដែលត្រូវបានបំបែកត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប ។

អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់អនុសាសន៍ថា ក្នុងន័យនេះ បានកំណត់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង គឺដើម្បីបម្រើឲ្យកាលៈទេសៈសំអាងហេតុពេញលេញ ខ្លួនអាចចង្អុលបង្ហាញពី "ផលប្រយោជន៍នៃយុត្តិធម៌" "លក្ខខណ្ឌបទចោទដែលបានជំនុំជម្រះដាច់ដោយឡែក បម្រើឲ្យគោលដៅនៃកិច្ចដំណើរការនីតិវិធី និងគោលការណ៍ដែលជាមូលដ្ឋានសំអាង ។ កត្តាពាក់ព័ន្ធជាច្រើន ត្រូវតែវាយតម្លៃលើ "ការបំបែកសំណុំរឿងមួយ និងរួមបញ្ចូលយ៉ាងសមស្របនូវការពិចារណាពីខាងលើដោយអង្គជំនុំជម្រះសាលាដំបូង ៖ តម្រូវឲ្យមានការពន្លឿននីតិវិធី និងតាមលំដាប់លំដោយត្រឹមត្រូវនៃសំណុំរឿង០០២/០១ ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញ "ការព្រមាន" ចំពោះ "សំអាងហេតុតិចតួចរបស់អង្គជំនុំជម្រះសាលាដំបូង" ទាក់ទងទៅនឹង "របៀបបំបែកសំណុំរឿងឲ្យសម្រេចបាននូវផលប្រយោជន៍យុត្តិធម៌" និងបានរកឃើញនូវកំហុសផ្នែកច្បាប់ទាំងនេះ ។

ដោយឡែក អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការបង្ហាញភ័ស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ពុំមានភាពចាំបាច់សម្រាប់សំណុំរឿង០០២/០១ ដើម្បីធ្វើឲ្យមាន "ភាពតំណាងសមហេតុផលនៅក្នុងបទចោទទាំងអស់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដោយសារពុំមានបទចោទណាមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានលើកលែង ។ សំអាងហេតុនេះ ពុំអាចរកបាននូវការសម្រុះសម្រួលជាមួយការបង្ហាញភ័ស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការបំបែកសំណុំរឿង០០២ ស្តីពីវិមតិសង្ស័យរបស់ខ្លួនចំពោះស្មារតី និងកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការរយៈពេលវែងឡើយ ។

> ទោះបីជាដូច្នេះមែន វិមតិសង្ស័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលទ្ធភាពរបស់សហជនជាប់ចោទនៅក្នុងការចូលរួមការជំនុំជម្រះ ដែលមានរយៈពេលវែងដូច្នេះ វាពុំទំនងអាចស្វែងរកវិធីណាមួយ ដើម្បីកំណត់ពីវិសាលភាពនៃសំណុំរឿង០០២/០១ ក្នុងដំណាក់កាលដំបូងបំផុតដែលអាចពង្រីកឲ្យបានកម្រិតអតិបរមានូវបទចោទទាំងអស់ប្រឆាំងនឹងជនជាប់ចោទនិងដែលអាចផ្តល់ឱកាសនៅក្នុងការទទួលបានយុត្តិធម៌ដ៏មានអត្ថន័យពេញលេញនៅក្នុងរយៈពេលមួយដ៏ខ្លីបំផុត ។

អង្គជំនុំជម្រះតុលាការកំពូលក៏បានរកឃើញដែរថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងផ្នែកច្បាប់ដោយខកខានក្នុងការពិគ្រោះយោបល់ជាមួយភាគីអំពីលក្ខខណ្ឌនៃការបំបែកកិច្ចដំណើរការនីតិវិធី ។ ពុំមានភាគីណាមួយបានទទួលការសួរយោបល់ជាមុនឡើយ ដោយសារអង្គជំនុំជម្រះសាលាដំបូងលើកឡើងថា នេះគឺជាការមិនចាំបាច់នៅក្នុងប្រព័ន្ធតុលាការដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេតត្រូវបានគ្រប់គ្រងដោយសមត្ថកិច្ចតុលាការ ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា នីតិវិធីនៃការពិភាក្សាយោបល់ភាគីគឺអាចចេញលទ្ធផលក្នុងពេលខាងមុខដែលនឹងពន្យារពេលសវនាការដ៏វែង មិនអាចទទួលយកបាន ។

អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា វិធានផ្ទៃក្នុងផ្តល់ឆន្ទានុសិទ្ធិពេញលេញជូនអង្គជំនុំជម្រះសាលាដំបូងទាំងការចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៅពេលដែលមានការចាំបាច់ និងផ្តល់ឲ្យនូវការពិចារណានូវការរៀបចំនីតិវិធី

ដាច់ៗពីគ្នា ទៅតាមលំដាប់លំដោយនៃការជំនុំជម្រះ ប៉ុន្តែពុំមែនផ្តល់សិទ្ធិសេរីភាពក្នុងការពិចារណាទៅលើទម្រង់នៃការបំបែកកិច្ចដំណើរការនីតិវិធីឡើយ ។ ការស្វែងរកឲ្យឃើញផ្សេងពីនេះ អាចពុំយកចិត្តទុកដាក់លើការខ្វែងគំនិតគ្នាទាំងពីរស្តីពីសិទ្ធិរបស់ភាគី និងលក្ខណៈផ្ទុយគ្នានៃដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួមទាំង "តួនាទី និងការទទួលខុសត្រូវដ៏សំខាន់របស់សហព្រះរាជអាជ្ញានៅក្នុងការធ្វើដីការបញ្ជូនរឿងឲ្យស៊ើបសួរ និងការបង្ហាញបទចោទនៅក្នុងដីកានោះដែរ" ។

ទោះបីជាការខកខានស្តាប់យោបល់ពីភាគីគឺជាមធ្យោបាយដោះស្រាយដោយផ្នែក នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយល់ព្រមពិចារណាលើសំណើរបស់សហព្រះរាជអាជ្ញាស្តីពីការស្នើសុំពង្រីកវិសាលភាពនៃរឿងក្តីដោយការរួមបញ្ចូលទីតាំងឧក្រិដ្ឋកម្ម "សវនាកាលើអង្គសេចក្តីដែលមានរយៈពេលជិតមួយឆ្នាំបានកន្លងផុតទៅហើយ ដោយគោរពតាមលក្ខខណ្ឌនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ បានធ្វើឲ្យវិសាលភាពនៃសំណុំរឿង០០២/០១ចេញជារូបរាងយ៉ាងមានប្រសិទ្ធិភាព" ។ ការកំណត់ថា ការបំបែកសំណុំរឿងទាំងមូលត្រូវបានច្រានចោល ដោយសំអាងលើកំហុសឆ្គងផ្នែកច្បាប់បានរកឃើញថាការប្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាសុំដាក់បន្ថែមទីតាំងឧក្រិដ្ឋកម្មត្រូវបានលើកយកមកពិភាក្សា ។

អង្គជំនុំជម្រះសាលាដំបូង បច្ចុប្បន្នកំពុងធ្វើការវាយតម្លៃសាជាថ្មីលើភាពត្រឹមត្រូវនៃការបំបែកកិច្ចដំណើរការនីតិវិធី បន្ទាប់ពីការស្តាប់សំណើរបស់ភាគី និងការរក្សានូវតុល្យភាពនៃផលប្រយោជន៍គ្រប់ភាគីចំពោះកត្តាពាក់ព័ន្ធទាំងអស់ ។ នៅក្នុងការអនុវត្តបែបនេះ គឺត្រូវតែកំណត់ថា តើវាគឺជាលទ្ធភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ដើម្បីបម្រើឲ្យការចោទប្រកាន់នៅក្នុងសវនាការតូចៗជាងនេះ ឬក៏ "យ៉ាងហោចណាស់នៅក្នុងសវនាការតូចមួយស្តីពីផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ។ ចំពោះភាពត្រឹមត្រូវនៃការបំបែកកិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះសាលាដំបូងគប្បីបង្កើត និងបញ្ជាក់ពី "ផែនការនៃការជំនុំជម្រះ" សម្រាប់បទចោទនៅសេសសល់ដែលនឹងត្រូវយកមកជំនុំជម្រះ និងបញ្ជាក់អំពីក្តីព្រួយបារម្ភពិតប្រាកដដែលលើកឡើងដោយភាគី ។ ចំពោះការរក្សានូវតុល្យភាពនៃផលប្រយោជន៍គ្រប់ភាគីចំពោះកត្តាពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះសាលាដំបូងគប្បី "បញ្ជាក់ឲ្យបានច្បាស់លាស់" ថា យោងតាមការធ្លាក់ចុះដុនដាបនៃសុខភាពរបស់ជនជាប់ចោទ "ជាការប្រសើរដែលយុត្តិធម៌ គប្បីផ្តល់ជូនតាមរយៈការចេញនូវសាលក្រមមួយ" ទៅលើបទចោទតូចៗជាច្រើន និង "ផ្តល់ជូនតាមរយៈការពិចារណាទៅលើភាពតំណាងនៃសំអាងហេតុក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសវនាការតូចៗ" ។

អ្វីដែលសំខាន់អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ជូនការព្រមានទុកជាមុនចំពោះការព្រួយបារម្ភរបស់ខ្លួនទាក់ទងនឹងផ្នែកច្បាប់ និងលទ្ធភាពអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះលើសំណុំរឿងដែលមានសាលក្រមដាក់ទោសបន្តបន្ទាប់ប្រឆាំងនឹងជនជាប់ចោទ ។ ការស្នើសុំមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បី "បង្កើតឲ្យមានអង្គចៅក្រមជំនុំជម្រះមួយទៀត នៅក្នុងអង្គជំនុំជម្រះសាលាដំបូងដើម្បីគាំទ្រដល់ការជំនុំជម្រះឲ្យបានទាន់ពេលទៅលើផ្នែកដែលនៅសេសសល់នៃសំណុំរឿង០០២" ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា "អង្គចៅក្រមជំនុំជម្រះទីពីរនឹងមានលទ្ធភាពការពារបាន ចំពោះការបារម្ភណាមួយទៅលើភាពលម្អៀងដែលអាចមាន ឬក៏ភាពលម្អៀងជាក់ស្តែង" ប្រសិនបើចៅក្រមតែមួយ ធ្វើការជំនុំជម្រះលើសពីរឿងក្តីមួយប្រឆាំងនឹងជនជាប់ចោទដដែល ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ទៀត ថាអង្គចៅក្រមជំនុំជម្រះទីពីរអាចនឹងចាប់ផ្តើមភ្លាមៗ លើកិច្ចដំណើរការនីតិវិធីក្នុងខណៈដែលអង្គជំនុំជម្រះសាលាដំបូងនេះ កំពុងជាប់រវល់ជាមួយនឹងការព្រាងលើសាលក្រមទីមួយ ហើយកិច្ចការនោះប្រើរយៈពេលលើសពី៨ខែ ដែលមិនលើសខុសគ្នាជាមួយករណីរបស់ ឌុច (សំណុំរឿង០០១) ។

ដោយសារកង្វះខាតផ្នែកហិរញ្ញវត្ថុរបស់តុលាការកំពុងបន្ត និងទុក្ខលំបាកនៃសុខភាពរបស់ជនជាប់ចោទ នាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងទំនងជាសម្រេចបន្តកិច្ចដំណើរការនីតិវិធីជាមួយគម្រោងរបស់ខ្លួនសម្រាប់សវនាការតូចៗជាច្រើន ស្តីពីដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ហើយនឹងជំនួសដោយការផ្តោតទៅលើការកំណត់ច្បាស់លាស់អំពីវិសាលភាពសមស្របមួយ និងភាពតំណាងនៃបទចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១

ដែលប្រហែលគ្មានឹងការរៀបចំនាពេលបច្ចុប្បន្នក្នុងការឈានទៅរកការចេញសាលក្រមមួយក្នុងរយៈពេលឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ ជាការពិត នៅក្នុងការចងួលបង្ហាញក្នុងសេចក្តីសម្រេចរបស់ខ្លួនជូនទៅភាគីលើបញ្ហាទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលបានចោទសួរជាចំណុចៗថា ៖

> *ដោយសារតែការដាក់បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអង្គជំនុំជម្រះធ្លាប់បានជួបប្រទះនូវការពន្យារពេល និងផលវិបាកបន្ថែមទៀត ក្នុងការទទួលបានវត្តមានរបស់ជនជាប់ចោទទាំងបីនាក់តាមពេលវេលាដែលបានកំណត់ ដោយសារតែការចុះដុនដាបផ្នែករាងកាយជនជាប់ចោទគាត់ ។ ដោយផ្អែកលើកាលៈទេសៈដែលមានការផ្លាស់ប្តូរនេះ និងផលវិបាកនានានៃការអនុវត្តវិធីសាស្ត្រណាមួយផ្សេងនៅដំណាក់កាលយឺតពេលទៅហើយនេះ តើលោកលោកស្រីនៅតែជំទាស់នូវការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងទៅលើវិសាលភាពនៃការជំនុំជម្រះដំណាក់កាលទីមួយរបស់ខ្លួនតាមរបៀបដែលត្រូវបានកំណត់ ដោយដីកាបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលពាក់ព័ន្ធនានាកន្លងមកដែរឬទេ?*

ភាគីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងច្បាស់អំពីពេលវេលាសំខាន់ត្រូវចំណាយដើម្បីរៀបចំសវនាការលើភស្តុតាងរួចមកហើយ រហូតដល់សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានមោឃភាពនិងការទាមទារឲ្យមានការពន្លឿនការបញ្ចប់កិច្ចដំណើរការនីតិវិធី ហើយទំនងជាសំណើដែលពង្រីកឲ្យមានការកែទម្រង់សវនាការនាពេលបច្ចុប្បន្ននេះទាំងស្រុង ។ ខណៈដែលភាគីសហព្រះរាជអាជ្ញាទំនងជាស្នើសុំត្រឹមតែបន្ថែមទីតាំងឧក្រិដ្ឋកម្មពីរកន្លែងដែលត្រូវបានច្រានចោលនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឈមមុខនឹងសេចក្តីសម្រេចមួយដែលមានបញ្ហាលំបាកជាងមុន ។ នៅក្នុងដើមបណ្តឹងរដ្ឋប្បវេណីជិត៨.០០០នាក់ ដែលមាននៅក្នុងសំណុំរឿង០០២/០១ គឺមានតែដើមបណ្តឹងរដ្ឋប្បវេណីប្រហែល៧៥០នាក់ ប៉ុណ្ណោះ ដែលជាប់ពាក់ព័ន្ធនៅក្នុងបញ្ហាគោលនយោបាយចលនាផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវដកចេញនឹងពុំត្រូវបានស្តាប់នូវទុក្ខសោកដែលខ្លួនបានទទួលរង និងទំនងជាត្រូវដកចេញខ្លះ ឬទាំងស្រុងពីទម្រង់នៃសំណងដែលគប្បីមាននៅក្នុងការផ្តន្ទាទោស ។ ក្រុមមេធាវីការពារក្តីទាំងអស់ដែលពុំទទួលបានផលប្រយោជន៍ពីការពង្រីកនៃបទចោទជាច្រើននោះ ទំនងជាមានមានអំណះអំណាងដោយបង្ខំឲ្យសាក្សីគន្លិះត្រូវមករំឭកឡើងវិញ ប្រសិនបើសក្ខីកម្មរបស់សាក្សីទាំងនោះ នឹងត្រូវប្រើប្រាស់ដើម្បីបង្ហាញភស្តុតាងបន្ថែមទៅលើបទចោទប្រកាន់ដែលពុំបានគិតទុកជាមុន ។

ទោះបីជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពន្យារពេល ដោយសមហេតុផល គឺទំនងជាលទ្ធផលនៅក្នុងសំណុំរឿង ០០២/០១ រួមមានភាពជាតំណាងពេញលេញនៃការជ្រើសរើសបទឧក្រិដ្ឋ ការប្រតិបត្តិជាក់លាក់នូវគោលការណ៍គ្រឹះដែលខ្លួនប្រកាន់ខ្ជាប់ គប្បីបង្កើនចំនួនជនរងគ្រោះដែលការឈឺចាប់របស់ខ្លួនត្រូវបានថ្លែងចេញ ហើយអ្វីដែលអាចនឹងកើតឡើងនោះ ប្រសិនបើនៅពេលចេញសាលក្រមនឹងផ្តល់ឲ្យមានគំរូដែលអាចប៉ាន់ប្រមាណមួយនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌សម្រាប់តុលាការកម្ពុជា ។ **អាន ហាញឌុល**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# ប្រជាជនចង់ឱ្យសាលាក្តីខ្មែរក្រហមពន្លឿនការកាត់ទោស

អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យបានទទួលមរណភាពក្នុងអាយុ៨៧ឆ្នាំនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងទីក្រុងភ្នំពេញនៅថ្ងៃ ទី១៤ ខែមីនា ឆ្នាំ២០១៣ នៅវេលាម៉ោង៨ និង៤៥នាទីព្រឹក ។ ការស្លាប់នេះបានកើតឡើងមុនពេលដែលសាលក្រមអាចសម្រេចបានទៅទៀតក្នុងសំណុំរឿង០០២ដ៏ល្បីល្បាញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការស្លាប់នេះធ្វើឲ្យ អៀង សារី រួចផុតពីដំណើរការតុលាការ ហើយឥឡូវនេះសាធារណជននៅរង់ចាំមើលថាតើយុត្តិធម៌នឹងត្រូវធ្វើឡើងយ៉ាង ម៉េចខ្លះចំពោះមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ដែលនៅសេសសល់ ។

ការស្លាប់របស់ អៀង សារី ក៏បានគូសបញ្ជាក់អំពីការព្រួយបារម្ភរបស់សាធារណជនដែរជុំវិញបញ្ហាល្បឿនដែលសំណុំរឿង០០២កំពុងដំណើរការនេះ ។ មនុស្សជាច្រើនសម្តែងការព្រួយបារម្ភថា មេដឹកនាំដែលកំពុងត្រូវបានជំនុំជម្រះទោសអាចស្លាប់មុនពេលមានសាលក្រមស្ថាពរចុងក្រោយ ។ ប្រសិនបើមានករណីនោះមែន ដំណើរការចោទប្រកាន់ទៅលើជនត្រូវចោទនឹងត្រូវបានបញ្ចប់ ហើយយុត្តិធម៌ដែលទាមទារពីសំណាក់ប្រជាជនកម្ពុជាទាំងមូលនឹងនៅត្រឹមតែជាសេចក្តីប្រាថ្នាតែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះ សាធារណជនមួយចំនួនដែលត្រូវបានសម្ភាសន៍ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាមានមតិជាឯកច្ឆ័ន្ទនៅក្នុងការអំពាវនាវឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពន្លឿនការកាត់ ទោស និងដោះស្រាយបញ្ហាដែលតុលាការកំពុងប្រឈមមុខ ។

**◆ សឹម រឿន អាយុ៩៣ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ**

វាជាការគួរឲ្យសោកស្តាយដែលការកាត់ទោស អៀង សារី មិនទាន់បានបញ្ចប់នៅឡើយ ។ អៀង សារី ជាមេដឹកនាំខ្មែរក្រហមមួយរូបដែលបណ្តាលឲ្យស្លាប់ប្រជាជនជិតពីរលាននាក់ ។ ខ្ញុំមិនខឹងអ្វីជាមួយនឹង អៀង សារី ដែលបានស្លាប់ទៅហើយនោះទេ ។ ប៉ុន្តែខ្ញុំសូមលើកទឹកចិត្តឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពន្លឿនដំណើរការយុត្តិធម៌នេះផង ។

**◆ កេង ហួត អាយុ៤៨ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ**

ខ្ញុំគ្មានអ្វីថ្លែងក្រៅតែពីពាក្យសោកស្តាយចំពោះការស្លាប់របស់ អៀង សារី ។ ប្រជាជនផ្សេងទៀតក៏មានចិត្តដូចគ្នានេះដែរ ដោយសាររបបខ្មែរក្រហមបានប្រព្រឹត្តអំពើឃោរឃៅទ្រង់ទ្រាយធំមកលើប្រជាជន ។ ក្នុងជំនាន់របបកម្ពុជាប្រជាធិបតេយ្យ ឈាមហូរដូចទន្លេ ។ ទោះបីជា អៀង សារី ស្លាប់ហើយក៏ដោយ ខ្ញុំនៅតែខឹងគាត់ ហើយជូនពរគាត់ជាតិក្រោយគ្មានសេចក្តីសុខឡើយ ដើម្បីជាទណ្ឌកម្មចំពោះការសម្លាប់ដែលគាត់បង្កឡើង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវធានាឲ្យប្រាកដថា ជនជាប់ចោទផ្សេងទៀតត្រូវបានដាក់ទោស ហើយយុត្តិធម៌ត្រូវបានផ្តល់ជូនប្រជាជន» ។

**◆ ខ្ទឹម ចក អាយុ៥៥ឆ្នាំ នៅខេត្តបន្ទាយមានជ័យ**

ខ្ញុំគ្មានការសោកស្តាយអ្វីទេចំពោះការស្លាប់របស់ អៀង សារី ព្រោះគាត់បានធ្វើឲ្យប្រទេសជាតិ យើងទាំងមូលរស់នៅក្នុងភាពលំបាកវេទនា ។ ប្រជាជនខ្មែរទទួលរងការឈឺចាប់រាប់មិនអស់ដោយសារតែគាត់ ហើយយើងតែងរំពឹងថាគាត់នឹងត្រូវបានកាត់ទោស ។ យ៉ាងណាមិញខ្ញុំអភ័យទោសឲ្យគាត់ហើយ ព្រោះគាត់បានស្លាប់បាត់ទៅហើយ ។

**◆ មុំ ជា អាយុ ៧៨ឆ្នាំ នៅខេត្តតាកែវ**

ការស្លាប់របស់អៀង សារី នៅពេលដែលគាត់កំពុងស្ថិតក្នុងការកាត់ទោស គឺជាការប្រមាថមួយចំពោះយុត្តិធម៌ ។ ដោយសារសាលាក្តីខ្មែរក្រហមពុំមានភាពជាម្ចាស់លើខ្លួនឯងធ្វើឲ្យដំណើរការកាត់ក្តីមានសភាពយឺតយ៉ាវ និងស្មុគស្មាញ ។ បើទោះបីជាខ្ញុំស្អប់គាត់យ៉ាងណាក្តី ខ្ញុំបានអភ័យទោសឲ្យគាត់ ហើយខ្ញុំមិនចង់គិតពីបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្តទៀតទេព្រោះវាធ្វើឲ្យខ្ញុំនឹកដល់សាច់ញាតិរបស់ខ្ញុំដែលបានស្លាប់ ។

**◆ ផាត ទុល អាយុ៩១ឆ្នាំ នៅខេត្តបន្ទាយមានជ័យ**

ខ្ញុំមានការសោកស្តាយណាស់ចំពោះការស្លាប់របស់ អៀង សារី ។ បច្ចុប្បន្នដំណើរការនៃការកាត់ក្តីមានសភាពយឺតយ៉ាវ ដូចនេះខ្ញុំសូមសំណូមពរឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាលស្វែងរកវិធីសាស្ត្រណាដើម្បីប៉ះប៉ូវដល់ការស្លាប់នេះ ។ ខ្ញុំពុំស្ងប់ចិត្តសោះ ប៉ុន្តែខ្ញុំបានអភ័យទោសឲ្យគាត់ហើយ ដោយសង្ឃឹមថាជាតិក្រោយគាត់នឹងមិនប្រព្រឹត្តទង្វើដូច្នេះទៀត ។

◆ ***ឈឹម សំណាង អាយុ ៥៦ឆ្នាំ រស់នៅបន្ទាយមានជ័យ***

វាគួរឲ្យសោកស្តាយណាស់ ដែលគាត់ស្លាប់ទៅដោយមិនបានទទួលការកាត់ទោស ។ ខ្ញុំគិតថានេះ ជាភាពអយុត្តិធម៌មួយយ៉ាងខ្លាំងចំពោះប្រជាជនដែលបានបាត់បង់ជីវិត និងទទួលរងការឈឺចាប់ដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំមិនអាចបំភ្លេច និងអភ័យទោសចំពោះអ្វីដែលគាត់បានធ្វើនោះទេ ។

◆ ***ឌី លឿន អាយុ៥០ឆ្នាំ នៅខេត្តបន្ទាយមានជ័យ***

កើត ចាស់ ឈឺ ស្លាប់វាគឺជាខ្សែជីវិតទូទៅរបស់មនុស្សជាតិ ប៉ុន្តែការស្លាប់របស់ អៀង សារី នេះ វាជាការប្រមាថដល់ប្រជាជនដែលរងការឈឺចាប់ពីរបបខ្មែរក្រហម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានតួនាទីក្នុងការស្វែងរកយុត្តិធម៌ដល់ប្រជាជនខ្មែរនិងផ្តល់ជាការដាស់តឿនដល់ខ្មែរជំនាន់ក្រោយកុំឲ្យធ្វើគ្រាប់តាម ។ បើសិនជាអាចខ្ញុំពិតជាចង់ឃើញឧក្រិដ្ឋជនដូច អៀង សារី នេះទទួលទោស ។

◆ ***នួន សុផល អាយុ៦៣ឆ្នាំ នៅខេត្តបន្ទាយមានជ័យ***

ការស្លាប់របស់ អៀង សារី អាចចាត់ទុកថាជាការបាត់បង់ឱកាសមួយក្នុងការផ្តល់យុត្តិធម៌ដល់ប្រជាជនកម្ពុជា ។ ទោះបីជាគាត់ទទួលមរណភាពក៏ដោយ ខ្ញុំគិតថាសាលាក្តីខ្មែរក្រហមគួរតែកាត់ទោសគាត់តាមបច្ឆាមរណៈ ។ លុះត្រាតែមេដឹកនាំខ្មែរក្រហមទាំងអស់បានទទួលទោសទើបអាចបញ្ជាក់ថាយើងបានទទួលយុត្តិធម៌ពេញលេញ ។

◆ ***ពឿន សារ៉ាយ អាយុ៨៩ឆ្នាំ មកពីខេត្តក្រចេះ***

ខ្ញុំពុំមានការខឹងសម្បាចំពោះការស្លាប់ របស់ អៀង សារី ទេ ដោយសារខ្ញុំយល់ថាសាលាក្តីខ្មែរក្រហមបានបំពេញគោលដៅរបស់ខ្លួនដោយបន្តដំណើរការនីតិវិធីរហូតដល់ អៀង សារី ស្លាប់ ។

◆ ***ទុយ ញ៉ូ អាយុ៦៥ឆ្នាំ មកពីខេត្តក្រចេះ***

ខ្ញុំពុំមានយោបល់អ្វីទៅលើការស្លាប់របស់ អៀង សារី ឡើយក្រៅពីការសោកស្តាយចំពោះសវនាការរបស់គាត់ដែលមិនទាន់បានបញ្ចប់ ។ ខ្ញុំគិតថា យើងគួរតែបន្តចងក្រងឯកសារស្តីពីអំពើដ៏សាហាវយោរយៅនៃរបបខ្មែរក្រហមទុកសម្រាប់អប់រំក្មេងជំនាន់ក្រោយ ។

◆ ***ជិន មុត អាយុ៧៥ឆ្នាំ រស់នៅខេត្តកំពង់ចាម***

ទោះបីជាខ្ញុំពុំបានតាមដានកិច្ចដំណើរការនីតិវិធីបានទៀងទាត់ក៏ដោយ ក៏ខ្ញុំពេញចិត្តចំពោះសាលាក្តីខ្មែរក្រហមដែរ ។ នៅពេលដែលខ្ញុំបានដឹងអំពីការស្លាប់របស់ អៀង សារី ខ្ញុំមានតែអារម្មណ៍សោកស្តាយចំពោះប្រទេសជាតិដែលបាត់បង់បុគ្គលម្នាក់ដែលអាចផ្តល់នូវចម្លើយតបចំពោះសំណួរជាច្រើនទាក់ទងនឹងរយៈពេលនៃរបបខ្មែរក្រហម ។ ជាមួយនឹងការស្លាប់របស់ អៀង សារី នេះ ចំពោះខ្ញុំក៏បាត់បង់នូវឱកាសក្នុងការស្តាប់ការពន្យល់របស់គាត់អំពីការប្រព្រឹត្តអំពើព្រៃផ្សៃ និងការរំលោភបំពានដ៏ច្រើនសន្ធឹកសន្ធាប់ ។ ខ្ញុំនៅតែមានសង្ឃឹមថា មេដឹកនាំជាន់ខ្ពស់ដែលនៅមានជីវិតនឹងផ្តល់នូវចម្លើយតបទាំងនោះ ។ ខ្ញុំចង់ឲ្យតុលាការសម្រេចអំពីអ្នកដែលទទួលខុសត្រូវចំពោះអំពើដែលរំលោភបំពាននិងមហន្តរាយនៅក្នុងរយៈពេលដ៏ខ្មៅងងឹតនេះ ។ ការពិតគឺមានសារសំខាន់ណាស់ ដោយហេតុថា ការពិតទាំងនោះនឹងអប់រំក្មេងជំនាន់ក្រោយអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំមិនចង់ឲ្យមានការសងសឹកទេ ប៉ុន្តែខ្ញុំចង់ឲ្យរកឃើញនូវការពិតប៉ុណ្ណោះ ។ ខ្ញុំគិតថា បើទោះបីជាសវនាការទៅលើមេដឹកនាំជាន់ខ្ពស់ចុងក្រោយទាំងពីរនាក់នេះនឹងក្លាយជាសញ្ញាណនៃយុត្តិធម៌ ។ ជាចុងក្រោយ ខ្ញុំពុំមានកំហឹងចំពោះកម្មាភិបាលថ្នាក់ក្រោមទេ ព្រោះខ្ញុំជឿថា កម្មាភិបាលទាំងនោះគ្រាន់តែអនុវត្តតាមបញ្ជាខាងលើដើម្បីការពារជីវិតខ្លួនឯងតែប៉ុណ្ណោះ ។

◆ ***អ៊ូ ហ៊ាង មានអាយុ៧១ ឆ្នាំ រស់នៅខេត្តកំពង់ធំ***

ខ្ញុំពុំសប្បាយចិត្តសោះចំពោះការស្លាប់ដោយសុខសាន្តរបស់ អៀង សារី បែបនេះ ដោយសារវាខុសគ្នាទៅនឹងការស្លាប់របស់ប្រជាជនរាប់លាននាក់ ក្រោមបញ្ជារបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ សូម្បីតែគុកដាក់មេដឹកនាំទាំង នោះក៏មានសភាព

ប្រសើរជាងគុកដែលប្រជាជនកម្ពុជាជាច្រើននាក់បានទទួលរងទុក្ខ និងស្លាប់នៅក្រោមច្បាប់របស់ខ្មែរក្រហមដែរ ។ បើទោះបីជាមេដឹកនាំត្រូវបាននាំយកមកជំនុំជម្រះនៅក្នុងតុលាការ ក៏មេដឹកនាំទាំងនោះអាចដេកស្រួល មានសម្លៀកបំពាក់ត្រឹមត្រូវ និងការហូបចុកប្រសើរដែរ ។ ខ្ញុំមានការឈឺចាប់ណាស់ការដែល អៀង សារី ស្លាប់នៅលើពូកត្រឹមត្រូវនៅក្នុងមន្ទីរពេទ្យ បន្ទាប់ពីទទួលបានការព្យាបាលដោយ ក្រុមគ្រូពេទ្យជំនាញ ។ វាខុសគ្នាស្រឡះពីការស្លាប់បន្តបន្ទាប់គ្នារបស់ប្រជាជនកម្ពុជាជាច្រើននាក់ដែលស្លាប់ដោយសារគ្មានការព្យាបាល ហើយសាកសពរបស់ជនរងគ្រោះត្រូវបានទុកចោលឲ្យស្អុយរលួយកណ្ដាលវាលស្រែ ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាសាលាក្ដីខ្មែរក្រហមចំណាយពេលយូរម្ល៉េះក្នុងការកាត់ទោសនេះ ។ ខ្ញុំខ្លាចថាមេដឹកនាំដែលនៅសេសសល់នឹងស្លាប់មុនពេលទទួលបានយុត្តិធម៌ ។

### ◆ មុំ ម៉េត រស់នៅភ្នំពេញ

ខ្ញុំសោកស្ដាយដែលគាត់ស្លាប់មុនពេលតុលាការបញ្ចប់ការកាត់ក្ដី ។ ដំណើរការនៅក្នុងសាលាក្ដីខ្មែរក្រហមយឺតណាស់ ហើយនឹងពុំអាចផ្ដល់យុត្តិធម៌ជូនអ្នកដែលស្លាប់នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហមបានទេ ។

### ◆ ចេង ហុង រស់នៅភ្នំពេញ

ខ្ញុំសោកស្ដាយដែលថា តាមរយៈការជួបប្រទះនូវបញ្ហាកង្វះថវិកានៅក្នុងការកាត់ទោស អៀង សារី ពុំអាចបញ្ចប់នៅមុនពេលខ្លួនស្លាប់ ។ ដោយសារវ័យចាស់ជរា និងជំងឺរបស់ខ្លួន អៀង សារី និយាយតិចបំផុតនៅក្នុងពេលកាត់ទោសខ្លួន ហើយការស្លាប់របស់ អៀង សារី យើងបាត់បង់នូវធនធានព័ត៌មានដ៏សំខាន់អំពីខ្មែរក្រហម ។

### ◆ សំបូរ ម៉ាណារ៉ា រស់នៅភ្នំពេញ

បណ្ដឹងរបស់ អៀង សារី ត្រូវបានបញ្ចប់ដោយសារការស្លាប់របស់គាត់ ។ ព័ត៌មានសំខាន់នៅក្នុងសម័យខ្មែរក្រហមត្រូវបានបាត់បង់ជារៀងរហូត ។ ខ្ញុំមានការអាណិតដល់ជនរងគ្រោះទាំងអស់ដែលតែងតែគិតថា ខ្លួននឹងទទួលបាននូវចម្លើយដ៏សមស្របសម្រាប់ទង្វើព្រៃផ្សៃ និងការឈឺចាប់ទាំងឡាយនៅក្នុងសម័យខ្មែរក្រហម ។ មេដឹកនាំខ្មែរក្រហមទាំងនោះមិនមានបំណងក្នុងការសារភាពនូវឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនោះទេ ។

យោងតាមច្បាប់អន្តរជាតិ ការកាត់ទោស អៀង សារី ត្រូវបានបញ្ចប់ដោយសារការស្លាប់របស់គាត់ ។ ការស្លាប់របស់គាត់គឺជាការខាតបង់មួយជាពិសេសចំពោះក្មេងជំនាន់ក្រោយដែលបាត់បង់នូវសាច់ញាតិបងប្អូននៅក្នុងសម័យខ្មែរក្រហមនឹងលែងមានឱកាសដើម្បីរៀនអំពីការពិតដែលបានកើតឡើងនៅក្នុងអតីតកាល ។ រដ្ឋាភិបាលនិងសហគមន៍អន្តរជាតិត្រូវទទួលខុសត្រូវចំពោះហេតុការណ៍ដ៏គួរឲ្យសោកស្ដាយមួយនេះ ។ ក្នុងនាមជាអ្នកប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវ ខ្ញុំមិនអាចបញ្ចេញយោបល់ថាតើ អៀង សារី បានប្រព្រឹត្តឧក្រិដ្ឋកម្មមែនឬអត់ ពីព្រោះតុលាការមិនទាន់បានបញ្ចប់ការងារនោះទេ ។

### ◆ ហឹម ហ៊ុយ អតីតកម្មាភិបាលនៅមន្ទីរស-២១

យើងមិនបានទាញយកព័ត៌មានពី អៀង សារី បានទេ ដោយសារគាត់បានធ្លាក់ខ្លួនឈឺយូរមកហើយ ។ ខ្ញុំគិតថា តុលាការនៅតែអាចរកយុត្តិធម៌បានតាមរយៈការកាត់ទោសមេដឹកនាំខ្មែរក្រហមពីររូបទៀត ។

### ◆ សូហ៊ីយ៉ាន គាយិប អាយុ៩០ឆ្នាំ នៅខេត្តបាត់ដំបង

ខ្ញុំសោកស្ដាយយ៉ាងខ្លាំងចំពោះការស្លាប់របស់ អៀង សារី ព្រោះសំណួរជាច្រើនទាក់ទិននឹងខ្មែរក្រហម គាត់ពុំបានផ្ដល់ចម្លើយនៅឡើយទេ ។ បើទោះជាការស្លាប់របស់គាត់ជាសេចក្ដីបញ្ចប់នៃរឿងក្ដីគាត់ ប៉ុន្តែខ្ញុំគិតថា សាលាក្ដីបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនហើយ ព្រោះសាលាក្ដីនេះបានខំអស់ពីលទ្ធភាពដើម្បីស្វែងរកយុត្តិធម៌ឲ្យប្រជាជន ។

### ◆ សុបលី អាលីអូស្មាន់ អាយុ៤៩ឆ្នាំ ជាអ៊ីមាំខេត្តតាកែវ

ដំណឹងមរណភាពរបស់ អៀង សារី ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលណាស់ ព្រោះថាខ្ញុំពុំសូវជាបានតាមដានព័ត៌មានប៉ុន្មានទេ ។ ទោះបីជាយ៉ាងនេះក្ដី ការស្លាប់របស់គាត់វាជារឿងមុន និងក្រោយប៉ុណ្ណោះ ដោយសារសុខភាពរបស់គាត់ចុះអន់ខ្សោយជាយូរណាស់មកហើយ ។ ខ្ញុំគិតថាសាលាក្ដីខ្មែរក្រហមគប្បីពន្លឿនល្បឿននៃការកាត់ក្ដីដើម្បីផ្ដល់យុត្តិធម៌ឲ្យប្រជាជនយើង ។ ខ្ញុំសោកស្ដាយណាស់ដែលតុលាការមិនបានកាត់ទោសគាត់ ប៉ុន្តែការដែលគាត់ត្រូវជាប់ឃុំឃាំងកន្លងមក ក៏អាចចាត់ទុកថាជាទារុណកម្មមួយ

សម្រាប់គាត់ដែរ ។

**◆ នុត ស្វេស អាយុ៣៩ឆ្នាំ ជាមន្ត្រីរាជការ**

ការស្លាប់របស់គាត់មិនមានអ្វីគួរអោយភ្ញាក់ផ្អើលទេ ព្រោះគាត់មានវ័យចំណាស់ហើយ ។ បើទោះជាសំណុំរឿងរបស់គាត់ត្រូវបានបិទ ការកាត់ទោសមេដឹកនាំខ្មែរក្រហមពីររូបទៀតនៅតែបន្ត ។ ខ្ញុំគាំទ្រយ៉ាងពេញទំហឹងចំពោះការខិតខំប្រឹងប្រែងរបស់សាលាក្តីខ្មែរក្រហមក្នុងការស្វែងរកយុត្តិធម៌ឲ្យប្រជាជន ព្រោះនេះអាចសបញ្ជាក់ឲ្យឃើញថា យើងកំពុងរស់នៅក្នុងសង្គមមួយដែលដឹកនាំដោយច្បាប់ ។ ថ្វីត្បិតតែការស្លាប់របស់គាត់ជួយឲ្យគាត់រួចផុតពីការកាត់ទោសតាមផ្លូវច្បាប់ ប៉ុន្តែកេរ្តិ៍ឈ្មោះអសោចរបស់គាត់នឹងត្រូវបានកត់ត្រាជាប្រវត្តិសាស្ត្រ ។

**◆ សំ បូរ័ត្ន ជាគ្រូបង្រៀន ក្នុងខេត្តបន្ទាយមានជ័យ**

ការស្លាប់របស់គាត់បាននាំទៅជាមួយរឿងរ៉ាវពិតប្រាកដជាច្រើនក្នុងសម័យខ្មែរក្រហម ហើយសាលាក្តីនឹងត្រូវបញ្ចប់ដោយមិនពេញលក្ខណៈ ។

**◆ អម សុផល ជាគ្រូបង្រៀន ក្នុងខេត្តព្រៃវែង**

ខ្ញុំមានការសោកស្តាយចំពោះការស្លាប់របស់គាត់ ដោយសារគាត់ពុំបានសារភាពនូវអ្វីដែលគាត់បានធ្វើនៅឡើយ ហើយប្រជាជនកម្ពុជាក៏ពុំទទួលបានយុត្តិធម៌ ។ អៀង សារី គឺជាមេដឹកនាំកំពូលក្នុងសម័យខ្មែរក្រហម ការស្លាប់នេះធ្វើឲ្យយើងបាត់បង់នូវចម្លើយជាច្រើន ដែលបណ្តាលឲ្យដំណើរការនៃការកាត់ក្តីកាន់តែមានភាពលំបាកឡើង ។

**◆ អ៊ូ បាណុង អាយុ២៤ឆ្នាំ និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកសារព័ត៌មាន និងទំនាក់ទំនង**

ខ្ញុំដឹងច្បាស់ពីស្ថានភាពសុខភាពរបស់ អៀង សារី ការស្លាប់របស់គាត់គ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ ។ ខ្ញុំសូមចូលរួមរំលែកមរណទុក្ខនេះ ប៉ុន្តែខ្ញុំមានអារម្មណ៍សោកស្តាយណាស់ដោយសារតែយើងបានបាត់បង់នូវចុងចោទមួយយ៉ាងសំខាន់ក្នុងសំណុំរឿង ០០២ ។ នេះជាការបាត់បង់មួយយ៉ាងធំចំពោះក្មេងជំនាន់ក្រោយ ដោយសាររឿងរ៉ាវ និងទង្វើដ៏ឃោរឃៅជាច្រើនក្នុងសម័យខ្មែរក្រហមនៅមិនទាន់បានលាតត្រដាង ។

**◆ កែវ សុភ័ក្ត្រ អាយុ២៤ឆ្នាំ ជាសិស្សនៃវិទ្យាស្ថានកិច្ចសហប្រតិបត្តិការអន្តរជាតិកម្ពុជា**

កើត ចាស់ ឈឺ ស្លាប់ជារឿងធម្មតារបស់មនុស្សជាតិ ខ្ញុំពុំមានការភ្ញាក់ផ្អើលចំពោះដំណឹងមរណភាពរបស់ អៀង សារី ទេ ។ ខ្ញុំគិតថា ការស្លាប់នេះមានផលវិជ្ជមាន និងអវិជ្ជមាន ។ ចំពោះចំណុចអវិជ្ជមានគឺយើងបាត់បង់នូវឱកាសស្វែងយល់ពីមូលហេតុនៃអំពើប្រល័យពូជសាសន៍នាសម័យខ្មែរក្រហម ។ ចំណុចវិជ្ជមាននោះ គឺគាត់បានរួចផុតពីទុក្ខទោស និងបានគេចផុតពីកំហឹងរបស់ប្រជាជន ។

**◆ ពៅ គឹមថង ភេទស្រី អាយុ២៥ឆ្នាំ ជានិស្សិតនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

ខ្ញុំមានការព្រួយបារម្ភថា តើសំណុំរឿង០០២នឹងបន្តដំណើរការដោយរបៀបណានៅពេលដែលពុំមានវត្តមានរបស់ អៀង សារី ព្រោះមានតែរូបគាត់ទេដែលជាអ្នកអាចបកស្រាយបំភ្លឺពីសកម្មភាពរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។

**◆ ឈន វាសនា ភេទប្រុស អាយុ២២ឆ្នាំ ជានិស្សិតឆ្នាំទី៤ ផ្នែកច្បាប់នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

«ខ្ញុំយល់ថា ការស្លាប់របស់គាត់លឿនពេក ហើយការស្លាប់របស់គាត់ជាការបាត់បង់នូវដំណើរការតុលាការ ដោយសារគាត់មានចម្លើយជាច្រើន ។ ឆ្លងកាត់តាមការសិក្សារបស់ខ្ញុំ គាត់ជាអ្នកអនុវត្តគោលនយោបាយផ្ទាល់នៅក្នុងសម័យខ្មែរក្រហមពេលដែលគាត់ថា គាត់ជាអ្នកស្នេហាជាតិ ។ ក្រោមការអះអាងនេះគឺគាត់បានធ្វើទារុណកម្មប្រជាជនជាច្រើននាក់» ។

◆ សុះ មីន ភេទប្រុស អាយុ៥៩ឆ្នាំ នៅខេត្តកំពង់ចាម «ខ្ញុំមានការខឹងសម្បាខ្លាំងណាស់ចំពោះការស្លាប់របស់ អៀង សារី ហើយភាគច្រើនខ្ញុំខឹងតុលាការដែលធ្វើការយឺតពេក ។ ខ្ញុំខឹងដែល អៀង សារី ស្លាប់ដោយមិនទាន់មានសាលក្រមច្បាស់លាស់ ។ តុលាការត្រូវតែពន្លឿនដំណើរការទៅមុខទៀត ដូច្នេះ នួន ជា និង ខៀវ សំផន នឹងត្រូវកាត់ទោស ហើយកំហុសរបស់ អៀង សារី នឹងមិនកើតឡើងទៀតទេ» ។

**◆ គេះ អែសះ អាយុ៧៤ឆ្នាំ រស់នៅខេត្តក្រចេះ**

ពេលខ្ញុំបានឮពីការស្លាប់របស់ អៀង សារី តាមវិទ្យុ

ខ្ញុំនិយាយមិនចេញ ។ ខ្ញុំបានតាមដានដំណើរការតុលាការនេះយូរមកហើយ ហើយខ្ញុំស្រឡាំងកាំងពេលឮថាគាត់ស្លាប់មុនពេលចេញសាលក្រម ។

**◆ ហាជី ស៊ុលធី អាយុ៤៥ឆ្នាំ រស់នៅខេត្តកំពង់ធំ**

តុលាការធ្វើការយឺតណាស់ ហើយខ្ញុំចាំមើលតើតុលាការនឹងធ្វើអ្វីបន្ថែមទៀតលើករណីមេដឹកនាំដែលនៅរស់ ។

**◆ សួន សាន នៅវត្តបុទុមវត្តី**

អាត្មាមានការសោកស្ដាយចំពោះការស្លាប់របស់ អៀង សារី ព្រោះថា ការស្លាប់របស់គាត់ធ្វើឲ្យយើងអស់សង្ឃឹមក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនខ្មែរដែលរងទុក្ខ និងបាត់បង់ជីវិតក្នុងជំនាន់នោះ ។ តាមសាសនាព្រះពុទ្ធ គឺគាត់នឹងទទួលផលកម្មទោះបីជាស្លាប់ទៅក៏ដោយ ។ ការស្លាប់នេះ ជាការបាត់បង់ព័ត៌មានជាច្រើន ដោយសារកាលនៅរស់ អៀង សារី បានបដិសេធមិនទទួលខុសត្រូវ ។

**◆ អាណាន់ មកពីខេត្តកំពង់ស្ពឺ**

ខ្ញុំសោកស្ដាយខ្លាំងណាស់ពេលដែលឮថា អៀង សារី ស្លាប់ ហើយសាលាក្ដីខ្មែរក្រហមក៏បាត់បង់ព័ត៌មានច្រើនដែរ ។ ដោយសារមរណភាពរបស់គាត់សម្រាប់អ្នកដែលរង់ចាំនូវភាពយុត្តិធម៌ត្រូវរង់ចាំដោយឥតបានការ ។

**◆ កែ គឹមហេង មន្ត្រីខាងដឹកជញ្ជូន**

ការស្លាប់របស់ អៀង សារី គឺជាការបាត់បង់មួយសម្រាប់សាលាក្ដីខ្មែរក្រហមដោយសារតែសាលាក្ដីនេះមិនទាន់បានជំនុំជម្រះទោស អៀង សារី ឲ្យបានចប់ចុងចប់ដើមនៅឡើយ ។ ការស្លាប់របស់គាត់នឹងកប់ទៅជាមួយនឹងយុត្តិធម៌ដែលជនរងគ្រោះបានរង់ចាំអស់រយៈពេលជាយូរមកហើយ ។

**◆ សៃ សុខុម មកពីខេត្តប៉ៃលិន**

ដោយសារតែ អៀង សារី ស្លាប់បាត់ទៅហើយ ខ្ញុំសង្ឃឹមថាប្រជាជនកម្ពុជានឹងអត់ឱនទោសដល់គាត់ ដូច្នេះគាត់នឹងអាចទៅរកសុគតិភពបាន ។ គាត់ស្លាប់ហើយ យើងមិនអាចយកអ្វីពីគាត់បានទៀតទេ ។

**◆ អាប់ឌូហ្កានី ពីន មូសា អាយុ៥០ឆ្នាំ ហាគីម នៅខេត្តស្ទឹងត្រែង**

ការស្លាប់របស់ អៀង សារី បានបន្សល់នូវភាពមិនច្បាស់លាស់ពីអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម ។ សំណួរនៅតែគ្មានចម្លើយត្រង់ថា អៀង សារី គឺជាអ្នកបញ្ជាឲ្យមានការសម្លាប់មនុស្ស ឬគ្រាន់តែជាអ្នកស្ដាប់បង្គាប់ ។ ដូច្នេះ ប្រវត្តិសាស្ត្រខ្មែរក្រហមនៅតែមិនច្បាស់ ។ ការស្លាប់របស់ អៀង សារី បានបន្សល់នូវការសោកស្ដាយយ៉ាងខ្លាំងព្រោះជនរងគ្រោះអាចគិតថា អៀង សារី បានគេចពីបទចោទទាំងឡាយនៅសាលាក្ដីខ្មែរក្រហម និងគេចពីយុត្តិធម៌ជាលើកទីពីរ ។ ក្នុងឆ្នាំ ១៩៧៩ តុលាការប្រជាជនបដិវត្តន៍ត្រូវបានបង្កើតឡើង ហើយបានកាត់ទោស ប៉ុល ពត និង អៀង សារី ប្រហារជីវិតដោយកំបាំងមុខ ។ មេដឹកនាំ នួន ជា និង ខៀវ សំផន ក៏អាចនឹងស្លាប់មុនការប្រកាសសាលក្រមដែរ ដោយសារតែសាលាក្ដីខ្មែរក្រហមកំពុងតែជួបប្រទះនូវបញ្ហាថវិកា ។ ហេតុដូច្នេះ សាលាក្ដី ត្រូវតែបង្កើតល្បឿនបន្ថែមទៀតដើម្បីឈានទៅរកការប្រកាសសាលក្រមទាក់ទងនឹងករណី០០២នេះ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

## ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសំឡេងអំពើប្រល័យពូជសាសន៍ ៖ យុត្តិធម៌ និងការអត់ឃ្មាន ដែលបានចាប់ផ្ដើមផ្សាយនៅថ្ងៃអាទិត្យ ទី៣ ខែមីនា ឆ្នាំ២០១៣ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្ដាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា AM 918KHz រាជធានីភ្នំពេញ វេលាម៉ោង៩ព្រឹក និងម៉ោង៧និង៣០នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៨រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៨រសៀល ។

*លិខិតពីអ្នកអាន*

# ការព្យាបាលរបួស និង ការផ្សះផ្សា

## គ្រួសារមួយរបស់ជនរងគ្រោះមកមើលទីតាំងព្រៃវែង

កាលពីខែធ្នូ ឆ្នាំ២០១១ មិត្តភក្តិជនជាតិខ្មែររបស់ខ្ញុំម្នាក់ឈ្មោះ ឡេង លីណា ហើយនឹងខ្ញុំបានទៅសួរសុខទុក្ខក្រុមគ្រួសាររបស់ អ៊ុច សាមីន ដែលសព្វថ្ងៃរស់នៅក្នុងខេត្តព្រៃវែងដើម្បីរាយការណ៍អំពីការស្លាប់របស់ អ៊ុច សាមីន មានអាយុ១៦ឆ្នាំដែលបានស្លាប់នៅមន្ទីរស-២១ ។ ខ្ញុំមិនដឹងថា គ្រួសាររបស់ អ៊ុច សាមីនដឹងថា អ៊ុច សាមីន ស្លាប់នៅទួលស្លែងឬក៏អត់ទេ តែជាទូទៅ ប្រជាជនកម្ពុជាមួយចំនួនមិនដឹងថា សាច់ញាតិរបស់ខ្លួនបានស្លាប់នៅទីណាទេក្នុងរបបខ្មែរក្រហម ។ អ៊ុច សាមីន គឺជាជនរងគ្រោះម្នាក់នៅមន្ទីរស-២១ ហើយដែលត្រូវបានខ្មែរក្រហមសម្លាប់នៅទីនោះ ក្នុងឆ្នាំ១៩៧៨ ។ ពេលខ្ញុំឃើញរូបថតរបស់ អ៊ុច សាមីន នៅក្នុងកម្មវិធីទូរទស្សន៍របស់អាល្លឺម៉ង់មួយ ខ្ញុំចង់ស្វែងរកប្រភពកំណើតរបស់ជនរងគ្រោះនោះ ។ ការស្វែងរកវត្តមានរបស់ អ៊ុច សាមីន មិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការជួយជ្រោមជ្រែងពីលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ ។ បន្ទាប់ពីខ្ញុំ អ៊ីម៉ែលទៅលោក ឆាំង យុ ដើម្បីសុំមើលប្រវត្តិរូបរបស់ អ៊ុច សាមីន ហើយលោកបានឆ្លើយតបមកវិញដោយភ្ជាប់ជាមួយនូវប្រវត្តិរូបរបស់ អ៊ុច សាមីន និងបញ្ជីឈ្មោះជនរងគ្រោះទាំងអស់ដែលត្រូវបានសម្លាប់ក្នុងមន្ទីរស-២១ ។ បន្ទាប់ពីខ្ញុំបានទទួលប្រវត្តិរូបរបស់ អ៊ុច សាមីន ហើយទើបខ្ញុំដឹងថា គាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៨ ហើយត្រូវបានយកទៅសម្លាប់នៅថ្ងៃបន្ទាប់ នៅឯវាលពិឃាតជើងឯក ។

នៅក្នុងខែធ្នូ ឆ្នាំដដែលនោះដែរ បន្ទាប់ពីខ្ញុំបានរកឃើញនូវប្រវត្តិរូបដែលពិពណ៌នាអំពីទីកន្លែងកំណើតរបស់ អ៊ុច សាមីន ខ្ញុំក៏បានទៅសាកសួរសុខទុក្ខអ្នកភូមិរបស់គាត់ ។ អ្វីដែលខ្ញុំរកឃើញ ហើយគួរឲ្យភ្ញាក់ផ្អើលនោះគឺថា បងប្អូនប្រុសពីររូបរបស់ អ៊ុច សាមីន ដែលរស់នៅទីនោះមិនបានដឹងថា សាមីន ត្រូវខ្មែរក្រហមបញ្ជូនទៅ និងសម្លាប់ចោលនៅពេលណា និងកន្លែងណាទេ ។ ខ្ញុំក៏បានបង្ហាញប្រវត្តិរូប និងរូបថតរបស់ អ៊ុច សាមីន ទៅបងប្អូនរបស់ប្រុសទាំងពីរនាក់របស់ អ៊ុច សាមីន ហើយអ្នកទាំងនោះតក់ស្លុតយ៉ាងខ្លាំងនៅពេលដែលឃើញប្រវត្តិរូប ព្រមទាំងរូបថតដែលអ្នកទាំងពីរមិនដែលឃើញពីមុនមកសោះ ។ បន្ទាប់ពីខ្ញុំរៀបរាប់ប្រាប់ដល់អ្នកទាំងនោះពីទីកន្លែងដែល អ៊ុច សាមីន ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ បងប្អូនទាំងពីររបស់ សាមីន បង្ហាញពីចំណាប់អារម្មណ៍ និងបំណងរបស់ខ្លួនមកទស្សនានៅមន្ទីរស-២១ ដែលឥឡូវនេះត្រូវបានស្គាល់ថាជា "សារមន្ទីរទួលស្លែង" និងចង់មកមើលវាលពិឃាតជើងឯក ។ ខ្ញុំផ្ទាល់ក៏បាននាំអ្នកទាំងនោះទៅទស្សនាកន្លែងទាំងពីរនេះ ។

ខែធ្នូ ឆ្នាំ២០១១ នោះដែរ ខ្ញុំបានមកដល់ប្រទេសកម្ពុជា ។ លីណា ហើយនិងខ្ញុំបានទាក់ទងលោក ញាណ សុជាតិ នៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សុជាតិ បានជួយយកអាសារ និងលើកទឹកចិត្តឲ្យយើងនាំក្រុម



ប្អូនប្រុសរបស់ អ៊ុច សាមីន ឈ្មោះ អ៊ុច គីប (ឆ្វេង) និង អ៊ុក ហាង (រស់នៅជាមួយគ្រួសារ សាមីន តាំងពី សាមីនមិនទាន់កើតមកម្ល៉េះ) ថតនៅទួលស្លែងកាលពីខែធ្នូ ឆ្នាំ២០១២ ។

គ្រួសាររបស់ អ៊ុច សាមីន មកទស្សនាគុកទួលស្លែង និងវាលពិឃាតជើងឯក ជាកន្លែងដែល អ៊ុច សាមីន ត្រូវបានខ្មែរក្រហមសម្លាប់ ។

មួយឆ្នាំក្រោយមក នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១២ ខ្ញុំបានចាកចេញពីប្រទេសអាល្លឺម៉ង់ ហើយបានមកដល់ប្រទេសកម្ពុជា ។ លីណា និងខ្ញុំបានណាត់ជួប សុជាតិ នៅឯការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅអំឡុងនៃការណាត់ជួបនោះ យើងបានពិភាក្សាគ្នាអំពីលទ្ធភាពដែលអាចនាំយកក្រុមគ្រួសាររបស់ អ៊ុច សាមិន មកកាន់ទីក្រុងភ្នំពេញ ហើយ សុជាតិ សន្យាថា នឹងព្យាយាមជួយស្វែងរកនូវលេខទូរស័ព្ទរបស់អាជ្ញាធរភូមិឃុំដើម្បីឲ្យអាជ្ញាធរជួយទៅប្រាប់បងប្អូនរបស់ អ៊ុច សាមីន ដែលរស់នៅក្នុងខេត្តព្រៃវែង ។ យើងក៏ត្រឡប់ទៅផ្ទះវិញក្រោយពីជួប សុជាតិ រួច ។ មិនដល់មួយម៉ោងផង យើងបានទទួលទូរស័ព្ទពី សុជាតិ ដែលបាននិយាយថា គាត់រកបាន លេខទូរស័ព្ទទំនាក់ទំនងរបស់បងប្អូន អ៊ុច សាមីន ហើយតាមរយៈមេភូមិ ។ បន្ទាប់មកទៀត លីណា បានទូរស័ព្ទទៅបងប្អូនប្រុសរបស់ អ៊ុច សាមីន ដែលយើងធ្លាប់ជួបកាលពីខែធ្នូ ឆ្នាំ២០១១ម្តងរួចទៅហើយ ។ យើងមានការតក់ស្លុតនៅពេលដែលដឹងថា បងប្អូនប្រុសរបស់ អ៊ុច សាមីន ម្នាក់ទើបតែបានស្លាប់ក្នុងរយៈពេលពីរបីខែមុននេះដោយខប្បត្តិហេតុលង់ទឹក ។ ចុងក្រោយយើងនិយាយជាមួយបងប្អូនប្រុសម្នាក់របស់ អ៊ុច សាមីន ។ យើងនិយាយទៅកាន់គាត់ ហើយនឹងអញ្ជើញគាត់ ព្រមទាំងសមាជិកគ្រួសារគាត់ចំនួនប្រាំបីរូប រួមទាំងញាតិសន្តានមកទីក្រុងភ្នំពេញ ។

អ្នកទាំងអស់ក៏បានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញ ។ បងប្អូនរបស់ អ៊ុច សាមីន ដែលកូនស្លាប់ដោយសារលង់ទឹកក៏បានចូលរួមដំណើរមកភ្នំពេញដែរ ដោយទឹកមុខក្រៀមក្រំ ។ លីណា ហើយនិងខ្ញុំក៏សោកស្តាយដែរ ចំពោះការបាត់បងបងប្រុសរបស់ អ៊ុច សាមីន ដែលយើងធ្លាប់បានជួបកាលពីខែធ្នូឆ្នាំ២០១១ ។

បន្ទាប់ពីអ្នកទាំងនោះមកដល់ភ្នំពេញ លីណា បានរៀបចំនូវអាហារថ្ងៃត្រង់នៅផ្ទះរបស់គាត់ ។ បន្ទាប់មកទៀត យើងក៏ចាប់ផ្តើមដំណើរទៅកាន់សារមន្ទីរទួលស្លែង ដោយដើររួមគ្នាពីបន្ទប់មួយទៅកាន់បន្ទប់មួយទៀត ដោយមើលគ្រប់ទិដ្ឋភាពទាំងអស់ ព្រមទាំងរូបថតរាប់ពាន់ រាប់ម៉ឺនសន្លឹកដែលដាក់តាំងនៅទីនោះ ។

នៅសារមន្ទីរទួលស្លែងគឺថាសមាជិកក្រុមគ្រួសាររបស់ អ៊ុច សាមីន ដែលមកទស្សនាចំនួនប្រាំបួននាក់ បានដើរមើលដោយស្ងៀមស្ងាត់ ប៉ុន្តែរឹតតែស្ងៀមស្ងាត់ និងការក្រៀមក្រំ តក់ស្លុតបន្ទាប់ពីអ្នកទាំងនោះបានឃើញបន្ទប់មួយដែលជាបន្ទប់សម្រាប់ធ្វើទារុណកម្ម រួមជាមួយនឹងរូបភាពរបស់អ្នកទោសដែលបានស្លាប់និងឧក្រិដ្ឋកម្មផ្សេងៗដែលបានកើតឡើងនៅទីនោះ ។ រូបភាពមួយដែលម្តាយកំពុងបីកូននៅលើដៃទាំងពីររបស់ខ្លួន បង្ហាញពីភាពអមនុស្សធម៌ និងអំពើដ៏សាហាវយង់ឃ្នង ។ ឧបករណ៍សម្រាប់ធ្វើទារុណកម្ម បង្ហាញពីកម្រិតនៃការធ្វើទារុណកម្មមកលើអ្នកទោស ។ ក្រុមគ្រួសាររបស់ អ៊ុច សាមីន ចំណាយពេលយ៉ាងយូរពិនិត្យមើលបន្ទប់នីមួយៗ ។ ខ្ញុំក្រលេកមើលរូបភាពអ្នកទោសនៅក្នុងមន្ទីរស-២១ទាំងអស់ និងរូបកម្មាភិបាលខ្មែរក្រហមដែលមានបិទតាំងនៅលើក្តារខៀនក្នុងសារមន្ទីរ ។ ខ្ញុំចាប់ផ្តើមក្រឡេកទៅមើលរូបរបស់ អ៊ុច សាមីន ហើយនឹកឆ្ងល់ថា ហេតុអ្វីដែលបណ្តាលឲ្យក្មេងស្រីរូបនេះត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់នៅថ្ងៃបន្ទាប់ដូច្នេះ ។ តាមរយៈរូបថតរបស់ អ៊ុច សាមីន ហាក់បីដូចជាមានសុខភាពល្អធម្មតាទេ ក្នុងអំឡុងពេលដែលខ្មែរក្រហមចាប់ខ្លួនគាត់ ។ តើខ្មែរក្រហមសម្លាប់គាត់ដោយរបៀបណា ។ ខណៈពេលដែលខ្ញុំព្យាយាមក្រឡេកទៅមើលរូបថតជនរងគ្រោះផ្សេងៗទៀតដោយប្រុងប្រយ័ត្ន ជួនកាលខ្ញុំហាក់ដូចជាចំណាំមនុស្សមួយចំនួននៅក្នុងរូបថត តែជាក់ស្តែង គ្រាន់តែជាការស្រមើស្រមៃតែប៉ុណ្ណោះ ។

នៅពេលដែលក្រុមគ្រួសាររបស់ អ៊ុច សាមីន ឃើញរូបថតរបស់ អ៊ុច សាមីន គាត់ក៏បានយកដៃស្ទាបមុខនៅលើរូបថតនោះដោយអារម្មណ៍សង្វេគ បើទោះបីជាអ្នកទាំងនោះធ្លាប់បានឃើញរូបថតនេះរួចមកហើយ នៅពេលដែលខ្ញុំទៅសួរសុខទុក្ខក្រុមគ្រួសាររបស់គាត់នៅក្នុងខែធ្នូ ឆ្នាំ២០១១ក៏ដោយ ។ វាហាក់បីដូចជាអ្នកទាំងនោះព្យាយាមទាក់ទងតាមអារម្មណ៍ទៅកាន់បងប្អូនស្រីជាទីស្រឡាញ់របស់ខ្លួន ។ អារម្មណ៍ និងមនោសញ្ចេតនារបស់អ្នកទាំងនោះ បានដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំជាខ្លាំង ។

សុជាតិ បានបញ្ជូនបុគ្គលិកម្នាក់ដើម្បីទៅសម្ភាសន៍ក្រុមគ្រួសាររបស់ អ៊ុច សាមីន នៅក្នុងបរិវេណសារមន្ទីរទួលស្លែង ព្រមទាំងបានថតសំឡេងអ្នកទាំងនោះផង ។ ដោយសារតែការសម្ភាសន៍នេះធ្វើឡើងជាភាសាខ្មែរ ខ្ញុំមិនបានដឹងថាតើអ្នកទាំងនោះ

និយាយអ្វីខ្លះទេ ។ ប៉ុន្តែជាក់ស្តែង ខ្ញុំអាចស្មានបានថា គ្រួសាររបស់ អ៊ុច សាមីន រៀបរាប់អំពីពេលដែលគាត់នៅជាមួយ អ៊ុច សាមីន នាសម័យមុនសង្គ្រាម ។

បន្ទាប់ពីពិនិត្យនៅគ្រប់អគាររួចហើយនោះ យើងទាំងអស់គ្នាបានឈប់សម្រាកមួយស្របក់ ហើយបន្ទាប់មក យើងបានទៅជួបមនុស្សម្នាក់នៅក្នុងក្នុងបរិវេណសារមន្ទីរនេះ ។ អ្នកនោះគឺ ជុំ ម៉ី ដែលជាអ្នករួចរស់ជីវិតម្នាក់ពីមន្ទីរស-២១ផ្ទាល់ ហើយសព្វថ្ងៃគាត់កំពុងតែលក់សៀវភៅដែលរៀបរាប់ពីសាច់រឿងផ្ទាល់របស់គាត់នៅក្នុងមន្ទីរស-២១នេះ និងសៀវភៅមួយចំនួនទៀតអំពីរបបខ្មែរក្រហម ។ ខ្ញុំធ្លាប់បានអានសៀវភៅរបស់គាត់ខ្លះដែរអំពីបទពិសោធន៍សោកនាដកម្មដ៏គួរឲ្យរន្ធត់នេះ ។

បងប្រុសរបស់ អ៊ុច សាមីន បានយករូបថតរបស់ អ៊ុច សាមីន មកជាមួយគាត់ ហើយបានបង្ហាញរូបថតនេះទៅកាន់ ជុំ ម៉ី ដែលបានមើលរូបថតនោះដោយយកចិត្តទុកដាក់ ។ បន្ទាប់ពីបានក្រឡេកមើលលើរូបថតនេះ ជុំ ម៉ី និយាយភ្លាមថា គាត់ស្គាល់ក្មេងស្រីនៅក្នុងរូបថតនេះ គឺ អ៊ុច សាមីន ។ ជុំ ម៉ី បាននិយាយទៀតថា មុនពេលត្រូវបានចាប់ខ្លួន គាត់និង អ៊ុច សាមីន ធ្វើការនៅរោងចក្រដេរក្រណាត់ជាមួយគ្នា នៅជិតផ្សារអូឫស្សី ក្នុងក្រុងភ្នំពេញ ។ គាត់និយាយថា អ៊ុច សាមីន នៅទីនោះជាអ្នកកាត់ដេរ ចំណែកឯគាត់កាន់ផ្នែកម៉ាស៊ីន ។ វាគឺជារឿងមួយដ៏កម្រដែលថា ជុំ ម៉ី ធ្លាប់ស្គាល់ អ៊ុច សាមីន ។ តើនេះជាភាពចៃដន្យឬ?

ខ្ញុំនៅតែមានចម្ងល់ថា តើហេតុអ្វីបានជាខ្ញុំផ្តោតការយកចិត្តទុកដាក់លើការទស្សនាដំបូងនៅក្នុងមន្ទីរស-២១ក្នុងឆ្នាំ២០០៣ ដោយគ្រាន់តែឃើញរូបថតរបស់ អ៊ុច សាមីន ក្នុងចំណោមរូបថតរាប់រយរាប់ពាន់សន្លឹក ។ សម្រាប់ខ្ញុំ នៅពេលដែលខ្ញុំក្រឡេកឃើញរូបថតរបស់ អ៊ុច សាមីន វាហាក់បីដូចជាថា គាត់ចង់និយាយអ្វីមួយមករកខ្ញុំ ដូចជាពាក្យ «មើលមកខ្ញុំ អ្នកនឹងដឹងថា អ្នកបានធ្វើអ្វីខ្លះមកលើខ្ញុំ» ។ នេះប្រហែលជាហេតុផលដែលធ្វើឲ្យខ្ញុំចាប់ផ្តើមស្វែងយល់ពី អ៊ុច សាមីន ។

លើសពីនេះខ្ញុំក៏បានរកឃើញរូបថតរបស់ អ៊ុច សាមីន នៅលើក្របសៀវភៅមួយដែរ ។ អ្នកណាដឹងថា តើក្រុមគ្រួសាររបស់ជនរងគ្រោះនឹងមានអារម្មណ៍យ៉ាងណា នៅពេលដែលឃើញឆ្អឹងលលាដ៍ក្បាល និងសម្លៀកបំពាក់ដែលនៅសេសសល់របស់ជនរងគ្រោះ ។ ឆ្អឹងលលាដ៍ក្បាលរបស់ជនរងគ្រោះខ្លះ បានបង្ហាញថា ខ្លួនត្រូវសម្លាប់ដោយសារការកាប់ដោយពូថៅ និងដំបងដែក ។ លើសពីនេះ ជនរងគ្រោះត្រូវជីកផ្នូរសម្រាប់កប់ខ្លួនឯង មុនពេលខ្មែរក្រហមសម្លាប់ ។ ការបញ្ជូនអ្នកទោសទៅសម្លាប់ធ្វើឡើងជារៀងរាល់យប់ ។ អ្វីដែលពិបាក និងមិនគួរឲ្យជឿ គឺថា យើងមិនដឹងថាតើអ្នកទោសពិតជាស្រែកថ្ងូរ និងឈឺចាប់ប៉ុណ្ណាទេ នៅពេលវាយនោះ ។ ចំណែកឯនៅវាលជើងឯក ដើមឈើធំៗជាច្រើនត្រូវបានប្រើសម្រាប់សម្លាប់កូនក្មេងឬទារក ដោយសម្លាប់ដោយការបោកផ្ទប់ទៅនឹងដើមឈើនេះ ។ ផ្នូរសាកសពភាគច្រើនមិនទាន់បានគាស់កកាយនៅឡើយទេ តែនៅជិតផ្នូរដែលបានគាស់កកាយហើយ យើងនឹងឃើញមានកម្ទេចកំទីឆ្អឹង សម្លៀកបំពាក់ និងរបស់របរផ្សេងទៀតរបស់អ្នកទោស ។

នៅល្ងាចថ្ងៃដដែលនោះដែរ ក្រុមគ្រួសាររបស់ អ៊ុច សាមីន បានត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញនៅខេត្តព្រៃវែង ។ បន្ទាប់ពីការទស្សនាសារមន្ទីរទួលស្លែង និងជើងឯករួច អ្នកទាំងនោះបានបង្ហាញពីការដឹងគុណនិងថ្លែងអំណរគុណមកកាន់យើង ដោយសារដំណើរទស្សនកិច្ចនេះគឺជាអ្វីដែលអ្នកទាំងនោះចង់បានយូរហើយ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ភាសន៍បងប្រុស ព្រមទាំងសាច់ញាតិរបស់ អ៊ុច សាមីន ។ សាច់ញាតិរបស់ អ៊ុច សាមីន ស្គាល់ អ៊ុច សាមីន តាំងពីពេលគាត់ចាប់កំណើតមក ។ សម្រាប់ខ្ញុំ បន្ទាប់ពីការទស្សនាកន្លែងដែល អ៊ុច សាមីន ត្រូវបានចាប់ខ្លួន និងសម្លាប់កាលពីច្រើនជាង៣៥ឆ្នាំមុន អាចព្យាបាលរបួសផ្លូវចិត្តរបស់អ្នកទាំងនោះ បានប្រសើរឡើងទោះជាតិច ឬច្រើនក៏ដោយ ។ លីណានិងខ្ញុំពិតជាថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក ឆាំង យុ និងលោក ញាណ សុជាតិ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ការជួយខ្នះខ្នែង ដូចជា ការផ្តល់ព័ត៌មានអំពី អ៊ុច សាមីន និងព្យាយាមស្រាវជ្រាវរកលេខទូរស័ព្ទទំនាក់ទំនងរបស់ក្រុមគ្រួសារ អ៊ុច សាមីន ។ នេះជាហេតុដែលធ្វើឲ្យការដំណើរទស្សនកិច្ចនេះប្រព្រឹត្តទៅបានដោយរលូន ។ បន្ទាប់ពីនោះមក ខ្ញុំមានអារម្មណ៍ពិតជារីករាយក្នុងចិត្តជាខ្លាំងដោយសារខ្ញុំអាចសម្រេចអ្វីដែលខ្ញុំបានធ្វើ ។

**ឡេង លីណា និង គាល ហេនរេធ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 159, March 2013 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.